ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Mar-2017, 14:28
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី៣៣០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រមនិលណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ័ង

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកនីកូឡាស គូមជែន
*(Mr.Nicolas KOUMJIAN)*

លោក សេង លាង

លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុនអរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រកូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ*(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡេប ជុនធី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក រ៉ិចច័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក សេង លាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡេា ជុនធី | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក ហ៊ីម ម៉ាន (2-TCCP-252) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី: លោក ហ៊ិម ម៉ាន** (2-TCCP-252)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ២៣
សួរដោយលោក ឡោ ជុនធី ផ្តើមពី........ ទំព័រ ២៥
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........ ទំព័រ ៤៣
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្តើមពី........ ទំព័រ ៥0

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[0៩:0៣:0៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-252។ ហើយមុននឹងស្តាប់សក្ខីកម្មសាក្សីអង្គជំនុំជម្រះនឹងស្តាប់បឋមអំពីកម្មវត្ថុនៃសំណើសុំរបស់លោកមេធាវី វ៉ិចទ័រ កូប៉េ ដែលប៉ុនប៉ងលើកកាលពីម្សិលមិញ ហើយព្រមទាំងពេលវេលាដែលត្រូវធ្វើសេចក្តីថ្លែងការណ៍ពាក់ព័ន្ធជាមួយនឹងការបង្ហាញអំពីសំណើ និងមូលហេតុនៃសំណើសុំទាំងរបស់ខ្លួន -- របស់លោកផង។

ក្រឡាបញ្ជីសវនាការលោកស្រី -- កញ្ញា ជា ស៊ីវហ៊ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្តឹងដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCCP-252។ ដើមបណ្តឹងរូបនេះ មានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ស៊ីវហ៊ង។ ជាបឋមនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជាមុនសិន។ អង្គជំនុំជម្រះ បានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាពឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និង

ដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធិភាព ខ្លួនសុំលះបង់សិទ្ធិ និងមានវត្តមានដោយយផ្ទាល់ ក្នុងបន្ទប់សវនាការ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ដែលបានកត់សម្គាល់អំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា ថ្ងៃនេះថា មានអាការៈឈឺចង្កេះរឹងរៃ ហើយមិនអាចអង្គុយយូរបាន និងផ្តល់អនុសាសន៍ថា សូអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ នៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះ មុននឹងឈានដល់ការស្តាប់នូវសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីមួយរូប អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវី វ៉ិចទ័រ កូប៉េ សុំឲ្យបង្ហាញបឋមទី១ថាតើសំណើបញ្ហាអ្វីខ្លះដែលលោកមានបំណង។ ទី២ថាតើការប៉ាន់ប្រមាណនៃពេលវេលាដែលលោកនឹងធ្វើសេចក្តីថ្លែងការណ៍អំពីបង្ហាញមូលហេតុ និងសំអាងហេតុនៃការសំណើសុំរបស់លោកនោះ ប្រហែលត្រូវការចំណាយពេលវេលាប៉ុន្មាន។

[០៩:០៧:០៥]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ អរុណសួស្តីលោក លោកស្រីចៅក្រម។ លោកប្រធានខ្ញុំត្រូវការពេលវេលា១៥ នាទី។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េះ**

បាទ សូមអរគុណ។ លោកប្រធានកាលពីពីរថ្ងៃមុននេះសហព្រះរាជអាជ្ញាអន្តរជាតិ នីកូឡាស គូមជែន បានដាក់សំណើសុំមួយដើម្បីសុំឲ្យកោះហៅសាក្សីបីនាក់បន្ថែមទៀតទាក់ទងទៅនឹងការប្រព្រឹត្ត មកលើជនជាតិចាម។ សំណើសុំនេះត្រូវបានចុះហត្ថលេខាដោយគាត់តែម្នាក់ឯងតែប៉ុណ្ណោះ មិនមាន ហត្ថលេខាពីសហព្រះរាជអាជ្ញាជាតិលោកស្រី ជា លាង នៅលើឯកសារលេខ E366 ទេ។ សាក្សីពីរ នាក់ក្នុងចំណោមសាក្សីបីនាក់ដែលបានលើកឡើងក្នុងឯកសារ E366 គឺថាត្រូវបានស្នើសុំដោយទាំង សហព្រះរាជអាជ្ញាអន្តរជាតិ និងសហព្រះរាជអាជ្ញាជាតិ។ ពួកគាត់បានស្នើសុំមុនថ្ងៃទី០៩ ខែឧសភា ២០១៤។ ហេតុដូច្នេះហើយបានជាសាក្សីទាំងពីរនេះគឺថាត្រូវបានផ្តល់លេខ TCW ទី១ គឺ 2-TCW-938 និងម្នាក់ទៀត 2-TCW-894។ ចំណុចសំខាន់ -- សាក្សីដែលសំខាន់គឺហាក់បីដូចជា សាក្សី 2-TCW-938 នេះទេ។ សាក្សីរូបនេះគឺថាបានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការរួចនៅក្នុងសំណុំរឿង ០០២/០១ គឺនៅដើមឆ្នាំ២០១២។ ខ្ញុំហាក់បីដូចជា មានភាពមិនច្បាស់លាស់បន្តិចចំពោះកាលបរិច្ឆេទ ដើម្បីធានាឲ្យច្បាស់ ឲ្យបានច្បាស់អំពីអត្តសញ្ញាណសាក្សីរូបនេះ។ នៅក្នុងសំណើសុំពីសហព្រះរាជ អាជ្ញាអន្តរជាតិ គូមជែន យើងអាចដឹងថា សាក្សី 2-TCW-938 គឺថាបានផ្តល់សក្ខីកម្មប្រាំដងរួមមក ហើយនៅក្នុងសំណុំរឿង០០៤។ សក្ខីកម្មទាំងនេះត្រូវបានប្រមូលចងក្រងនៅក្នុងឆ្នាំ២០១៣ ហើយ ក្រោយមកសក្ខីកម្មនេះក៏ត្រូវបានដាក់នៅក្នុងសំណុំរឿង០០៤នៅក្នុងខែធ្នូ ឆ្នាំ២០១៤។ ក្រោយមកសក្ខី-កម្មក៏ត្រូវបានបង្ហាញជូនទៅដល់មេធាវីការពារក្តី និងភាគីដទៃទៀតនៅក្នុងសំណុំរឿងរបស់យើងនៅខែ កុម្ភៈ ២០១៥ ហើយក៏បានទទួលយកទៅធ្វើជាភស្តុតាងនៅថ្ងៃទី១៧ កក្កដា ២០១៥ ប៉ុន្តែអង្គជំនុំជម្រះ បានសម្រេចនៅក្នុងខែសីហា ២០១៥ ថាមិនកោះហៅសាក្សី2-TCW-938 និង2-TCW-894 ទេ។ យោងទៅតាមសហព្រះរាជអាជ្ញាអន្តរជាតិ សាក្សីពីរនាក់នេះ ឥឡូវនោះអាចដកស្រង់ -- អាចផ្តល់ សូមដកស្រង់ "នូវភស្តុតាងដ៏សំខាន់" នៃ<អត្ថិ>ភាពនៃផែនការដើម្បីកម្ចាត់ជនជាតិចាមទាំងក្រុមចោល ជាប្រព័ន្ធតែម្តង។ សូមដកស្រង់ "អំពីភាពលម្អិតនៃផែនការដែលត្រូវបានបញ្ជាតាមឋានានុក្រមពីតំបន់ ៤១ ទៅថ្នាក់ស្រុក និងថ្នាក់ឃុំសម្រាប់ការអនុវត្ត"។ យោងទៅតាមសហព្រះរាជអាជ្ញាអន្តរជាតិ ភស្តុ-តាងនេះសំដៅគឺការបញ្ហាដែលសំខាន់នៅក្នុងរឿងក្តីនេះ ទោះបីជាការសម្លាប់ទ្រង់ទ្រាយធំៗនៃជនជាតិ ចាម គឺថាត្រូវបានប្រព្រឹត្តឡើងដោយអនុលោមទៅតាមគោលនយោបាយរបស់មេដឹកនាំបក្សកុម្មុយនីស្ត កម្ពុជាក្តី។ យោងទៅតាមសាក្សី 2-TCW-938 និងសាក្សី 2-TCW-894 តាមការយល់ឃើញរបស់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សហព្រះរាជអាជ្ញាអន្តរជាតិ សូមដកស្រង់៖ “ប្រហែលជាសាក្សីពីរនាក់នេះគឺថាជាសាក្សីដ៏សំខាន់សម្រាប់សវនាការវគ្គនេះ” បញ្ចប់ការដកស្រង់។ ដោយពិចារណា សូមដកៗស្រង់៖ “ចំណុចសំខាន់នៃភស្តុតាងដែលជាភស្តុតាងពាក់ព័ន្ធទៅនឹងបញ្ហាដ៏សំខាន់នៅខាងក្រោយការកំណត់គោលដៅមកលើជនជាតិចាម និងក្រុមដទៃទៀត។ ដូច្នេះតាមការយល់ឃើញរបស់សហព្រះរាជអាជ្ញាអន្តរជាតិថាត្រូវតែកោះហៅសាក្សីទាំងពីរនាក់នេះ។

[០៩:១២:២០]

<ក្រោយពីបានសង្ខេបសំណើសុំនេះ> ទី១ គឺថាយើងមានសំណើ<>ពីរ<ដើម្បីសុំការ>បញ្ជាក់<។> ដូចដែលខ្ញុំទើបដែលបានលើកឡើង សាក្សី2-TCW-938 បានផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះរួចហើយ ហើយសាក្សីរូបនេះក្រោយមកក៏ត្រូវបានសហព្រះរាជអាជ្ញាអន្តរជាតិ និងសហព្រះរាជអាជ្ញាជាតិស្នើសុំនៅក្នុងសំណុំរឿង០០២/០២”។ សំណួរដែលខ្ញុំស្នើសុំឱ្យមានការបញ្ជាក់នោះថាហេតុអ្វីបាន<ជាពេលនេះមាន>តែសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំ<កោះហៅសាក្សីរូប>នេះ<?> ខ្ញុំថ្ងៃនេះគឺថាស្នើសុំឱ្យសហព្រះរាជអាជ្ញាជាតិបញ្ជាក់គឺលោកស្រីជា លាង, ហេតុអ្វីក៏មិនចុះហត្ថលេខាទៅលើឯកសារ E366<?> តើមានអ្វីកែប្រែ<ចន្លោះពី>ខែឧសភា <២០១៤> មកដល់ឥឡូវនេះមានអ្វីខ្លះកែប្រែ? <លោកប្រធាន ខ្ញុំក៏ចង់ដឹងផងដែរពីសហព្រះរាជអាជ្ញាជាតិ> យោងទៅតាមច្បាប់កម្ពុជា <តើវាមានភាពស្របច្បាប់ទេ ដែល>សហព្រះរាជអាជ្ញាអន្តរជាតិ<>ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកោះហៅសាក្សី ដោយមិនមានការព្រមព្រៀង<ពី>សហព្រះរាជអាជ្ញាជាតិយ៉ាងដូច្នេះ<?> យើងខ្ញុំយល់ថាសវនាការទៅលើមន្ទីរសន្តិសុខក្រាំងតាចាន់ គឺលេខាស្រុកឈ្មោះបឿន ត្រូវបានស្នើសុំដោយសហព្រះរាជអាជ្ញា<អន្តរ>ជាតិតែប៉ុណ្ណោះ។ ប៉ុន្តែយើងខ្ញុំយល់ឃើញថានេះជាស្ថានភាពមួយផ្សេងគ្នាដោយសារតែសាក្សីរូបនេះមិនដែលបានផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២ទេ ដោយមិនគិតអំពីវត្តមានដែលចូលមកក្នុងសវនាការសំណុំរឿង០០២/០១ ទេ។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាជាតិគឺថាបានស្នើសុំរួមគ្នាឱ្យកោះហៅសាក្សី 2-TCW-938។ ឥឡូវនេះគឺថាគាត់មិនចូលរួមស្នើសុំទេ។ ហើយយើងមិនបានលើកបញ្ហាពាក់ព័ន្ធទៅនឹងសាក្សីឈ្មោះ បឿន ទេ នៅពេលនោះ គឺថាមិនមែនមានន័យថាយើងទុកបញ្ហាច្បាប់ចោលនៅពេលនេះនោះទេ។ ដូច្នេះ សំណើសុំរបស់ខ្ញុំលោកប្រធាន គឺសុំឱ្យសហព្រះរាជអាជ្ញាជាតិពន្យល់មកដល់យើងខ្ញុំថាតើច្បាប់ចែងថាយ៉ាងដូចម្ដេចដែរ? ដូច្នេះ យើងអាចពិនិត្យទៅលើបញ្ហានេះ នៅពេលដែលយើងខ្ញុំដាក់សំណើជាលាយលក្ខណ៍អក្សរដើម្បីជាការឆ្លើយតបទៅនឹង

សំណើសុំមួយនេះ។ ចំណុចទី២ យើងស្នើសុំឲ្យមានការបញ្ជាក់នោះ គឺពាក់ព័ន្ធទៅនឹងសហព្រះរាជអាជ្ញាអន្តរជាតិ។ សំណួរសួរថាហេតុអីបានទើបតែដាក់សំណើសុំនៅពេលនេះ ហេតុអីក៏យឺតយ៉ាវម្ល៉េះ? ហេតុអ្វីក៏គាត់ស្នើសុំឲ្យកោះហៅសាក្សីទាំងនេះ នៅពេលដែលយើងកំពុងតែស្ថិតនៅពាក់កណ្ដាលផ្លូវនៃការសវនាការស្ដាប់ភស្តុតាងទៅលើអ្វីដែលកើតឡើងទៅលើជនជាតិចាមនៅក្នុងតំបន់៤១<? លោកសហព្រះរាជអាជ្ញាអន្តរជាតិ លោកបានដឹង>ភស្តុតាងនេះគឺថា វាមានរួចមកហើយនៅក្នុងខែធ្នូ ឆ្នាំ ២០១៤ ហើយយើងខ្ញុំពេញចិត្តណាស់ បើសិនណាជាមានការពន្យល់ណាមួយមកដល់យើងខ្ញុំ។ យើងខ្ញុំពិតជាយល់ឃើញថា វាគួរឲ្យមានចំណាប់អារម្មណ៍មែនទែនដោយសារតែយើងរង់ចាំយូរមកហើយ។ ក្រោយពីបានស្ដាប់ឮសួរ-- បើបានស្ដាប់ចម្លើយនេះហើយគឺថា យើងខ្ញុំយកចម្លើយនេះទៅដាក់ក្នុងសំណើសុំជាលាយលក្ខណ៍អក្សររបស់យើងខ្ញុំ។ ហើយនេះគឺថា អាចឲ្យយើងខ្ញុំចូលនិយាយទៅលើចំណុចសំខាន់បន្ថែមទៀតដូចខាងក្រោមនេះ។ ខ្ញុំសូមជម្រាបដោយស្មោះត្រង់ លោកប្រធាន យើងខ្ញុំមិនបានឃើញសំណើសុំពីសហព្រះរាជអាជ្ញាអន្តរជាតិនេះទេ។ គឺថា យើងទទួលបានដំណឹងនេះគឺថា ដោយគួរឲ្យភ្ញាក់ផ្អើល។ ជាទ្រឹស្ដីគឺថាយើងត្រូវតែដឹងអំពីអត្ថិភាពនៃភស្តុតាងនេះ ដែលថាសហព្រះរាជអាជ្ញាអន្តរជាតិ ហៅថាជាភស្តុតាងមួយដែលសំខាន់បំផុត។ ប៉ុន្តែការពិតគឺមិនយ៉ាងដូច្នេះទេ។ នៅក្នុងឯកសារ <ចំនួន><៨.១៥៥ទំព័រ> នេះគឺថា មានបុគ្គលប្រហែលជា ៥០០នាក់ ដែលផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង០០៤ ហើយចាប់តាំងពី១ បានបង្ហាញពីដើមដំបូងរហូតមកដល់សវនាការវគ្គទី២ ប្រឆាំងមកលើលោក នួន ជា។ ឯកសារនេះគឺ<ត្រូវបានកប់ចោល។ សូមទោស ឯកសារនេះមិនបានបង្ហាញខ្លួនទេ នៅពេលយើងស្រាវជ្រាវតាម> ភី.ឌី.អេហ្វ <>នោះ <ហើយជាការពិត>គឺថា សហ -- វាមានកម្មសិក្សាការី គឺថា បានប្រមូលភស្តុតាងអំពី ពីសាក្សី 2-TCW-938 <កន្លះម៉ោងមុនពេល>ដែលបានជូនដំណឹងនៅក្នុងឯកសារ E366។ ហេតុអ្វីក៏យ៉ាងដូច្នេះ? ជាការសាមញ្ញទេគឺថា យើងខ្ញុំមិនអាចអានឯកសារជាង ៨០០០ទំព័រនេះបានទេ <បញ្ហាតែមួយគត់ដែលយើងអាចធ្វើបាន ហើយយើងបានធ្វើជាយូរមកហើយនោះ គឺធ្វើតាមរយៈ>ការស្រាវជ្រាវទៅលើ<ពាក្យនៅក្នុង>ឯកសាររាប់ពាន់ទំព័រទាំងនេះ។ យើងជាខ្ញុំមិនមានធនធាន ឬពេលវេលាអាន<ដើម្បីអាន>ឯកសារ<ភស្តុតាង>ដែលបានដាក់បញ្ចូលមក ហាក់បីដូចជាទឹកជំនន់ដែលកំពុងហូរមកចូលនៅក្នុងសំណុំរឿង០០៤ នោះទេ។ <ដូចដែលលោកប្រធានបានដឹង>ហើយ យើង<កំពុងតែមានសវនាការមួយ ដែលមិន>មាន<ពេល>ឈប់សម្រាកទេនៅក្នុងផ្នែកវគ្គនេះ <ឧទាហរណ៍ មិនមានការឈប់សម្រាកបន្តិចណាសោះរវាង>សវនាការផ្នែកអំពីការដ្ឋាន

ការងារ ហើយនិងសវនាការវគ្គស្តីអំពីការប្រព្រឹត្តមកលើជនជាតិចាម។ បន្ថែមពីលើនេះទៅទៀត ហើយកាន់តែសំខាន់ទៅទៀតនេះ គឺថាយើងខ្ញុំបានរៀបចំពេញលេញសម្រាប់សវនាការទៅលើបណ្តឹងសាទុក្ខ។ ទើបតែនៅថ្ងៃសុក្រកន្លងទៅនោះ យើងខ្ញុំបានដាក់ឯកសារ បានដាក់សំណើសុំដ៏សំខាន់ ចាប់តាំងពីឆ្នាំ២០០៨ មកជាមួយនឹងតុលាការកំពូល។ ហើយយើងខ្ញុំក៏បានស្នើសុំឱ្យមានធនធានដើម្បីឱ្យយើងខ្ញុំអាចសរសេរនូវសំណើទាំងនេះបាន។ ខ្ញុំវាហាក់បីដូចជាថាអង្គជំនុំជម្រះសាលាដំបូងខ្លួនឯងផ្ទាល់មិនបានឃើញសំណើសុំពីសហព្រះរាជអាជ្ញាអន្តរជាតិនោះទេ។ បើមិនដូច្នេះទេយើងយល់ឃើញថាសាក្សី 2-TCW-938, 2-TCW-894 ត្រូវតែដាក់ចូលទៅក្នុងបញ្ជីសាក្សីពាក់ព័ន្ធទៅនឹងជនជាតិចាម។ លោកប្រធានដូចដែលយើងខ្ញុំស្នើសុំឱ្យមានការឈប់សម្រាកជាបន្ទាន់ <យើងមិនអាចធ្វើការងារនេះបានទៀតទេ។ ត្រូវ>ផ្តល់ធនធានមកឱ្យយើងខ្ញុំភ្លាមៗ ឬក៏យើងផ្អាកសវនាការស្តីអំពីការប្រព្រឹត្តមកលើជនជាតិចាមនៅត្រឹមនេះសិន ដើម្បីឱ្យយើងខ្ញុំអាចពិនិត្យមើលភស្តុតាងដែលបានមកពីសំណុំរឿង០០៤។ ហើយសំខាន់ជាងនេះទៅទៀត ដើម្បីបង្កលក្ខណៈឱ្យយើងខ្ញុំអាចពិភាក្សាជាមួយកូនក្តីរបស់យើងខ្ញុំ និងទទួលនូវចម្លើយអំពីគាត់ <ដែល>យើង<នៅតែមិនអាច>ធ្វើ<បាន>។ ហើយនេះគឺជាចំណុចចុងក្រោយរបស់យើងខ្ញុំលោកប្រធាន។ ហើយវាក៏ចំណុចមួយសំខាន់មួយផងដែរ នៅពេលដែលយើងកំពុងតែមានសវនាការស្តាប់អំពីភស្តុតាងគឺ ថ្ងៃនេះ ពីម្សិលមិញក៏ដូចជាសប្តាហ៍កន្លងទៅនូវអ្វីដែលកើតឡើងចំពោះជនជាតិចាម ជាពិសេសនៅក្នុង<ស្រុកមួយនៃ>តំបន់៤១។

អ្នកស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៤ ឥឡូវនេះដូចជាយើងខ្ញុំបាននិយាយហើយគឺថាបានសាកសួរសាក្សីសំខាន់ៗពាក់ព័ន្ធទៅនឹងជនសង្ស័យម្នាក់ក្នុងចំណោមជនសង្ស័យនៅក្នុងសំណុំរឿង០០៤ គឺ <អោ អាន>។ ពួកគាត់ឥឡូវកំពុងតែធ្វើការស៊ើបអង្កេតទៅលើបទចោទស្តីអំពីអំពើប្រល័យពូជសាសន៍ប្រឆាំងមកលើរូបគាត់ទាក់ទងទៅនឹងតំបន់៤១។ តាអាន នេះពាក់ព័ន្ធទៅនឹងសាក្សីពីរ គឺថាគេបាននិយាយសំដៅថាពាក់ព័ន្ធទៅនឹងសាក្សីពីរនាក់នេះ។

[០៩:២១:៣៤]

ដូច្នេះ អ្វីដែលបានកើតឡើងនៅវត្តអូរត្រកួន គឺជាផ្នែកមួយនៃការស៊ើបអង្កេតក្នុងសំណុំរឿង០០៤។ អនុញ្ញាតឱ្យខ្ញុំយោងទៅលើកថាខណ្ឌ២៣ ដល់ ២៥ នៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរនៅក្នុងសំណុំរឿង០០៤ ទាក់ទងទៅនឹង <អោ អាន>។ <ឯកសារទាំងនេះមិនមាននៅក្នុងសំណុំរឿងនោះទេ ប៉ុន្តែ> គឺថាអស់ លោក លោកស្រីទាំងអស់គ្នាអាចរកឃើញសំណើសុំនេះតាមអ៊ីនធើណេតបាន។ ដូច្នេះ មន្ត្រី

ស៊ើបអង្កេតនៅក្នុងសំណុំរឿង00៤ កំពុងតែស្វែងរកភស្តុតាងដើម្បីបង្ហាញឱ្យឃើញអំពីអត្ថិភាពនៃគោលនយោបាយប្រល័យពូជសាសន៍ ប្រឆាំងមកលើជនជាតិចាមនៅក្នុងតំបន់៤១។ ហើយនិងមានស្រុកដទៃទៀតដែរនៅក្នុង៤១ ក៏ដូចជាមន្ទីរសន្តិសុខដទៃៗទៀតក្នុងតំបន់៤១។ ហើយគេកំពុងតែស្វែងរកឱ្យឃើញនូវរចនាសម្ព័ន្ធនៅក្នុងតំបន់៤១ តាំងពីថ្នាក់លើទៅថ្នាក់<តំបន់ ទៅស្រុក និងឃុំ ហើយឡើងពី>ក្រោម<>ទៅថ្នាក់លើ ពីថ្នាក់ស្រុកទៅដល់ថ្នាក់មជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា។

ដូច្នេះ អាចមានលទ្ធភាពថា អាចមានភស្តុតាងដោះបន្ទុកផងដែរ ដែលយើងអាចរកឃើញបានទាំងថ្ងៃនេះក៏ដូចពីម្សិលមិញ ឬក៏ថាថ្ងៃស្អែកទៀតក៏ថាបាន។ ដូច្នេះវាជាលក្ខណៈមួយខុសគ្នាយ៉ាងខ្លាំងពាក់ព័ន្ធទៅនឹងការដ្ឋានត្រពាំងថ្មនៅភូមិភាគពាយ័ព្យ។ <លោក លោកស្រីចៅក្រមដឹងថា មានបញ្ហាផងដែរអំពីភស្តុតាងដែលចេញមកពីសំណុំរឿង00៤ ពាក់ព័ន្ធទៅនឹង>ការដ្ឋានលើកទំនប់នេះ<។ ភាពខុសគ្នាសំខាន់នោះគឺ> យើងខ្ញុំក៏មិនបានជំទាស់តវ៉ាចំពោះ<អត្ថិភាពនៃទំនប់នោះទេ ហើយយើងខ្ញុំក៏មិនបានជំទាស់ចំពោះ>សេចក្ដីសម្រេចចិត្ត ការសម្រេចចិត្តរបស់កូនក្ដីយើងខ្ញុំ <និងអ្នកផ្សេងៗទៀត> ដើម្បីឱ្យមានសវនាការស្ដាប់ទៅលើការដ្ឋានទំនប់១មករានោះទេ។

[០៩:២៣:៣០]

យើងខ្ញុំមិនបានបង្ហាញនូវឯកសាររបស់យើងខ្ញុំ នៅក្នុងសវនាការស្ដីអំពីដេញដោលទៅលើឯកសារនោះទេ។ <បើសិនជាយើងបានធ្វើនោះ វាប្រហែលជាច្បាស់ណាស់សម្រាប់លោក លោកស្រីចៅក្រម> គឺថាយើង<មិន>ជំទាស់តវ៉ាទៅលើគោលនយោបាយនៅក្នុងការលើកទំនប់ <និងការដ្ឋានការងារនោះទេ>។ <ប៉ុន្តែ>យើងជំទាស់តវ៉ា<យ៉ាងដាច់អហង្កា>អំពីអំពើប្រល័យពូជសាសន៍មកលើជនជាតិចាម។ ហេតុដូច្នេះ យើងខ្ញុំស្នើសុំឱ្យអង្គជំនុំជម្រះនេះផ្អាកសវនាការពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើជនជាតិចាមនៅវត្តអូរត្រកួន នៅឃុំពាមជីកងរហូតដល់ការស៊ើបអង្កេតប្រឆាំងទៅនឹង <អោ អាន> នេះគឺថាបានបង្ហាញ ក៏ដូចជាភស្តុតាងដទៃទៀតបានបញ្ចប់ការស៊ើបអង្កេតសិន។

ដូច្នេះយើងខ្ញុំ យើង -- ជាជម្រើសទៅវិញគឺថា យើងខ្ញុំស្នើសុំឱ្យមានការស្ដាប់សវនាការទៅលើការប្រព្រឹត្តជនជាតិចាមនៅ<អតីត>ភូមិភាគបូព៌ាវិញ <ដោយសារតែភូមិភាគនេះមិនមែនជាផ្នែកនៃការស៊ើបអង្កេតប្រឆាំងនឹង អោ អាន នោះទេ។> ដូច្នេះសូមជ្រាបយ៉ាងដូច្នេះលោកប្រធាន។ យើងឆាប់ៗនេះ យើងខ្ញុំក៏ស្នើសុំឱ្យស្ដាប់សក្ខីកម្មសាក្សីពីរនាក់បន្ថែមនេះទៅលើការប្រព្រឹត្តជនជាតិចាមនៅភូមិភាគបូព៌ាវិញ។ យើងខ្ញុំនឹងចែកជូននូវកូពីនៃសំណើសុំរបស់យើងខ្ញុំនេះ គឺថានៅថ្ងៃចន្ទ។ ចំណុចនេះគឺខ្ញុំមាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តែប៉ុណ្ណោះឯងពាក់ព័ន្ធទៅនឹងសំណើសុំពីសហព្រះរាជអាជ្ញាអន្តរជាតិ។សូមអគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។សូមអញ្ជើញមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រមទាំងអស់ និងភាគីទាំងអស់ ដូចដែលខ្ញុំបានលើកឡើងហើយតាមរយៈអ៊ីម៉ែល<>របស់ខ្ញុំកាលពីម្សិលមិញនោះ គឺថាហាក់ដូចជា យើងមិនចង់ឆ្លើយទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាទេ យើងនឹងឆ្លើយជាលាយលក្ខណ៍អក្សរ ក៏ប៉ុន្តែឥឡូវនេះខ្ញុំសូមធ្វើការកត់សម្គាល់មួយចំនួនដោយហេតុថាលោកមេធាវី កូប៉េ ទើបតែលើកនិយាយអម្បាញ់មិញហ្នឹង ដូចជាអស់លោក លោកស្រីចៅក្រមដឹងហើយ គឺថាវាមានទំនាក់ទំនងផ្ទាល់ជាមួយនឹងសំណើរបស់លោកជាលាយលក្ខណ៍អក្សរថ្មីៗនេះគឺថាទាក់ទងទៅនឹងកាតព្វកិច្ចនៃការបញ្ជូនឯកសាររបស់សហព្រះរាជអាជ្ញា គឺឯកសារ E363។ ក្នុងនីតិវិធីនេះ យើងឃើញហើយថា បញ្ហាសំខាន់បំផុតនោះ យើងត្រូវដឹងថាតើយើងបន្តជំនុំជម្រះសេចក្ដីយ៉ាងម៉េចទៀត បើសិនជាមួយថ្ងៃទៅមួយថ្ងៃនោះ គឺថាមានការបញ្ចូលភស្តុតាងថ្មីពីសំណុំរឿងផ្សេងទៀតរហូតដែលកំពុងតែស៊ើបអង្កេត។ ដូចលោក កូប៉េ បាននិយាយហើយ គឺថានៅក្នុងសំណើលាយលក្ខណ៍អក្សរហ្នឹង គឺថាមានឯកសារច្រើនណាស់ ហើយត្រូវយើងត្រូវវិភាគឯកសារភស្តុតាងទាំងអស់នេះ គឺថាយើងបញ្ហាគោលការណ៍ដែរ បញ្ហាសម្ភារៈខ្វះធនធាន។ តើនៅក្នុងៗសំណុំរឿងដែលចាប់ដំណើរការហើយត្រូវ -- យើងមានសិទ្ធិត្រូវបញ្ចូលឯកសារថ្មីពីសំណុំរឿងផ្សេងទៀតបានដែរឬទេ? នេះជាបញ្ហាសំខាន់ណាស់ ហើយបញ្ហានេះនឹងបន្តមានរហូត ហើយយើងមិនអាចរកដំណោះស្រាយអីបានទាល់តែសោះ។ <ដូច្នោះ>សំណើ<E363> នេះ <មានគោលបំណងស្វែងរកដំណោះស្រាយមួយ ដែលអាចចៀសវាងការ>យឺតយ៉ាវនៅក្នុងសំណុំរឿងនេះ ហើយក៏<>អាចឲ្យគោរពកិច្ចដំណើរការនីតិវិធី<នៃការស៊ើបអង្កេត>មួយបានល្អ<>។

[០៩:២៧:៣៨]

អ៊ីចឹងខ្ញុំសូមយោងទៅនឹងសំណើចុងក្រោយយើង ដែលយើងបានឆ្លើយទៅនឹងព្រះរាជអាជ្ញា ដែលយើងចង់ដឹងថា តើអ្វីដែលព្រះរាជអាជ្ញានិយាយមកកាន់យើងទាក់ទងនឹងអង្គហេតុនេះ ដោយបញ្ចូល ភស្តុតាងសំខាន់ៗ ដែលពួក -- ព្រះរាជអាជ្ញាគាត់គិតថាអ៊ីចឹង ក៏ប៉ុន្តែមិនបាន មិនត្រូវបានស៊ើបអង្កេតនៅក្នុងសំណុំរឿងយើងនេះទេ។ តើចង់និយាយថាស៊ើបអង្កេតនៅសំណុំរឿង ០០២/២ នេះធ្វើមិន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ល្អ ឬក៏យ៉ាងម៉េច? ព្រោះថា សំណុំរឿងយើងនេះកំពុងតែជំនុំជម្រះហើយ ហើយមិនទាន់ចប់ផងចេះតែយកសំណុំឯកសារសំណុំរឿងផ្សេងមករហូតនោះ។ អ៊ីចឹងខ្ញុំសូមឲ្យអង្គជំនុំជម្រះអានសំណើរបស់យើង ហើយនិងសុំឲ្យឆ្លើយលម្អិត ជាលម្អិតតបទៅនឹងសំណើរបស់ព្រះរាជអាជ្ញាផងដែរគឺឯកសារ E363។ យើងនឹងដាក់សំណើជាលាយលក្ខណ៍អក្សរនៅពេលក្រោយលោកប្រធាន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំចង់សួរទៅសហមេធាវីការពារក្តីទាំងពីរនាក់ទៅលើបញ្ហានេះ។ ខ្ញុំមិននិយាយអំពីបញ្ហាច្បាប់ទេ ប៉ុន្តែខ្ញុំនិយាយអំពីការអនុវត្តជាក់ស្តែងតែម្តង។ បញ្ហាទី២ ដែលមេធាវី កូប៉េ លើកឡើង គឺថា ដោយសារកង្វះពេលវេលា និង ធនធាន។ ជាការពិតហើយ គឺថាយើង<មិនអាចផ្តល់ធនធានបន្ថែមទៀតបានទេ។> -- តើលោកមានបានដាក់សំណើសុំទៅការិយាល័យរដ្ឋបាលសុំធនធានបន្ថែមដែរឬទេលោក កូប៉េ?

[០៩:២៩:២៧]

**លោក វ៉ិចទ័រ កូប៉េ៖**

យើងបានស្នើសុំជាច្រើនលើកហើយ ប៉ុន្តែចម្លើយបានឆ្លើយមកថា មិនមានថវិកាដើម្បីផ្តល់ធនធានបន្ថែមទេ។ យើងខ្ញុំគឺថា ចង់ស្នើសុំឲ្យមាន<បុគ្គលិក ឬ>កង់ស៊ុលតង់<>មកជួយនៅក្រុមយើងខ្ញុំ ប៉ុន្តែ<វាមិន>អាចធ្វើទៅបានទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

គឺលោកទើបតែស្នើសុំថ្មីៗ ឬក៏យ៉ាងម៉េចលោក?

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថា ខ្ញុំបានទៅការិយាល័យរបស់លោក អេន<ឌីលី> ជារៀងរាល់សប្តាហ៍ ប៉ុន្តែគាត់ឆ្លើយថា មិនមានលទ្ធភាពផ្តល់ឲ្យទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដូច្នេះពេលវេលារបស់<លោក> គឺសួរអំពីពេលវេលា។ លោកថាលោកត្រូវការពេលវេលាបន្ថែម ជាពិសេសចាប់ពីពេលនេះទៅតែម្តង ដើម្បីត្រៀមរៀបចំទៅលើការចូលរួមនៅក្នុងសវនាការលើបណ្តឹងសាទុក្ខ។ សូមលោកផ្តល់ពេលវេលាឲ្យច្បាស់ អាចនិយាយពីថ្ងៃ ពីអ៊ីចឹង ត្រូវការប៉ុន្មានថ្ងៃ?

[០៩:៣០:២៣]

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកស្រីចៅក្រម ហ្វេនស៍ គឺថាខ្ញុំបានធ្វើការ -- ខ្ញុំបានលើកឡើងពីបញ្ហានេះនៃការរៀបចំសម្រាប់បណ្តឹងសាទុក្ខរួចមកហើយ <ខ្ញុំលើករឿងនេះឡើង ពីព្រោះមានអ្វីមួយដែលយើងយើងកំពុងតែធ្វើក្នុងពេលដំណាលគ្នា។ ពិតណាស់> នៅពេលដែលយើងមានកាលវិភាគកំណត់អំពីសវនាការ <សំណួរសួរថា តើយើងអាចអាចស្ថិតនៅក្នុង>សវនាការស្តី<ស្តាប់>ភស្តុតាងនៅ -- ទៅលើប្រធានបទណា<បានទេ។ ប៉ុន្តែរហូតមកដល់ពេលនេះ យើងមិនបានឮអ្វីទាំងអស់។ ដូច្នេះខ្ញុំគិតថា សំណួររាប់លានដុល្លារនៅថ្ងៃនេះគឺ តើនៅពេលណាដែលយើងនឹងមាន>សវនាការលើបណ្តឹងសាទុក្ខហ្នឹង<? ប៉ុន្តែវាមិនបានផ្លាស់ប្តូរការពិតដែលថា យើងកំពុងតែរៀបចំលើមូលដ្ឋានប្រចាំថ្ងៃដើម្បីស្តាប់សវនាការលើ>បណ្តឹងសាទុក្ខ<រួចទៅហើយ>។ <យើងមានការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងសាទុក្ខរបស់យើង ដូច្នេះយើងដឹងនូវអ្វីដែលអាចជាបញ្ហានៃការពិភាក្សា។> ដូចដែលខ្ញុំបានជម្រាបលើកឡើងហើយគឺថា <យើងបានដាក់>សំណើសុំ<>ភស្តុតាងបន្ថែមជាហូរហែ ដូច្នេះយើងខ្ញុំកំពុងតែស្ថិតនៅក្នុងការរៀបចំមួយយ៉ាងពេញលេញតែម្តង។ ដូច្នេះយើងខ្ញុំមិនមានពេលវេលាដើម្បីស្តាប់ភស្តុតាងទៅលើសវនាការសំណុំរឿង <00២/0២>។ ជាពិសេសខ្ញុំនិយាយសំដៅទៅលើបណ្តឹងសាទុក្ខនេះតែម្តង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំដឹងបញ្ហាជារួមហើយ ប៉ុន្តែយើងត្រូវតែកំណត់ពេលវេលាកាលវិភាគ។ ជា<ក់>ស្តែងគឺថា <ដូចដែលយើងបានធ្វើពីមុនមកហើយ យើងបានកែតម្រូវកាលវិភាគជាបន្តបន្ទាប់។ ប៉ុន្តែ>មកទាល់ហ្នឹងថ្ងៃនេះៗ តើលោកត្រូវការពេលវេលាអ្វី ពេលវេលាប៉ុន្មាន? <ខ្ញុំយល់ថា វាអាចផ្លាស់ប្តូរបានក្នុងរយៈពេលបីសប្តាហ៍ ឬក៏អ្វីក៏ដោយ ក៏ប៉ុន្តែយើងត្រូវការការធ្វើសេចក្តីសម្រេចមួយ។ បើយើងចង់សម្រុះ>សម្រួល<លោកនោះ គឺវាមានប្រយោជន៍ក្នុងការយល់ពីលោកនូវអ្វីដែលលោកត្រូវការនៅពេលនេះ។>

**លោក វ៉ិចទ័រ កូប៉េ៖**

បញ្ហាគឺ<ភាគច្រើននៃ>ឯកសារជាង៨.000ទំព័រ<ខ្ញុំមិនអាចអានបានទេ>។ កុងស៊ុលតង់ដែលធ្វើការ -- ទីប្រឹក្សា ដែលធ្វើការនៅក្នុងក្រុមរបស់យើងខ្ញុំ<បានអានឯកសារនេះខ្លះ ប៉ុន្តែវាត្រូវតែឆ្លងកាត់ខ្ញុំ>។ <ខ្ញុំ>ត្រូវអានឯកសារជាង៨.000ទំព័រនេះ ខ្ញុំមិនដឹង<ថា ខ្ញុំអាចអានបាននៅពេលណានោះ>ទេ យើងខ្ញុំមិនដឹងថាត្រូវការពេលវេលាប៉ុន្មានទេ ប្រហែលជាអាចពីរបីសប្តាហ៍<? ខ្ញុំមិនដឹងទេ។> ដូច្នេះ

ឯងបានជា លោកស្រី -- អង្គជំនុំជម្រះឃើញហើយខ្ញុំតែម្នាក់ឯងទេ គឺថាជារៀងរាល់ថ្ងៃគឺថាមិនដែលអវត្តមានទេ។ ហើយខាងសហព្រះរាជអាជ្ញាហ្នឹង គាត់ថាគាត់មានគ្នាច្រើនមែនទែន ស្អេកស្កះមកជួយគាត់។ <ខ្ញុំមិនដឹងច្បាស់ថាតើខ្ញុំអានឯកសារនោះចប់នៅពេលណានោះទេ។ ពីរឬបីសប្តាហ៍ក៏មិនដឹង។>

[០៩:៣៣:១៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំចាប់អារម្មណ៍នឹងចំនួន៨.000ទំព័រនេះ វាមើលឃើញទៅដូចសម្បើមណាស់។ តើលោកមេធាវី កូប៉េ ខ្ញុំចង់ដឹងថាតើចាប់ពីចុងឆ្នាំមុនមក ប្រហែលជាខែ១១ ឬក៏មុនខែ១១ផង ដែលកំណត់ហេតុស្តាប់ចម្លើយសំណុំរឿង០៤នេះ បានផ្តល់ជូនទៅភាគីហើយ។ ហើយលោកក៏អត់មានបានអានមួយទំព័រណាទេឬ?

**លោក វ៉ិចទ័រ កូប៉េ៖**

ដោយសារតែយើងខ្ញុំត្រូវចូលរួមនៅក្នុងសវនាការជារៀងរាល់ថ្ងៃ យើងៗខ្ញុំរវល់មែនទែន <ជាមួយនឹងបណ្តឹងសាទុក្ខរហូតដល់ចុងឆ្នាំមុន ហើយបន្ទាប់មកយើងបានចាប់ផ្តើមសវនាការនេះ។ ហើយដូចខ្ញុំនិយាយអ៊ីចឹង វាជាស៊ូណាមិ ដែលត្រូវបានគេដោះលែងមក។ ខ្ញុំមានពេលតែ២៤ម៉ោងក្នុងមួយថ្ងៃ។ ប្រហែលជាលោកចៅក្រមមានច្រើនជាងនេះ ប៉ុន្តែខ្ញុំមិនមានទេ>។<>

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវីខ្ញុំសូមធ្វើការកត់សម្គាល់មួយចំពោះមុខតុលាការកំពូលនោះគឺថា លោកបានរៀបរាប់ហើយ លោកបានប្រើប្រាស់ឯកសារពីសំណុំរឿង00៤។ ហើយនៅពេលដែលលោកនិយាយថាលោកមិនបានអានទាល់តែសោះ ខ្ញុំវាភ្ញាក់ផ្អើលមែនទែន ព្រោះមុខតុលាការកំពូលលោកបានប្រើឯក-សារចេញពីសំណុំរឿង 00៤ នេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនបាននិយាយដូច្នេះទេចៅក្រម។ កាលពីពីរសប្តាហ៍មុននេះគឺថាយើងបានដាក់សំណើសុំរបស់យើងខ្ញុំ<តាមវិធាន៨៧> គឺថាយើងខ្ញុំស្នើសុំឲ្យដាក់របាយការណ៍របស់ -- ដាក់កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនប្រាំមួយពីសំណុំរឿង00៤ យើងបានអានកំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណុំរឿង

០០៤ ដែលពាក់ព័ន្ធទៅនឹងការដ្ឋាន<ទំនប់>នានា ក៏ប៉ុន្តែយើងមិនមានពេលវេលាអាចអានឯកសារជាង ៨.០០០ទំព័រទេ <បញ្ហាតែមួយគត់ដែលយើងអាចធ្វើបាននោះគឺ ស្រាវជ្រាវតាមរយៈពាក្យ ហើយសង្ឃឹមថាយើងអាចរកឃើញនូវអ្វីដែលយើងស្វែងរកនោះ។ ប៉ុន្តែ>យើងខ្ញុំ<មិនអាច>អង្គុយចុះឲ្យបានត្រឹមត្រូវ អានឲ្យបានហ្មត់ចត់ <នូវរាល់ទំព័រទាំងអស់ដែលមកពីមនុស្សជាង៥០០នាក់ក្នុងសំណុំរឿង ០០៤នោះបានទេ>។ ស្ថានភាព គឺយ៉ាងដូច្នេះឯងលោកចៅក្រម។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ មុននឹងព្រះរាជអាជ្ញានិយាយ ខ្ញុំសូមផ្តល់សំណើ -- អំណះអំណាងឲ្យចប់តែម្តង។ លោកប្រធានតាមសវនាការកន្លងមកជាច្រើននេះគឺថាយើងឃើញថាមានសំណុំរឿង ០៣, ០៤ មកឯកសារចូលមករហូតនេះ ខ្ញុំដូចជាមិនស្រួលចិត្តសោះ ព្រោះថាអ្វីដែលចេញពី -- អ្វីដែលជាកាតព្វកិច្ចរបស់ព្រះរាជអាជ្ញានោះ វាក្លាយជាកាតព្វកិច្ចរបស់ភាគីការពារក្តីវិញទាក់ទងសំណុំរឿង ០៣,០៤នេះ គឺថាយើងមិនអាចដាក់សំណើតាមផ្លូវរដ្ឋបាលឲ្យបានគ្រប់គ្រាន់ដើម្បីសុំជំនួយបន្ថែម ហើយដល់អ៊ីចឹងទៅឃើញទៅធ្វើបង្ហាញឲ្យឃើញថាខាងមេធាវីការពារក្តីមិនធ្វើការងាររបស់ខ្លួន។

[០៩:៣៦:៤០]

ខ្ញុំគិតថានៅពេលណាមួយត្រូវតែនិយាយឲ្យច្បាស់តែម្តង គឺថាមានបញ្ហានេះ វិធីយ៉ាងច្បាស់លាស់ដែលត្រូវដោះស្រាយជាមុនសិន។ ដូចយើងធ្វើសរសេរក្នុងសំណើរបស់យើងហើយយើងអាចនិយាយពីពេលវេលាបានទាល់តែយើងបែងចែកឯកសារឲ្យច្បាស់លាស់ថាតើឯកសារណាបញ្ជូនមកអង្គជំនុំជម្រះមកមេធាវីការពារក្តីឲ្យដឹងច្បាស់សិន។ ជំហានដំបូងត្រូវតែបែងចែកឯកសារឲ្យច្បាស់ ហើយយើងមិនអាចប្រាប់ថាតើយើងត្រូវការពេលវេលាប៉ុន្មាននោះទេ យើងមិនអាច -- យើងមិនអាចធ្វើការនៅក្នុងសំណុំរឿង០០២/២នេះ ដែលវាចេះតែមានឯកសារបញ្ចូលមករហូតនោះ គឺថាបើអ៊ីចឹងបើតាមព្រឹត្តិន័យនោះគឺថាយើងៗឃើញហើយថាឯកសារភស្តុតាងទាំងអស់នោះមកពីសំណុំរឿងដែលកំពុងតែស៊ើបអង្កេត។ អ៊ីចឹងសូមឲ្យស៊ើបអង្កេតឲ្យចប់សិនទៅ ឲ្យវាដឹងច្បាស់លាស់តែម្តង តើត្រូវការប៉ុន្មានអីប៉ុន្មាន? តើត្រូវដោះស្រាយបញ្ហានីតិវិធីនេះជាមុនសិន តើត្រូវថា -- តើមានឯកសារណាខ្លះដែលត្រូវបញ្ជូនមក? ឯកសារដោះបន្ទុក ដាក់បន្ទុកអីជាដើម ហើយសាក្សីណាខ្លះដែលគ្រោងដោយសហព្រះរាជ

អាជ្ញា និងភាគីផ្សេងៗ ហើយជាបន្ទាប់មកទៀត ជាករណីលើកលែងហ្នឹង ថាយើងត្រូវគោរពតាមវិធាន ៨៧(៤) ចំពោះភស្តុតាងថ្មីៗ។ អ៊ីចឹងយើងឥឡូវឃើញៗថាហាក់ដូចជាមានការច្របូកច្របល់មែនទែន ផ្នែកនីតិវិធី ហើយមេធាវីការពារក្តីទ្រាំលែងបានហើយ។

[០៩:៣៨:១៧]

ខ្ញុំដូចជាមានការអល់អែកមែនទែន មើលទៅឃើញថាយើងនៅចំពោះមុខនីតិវិធីមួយដែលថា ការងារដែលត្រូវធ្វើជាបឋមមិនត្រូវបានធ្វើទេ ហើយយើងនៅតែបន្តធ្វើការ ហើយឯកសារដាក់ ប<ញ្ជូ>លរហូត អ៊ីចឹងយើងធ្វើការត្រូវការស្រាវជ្រាវថាតើមានឯកសារណាទាក់ទងនឹងទីតាំងណា សាក្សីណា ហើយឯកសារភស្តុតាងណាខ្លះដែលត្រូវទទួលយក ហើយឯកសារណាខ្លះជាភស្តុតាងដាក់បន្ទុក ឬក៏ដោះបន្ទុក ហើយការងារនេះជាការងាររបស់ព្រះរាជអាជ្ញាទេដែលត្រូវបែងចែកឲ្យច្បាស់ថា ត្រូវធ្វើយ៉ាងណា។ អ៊ីចឹងយើងខ្ញុំគិតថាខ្ញុំថាយើងគួរតែរៀបចំនីតិវិធីឲ្យបានច្បាស់លាស់ រៀបចំកាលវិភាគសវនាការ រៀបចំផ្នែកយើងនេះ វគ្គយើងនេះ ធ្វើយ៉ាងម៉េចឲ្យបានច្បាស់លាស់សិន។ សំណើ<>ខ្ញុំច្បាស់លាស់ហើយក្នុងសំណេររបស់ខ្ញុំ។ អ៊ីចឹងយើងកំពុងតែកាត់សេចក្តីបណ្តើរ ជំនុំជម្រះបណ្តើរ ហើយចេះតែទទួលពីឯកសារចេញពីសំណុំរឿងកំពុងតែស៊ើបអង្កេតបណ្តើរ អ៊ីចឹងត្រូវកំណត់ព្រំដែនឲ្យច្បាស់លាស់។ ខ្ញុំមិនអាចទទួលយកបានទេ យ៉ាងហោចណាស់យើងមានអារម្មណ៍ថាមេធាវីខៀវ សំផន មានអារម្មណ៍ថារាល់ដងត្រូវតែធ្វើដូចសុំទានគេអ៊ីចឹង ថាសុំថា អូ៎! សុំត្រូវការនេះត្រូវការនោះ ពន្យល់មូលហេតុថាយើងធ្វើនេះធ្វើនោះមិនបាន។ អ៊ីចឹងពីព្រោះថាពិបាកណាស់ យើងមិនដឹងថា បើថារាំក្បាច់អីទេរាល់ថ្ងៃនេះនោះ។ អ៊ីចឹងបើរឿងប្រាប់ពេលវេលាឲ្យច្បាស់លាស់ត្រូវការប៉ុន្មានអីប៉ុន្មាននោះ ត្រូវឲ្យខាងអង្គជំនុំជម្រះចេញសេចក្តីឲ្យច្បាស់លាស់ចេញសេចក្តីសម្រេចមួយអំពីនីតិវិធីឲ្យច្បាស់លាស់ អំពីចំនួនតើភស្តុតាងណាខ្លះទទួលយក។ នៅពេលដែលមានព័ត៌មានអស់ហ្នឹងហើយ យើងនឹងអាចដឹងថាយើងនឹងត្រូវផ្តល់ពេលវេលាថាត្រូវការពេលប៉ុន្មានអីប៉ុន្មានជាដើម។ អ៊ីចឹងត្រូវខាងព្រះរាជអាជ្ញានោះឲ្យច្បាស់ពីការងាររបស់ខ្លួនផងដែរ លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោក លោកស្រីចៅក្រម មានសំណួរអ្វីសួរភាគី មេធាវីការពារក្តីឲ្យច្បាស់លាស់ដើម្បីបញ្ចប់នូវបញ្ហាភាគីម្ខាងហ្នឹង ឲ្យជ្រះស្រឡះមុននឹងផ្តល់វេទិកាឲ្យភាគីម្ខាងទៀតឆ្លើយតបដែរឬទេ?

បាទ បើអត់មានទេ ផ្តល់វេទិកាទៅសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីឆ្លើយតប សហមេធាវីនាំ

មុខតំណាងរដ្ឋប្បវេណីក្រោយ ព្រោះគាំទ្រសហព្រះរាជអាជ្ញាទេ។

[០៩:៤១:១៨]

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន លោក លោកស្រី ចៅក្រម។ អនុញ្ញាតឱ្យខ្ញុំបាទឆ្លើយតបនូវអ្វីដែលយើងបានស្ដាប់នៅក្នុងព្រឹកនេះ។ ខ្ញុំស្ដាប់មើលទៅគឺថា វាជាចម្លើយតបទៅនឹងសំណើសុំរបស់យើងខ្ញុំហើយ។ នេះជាចំណុចទី១។ យើងមិនគួរណាមកបង្អាក់ការស្ដាប់សក្ខីកម្មសាក្សីលើសពី៤០នាទីហើយបានត្រៀមពេលវេលាដើម្បីដាក់សំណើសុំក្នុងរយៈពេលដល់ទៅ១០ថ្ងៃដូច្នេះទេ។ ការលើកឡើងរបស់មេធាវីការពារក្ដីវាជាការត្រឹមត្រូវ ខ្ញុំមិនជំទាស់ទេ។ ទី២ មេធាវីការពារក្ដីបានលើកបញ្ហានេះ ដើម្បីឱ្យអង្គជំនុំជម្រះពិចារណា។ មេធាវីការពារក្ដីសម្បូរពេលវេលាណាស់គឺថាផ្ញើអ៊ីម៉ែលចែកជូនទៅឱ្យគេមើលគ្រប់គ្នា <នូវការកត់សម្គាល់បឋមមួយនៃអ្វីដែលគាត់នឹងស្នើសុំទៅអង្គជំនុំជម្រះ។> នេះជាចំណុចមួយដែលធ្វើម្ដងហើយម្ដងទៀតៗ ដោយមេធាវីការពារក្ដី ដោយមិនមានការជូនដំណឹងមកដល់ភាគីអំពីសំណើសុំនេះទេ។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលនេះ ភ្លាមៗនៅក្នុងថ្ងៃនេះគឺការសួរមកកាន់សហព្រះរាជអាជ្ញា<>ជាតិ<ដែលមិន>មានវត្តមាននៅទីនេះ។ បើសិនណាជាគាត់ចង់សួរ<>សហព្រះរាជអាជ្ញាជាតិវិញគឺថាគាត់មានកាតព្វកិច្ចអ្វីដែលត្រូវពន្យល់អំពីបញ្ហាច្បាប់មកលោកនោះទេ។ <ផ្ទុយទៅវិញប្រសិនបើមេធាវីមានបំណងឱ្យគាត់មានវត្តមាននៅទីនេះ មេធាវីគួរតែជម្រាបជូនគ្រប់ភាគីពាក់ព័ន្ធជាមុននូវអ្វីដែលគាត់សួរនៅថ្ងៃនេះជាពុំខាន។>

[០៩:៤៣:០២]

ទី២ យើងខ្ញុំបានឮការអះអាងថា យើងបានដាក់សំណើសុំឱ្យកោះហៅសាក្សីបន្ថែមនេះ គឺថាយឺតយ៉ាវហើយ ហើយថាជាកំហុសរបស់យើងខ្ញុំ<នោះមិនត្រឹមត្រូវទេ>។ មេធាវីការពារក្ដីខ្លួនគាត់ហ្នឹងគឺថា បានកត់សម្គាល់ ឃើញហើយយើងបានដាក់សំណើសុំឱ្យកោះហៅសាក្សីពីរនាក់បន្ថែមទៀតនៅក្នុងសំណើ<ខែឧសភា> ឆ្នាំ២០១៤ ហើយសាក្សីទី៣ គឺជាសាក្សីមួយថ្មីទេដែលយើងទើបនឹងរកឃើញ។ អង្គជំនុំជម្រះគួរធ្វើការកត់សម្គាល់ផងថា បញ្ជីសាក្សីនៅក្នុង<ខែឧសភា> ឆ្នាំ២០១៤នេះស្ថានភាពនៃភស្តុតាងគឺថាយើងអាចមានពីសំណុំរឿង០០៤នោះគឺវាមិនដូចនៅពេលនេះទេ។ នៅពេលនោះ គឺថាមានកម្មាភិបាលថ្នាក់ទាបៗទេ ដែលមកបង្ហាញអំពីគោលនយោបាយដើម្បី<រក និង>កម្ទេចជនជាតិចាម។ អាស្រ័យទៅលើបញ្ហានេះ បានយើងខ្ញុំដាក់បញ្ចូលនូវសាក្សីបន្ថែមទៀត។ ហើយចាប់--

ដោយសារតែការស៊ើបអង្កេតកំពុងតែបន្ត មេឃុំ មេស្រុក ឬក៏ថាលេខាថ្នាក់ឃុំ ឬក៏ថ្នាក់ស្រុក គឺថាបាន ផ្តល់មកបង្ហាញ<សក្ខីកម្ម>អំពីគោលនយោបាយ<អំពីអត្ថិភាពនៃបញ្ហា>ពីលើមកក្រោម ដើម្បី<កំណត់ អត្តសញ្ញាណ និង>សម្លាប់ជនជាតិចាម<ទាំងអស់>។ មេធាវីគួរតែដឹងអំពីភស្តុតាងទាំងនេះ ខ្ញុំមិនជឿ ថាគាត់មិនដឹងទេ។ គាត់បាននិយាយថា អូ៎! យើងកប់ទុកនូវបញ្ហានេះ ធ្វើដូចស៊ូណាមិ រលក យក្សអើមក ដល់គឺថាព្រឹបៗតែម្តង មិនអាចដោះស្រាយបាន។ <កិច្ចសម្ភាសន៍លើរូបលេខាស្រុកចំនួនបួនលើកបាន ធ្វើនៅក្នុងឆ្នាំ២០១៣ ហើយម្តងទៀតនៅ>ឆ្នាំ២០១៤ម្តង។ <អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺចៅក្រម ស៊ើបទើបតែដាក់បង្ហាញក្នុងខែធ្នូ>ឆ្នាំ២០១៤ <រាល់កិច្ចសម្ភាសន៍ទាំងប្រាំនោះ ពិតណាស់ ដោយសារ តែភាពរសើបនៃព័ត៌មានដែលផ្តល់ឲ្យដោយបុគ្គលនេះ។ នៅពេលដែលកិច្ចសម្ភាសន៍ទាំងអស់នោះត្រូវ បានផ្សាយនៅខែធ្នូ ឆ្នាំ២០១៤> ហើយក៏យើងធ្វើសំណើសុំជាបន្ទាន់មួយ ដើម្បីស្នើសុំការអនុញ្ញាតឲ្យ បង្ហាញភស្តុតាង ហើយ<នៅពេលយើងបានទទួលការអនុញ្ញាត>ភស្តុតាង <គឺយើងបាន>បង្ហាញ< ភស្តុតាងទាំងអស់នោះ>នៅខែកុម្ភៈ ឆ្នាំ<២០១៥> ជាចំណុចសំខាន់មួយ។ យើងខ្ញុំបានដាក់សំណើសុំ ឲ្យបង្ហាញភស្តុតាងនេះដាច់ៗដោយឡែកពីគ្នានូវកិច្ចសម្ភាសន៍ចំនួនប្រាំលើកទៅលើលេខាស្រុក។ <អ្នក ទាំងអស់គ្នាដឹងហើយថា បុគ្គលនេះជានរណា ហើយនិងសារៈសំខាន់របស់គាត់>។ <ការ>ឡើងឈរ នៅទីនេះហើយថា ពួកគាត់មិនបានដឹងអំពី<សារៈសំខាន់នៃសាក្សីរូប>នេះហើយថា យើងនេះព្យាយាម លាក់បាំងនូវបញ្ហាទាំងអស់នេះ <គឺជាការដែលធ្វើឲ្យរន្ធត់ណាស់>។

[០៩:៤៦:០០]

លោកចៅក្រម ឡាវែន៍ បានចង្អុលបង្ហាញហើយថា នៅពេលដែលមេធាវីការពារក្តីឡើងឈរថា អត់មានពេលវេលាដើម្បីពិនិត្យមើលទៅលើឯកសារទាំងអស់នេះ ពួកគាត់ហាក់បីដូចជារៀបចំខ្លួនរួច ហើយដើម្បីចូលរួមនៅក្នុងសវនាការលើបណ្តឹងសាទុក្ខ។ ពួកគាត់ក៏បានប្រើប្រាស់ភស្តុតាងចេញអំពី សំណុំរឿង០០៤ផងដែរ។ <ពួកគេក៏បានប្រើប្រាស់ឯកសារទាំងនោះនៅក្នុងវគ្គ>ការដ្ឋានទំនប់ត្រពាំងថ្ម <ផងដែរ ដោយពួកគេបានប្រើប្រាស់ឯកសារទាំងអស់នោះយ៉ាងច្រើនបំផុតជាមួយសាក្សីនៅក្នុងសវ-នាការ ដោយមិនបានដាក់ឯកសារតាមវិធាន៨៧(៤)នោះទេ ហើយការធ្វើដូច្នោះ ខាងយើងមិនបាន ជំទាស់ទេ> រួមទាំងមេធាវីការពារក្តី ខៀវ សំផន ខ្លួនឯងផងដែរ។ ទើបតែប៉ុន្មានសប្តាហ៍មុននេះគាត់ នៅក្នុងសវនាការគឺសួរទៅលើសាក្សី<នៅក្នុងវគ្គ>ការដ្ឋានទំនប់ត្រពាំងថ្ម <ដោយប្រើប្រាស់កិច្ចសម្ភាសន៍ មួយ ក្នុងចំណោមកិច្ចសម្ភាសន៍ទាំងអស់នេះ>។ ហើយឥឡូវនេះស្រាប់តែហាក់បីដូចជាលើកនូវគោល

ការណ៍ជាមូលដ្ឋានណាមួយមក ដើម្បីបង្កឧបសគ្គទៅដល់តុលាការនេះតែម្តង។

ខ្ញុំមិនគិតថា -- ខ្ញុំសូមលើកនូវចំណុចមួយទៀតពាក់ព័ន្ធទៅនឹងអង្គជំនុំជម្រះសាលាដំបូង ខ្ញុំគិតថាសាក្សីនេះមិនត្រូវបានច្រានចោលទេ គឺថាសាក្សីនេះត្រូវបានដាក់ចូលនៅក្នុងការជ្រើសរើសសាក្សីជាបឋម។ ប្រហែលជាអង្គជំនុំជម្រះសាលាដំបូង<បានចាត់ទុកពួកគេជា>សាក្សី<គោលនយោបាយច្រើនជាង។ ខ្ញុំមិនច្បាស់ទេ។ ប៉ុន្តែពិតជាអត់មានការចេញសេចក្តីសម្រេចបដិសេធមសាក្សីទាំងអស់នេះទេ ហើយខ្ញុំក៏មិនគិតថា ពួកគេអាចនឹងត្រូវបានបដិសេធចោលនោះដែរ>។ ខ្ញុំយល់ឃើញថាមិនមានសំណួរអីដែលសួរបញ្ហាភស្តុតាងនេះបានទេ។ បញ្ហាសំខាន់គ្រាន់តែសួរថា ហេតុអ្វីបានជាប្រជាជនចាមត្រូវបានគេប្រមូលផ្តុំ ហើយយកទៅសម្លាប់ចោល<នៅក្នុងតំបន់នេះ>យ៉ាងដូច្នេះ។

ភស្តុតាងទាំងអស់នេះគឺថា វានឹងជួយបញ្ជាក់ទៅដល់ការសិក្សាស្រាវជ្រាវ<ជាច្រើនឆ្នាំ>ពាក់ព័ន្ធទៅនឹង<ថាតើមាន>គោលនយោបាយ<ដែរឬទេ? នៅពេលនេះ>យើងមានលេខាស្រុក មេស្រុកហ្នឹងដែលបានមកផ្តល់សក្ខីកម្មថា មានគោលនយោបាយច្បាស់ណាស់ ដើម្បីកំណត់អត្តសញ្ញាណចាម និងសម្លាប់ចាមនៅក្នុងតំបន់ដែលពួកគាត់រស់នៅ។

[0៩:៤៨:១៣]

យើងខ្ញុំសូមចូលទៅដល់អំពីកិច្ចដំណើរការនីតិវិធីដែលជាចំណុចសំខាន់។ ការជំទាស់តវ៉ាមួយនោះគឺថា ដោយសារការស៊ើបអង្កេតកំពុងតែបន្ត ដូច្នេះយើងត្រូវតែផ្អាកសវនាការវគ្គនេះសិន។ នេះសំណើសុំពីមេធាវីការពារក្តី។ មេធាវីការពារក្តីលើកឡើងវាត្រឹមត្រូវហើយ វាដោយសារថានេះជាចំណុចសំខាន់នៃសំណុំរឿងនេះ។ ប៉ុន្តែវាមិនខុសគ្នាទៅលើផ្នែកដទៃទៀតនៃកិច្ចដំណើរការនីតិវិធីទេ គឺថា<ការស៊ើបអង្កេតនឹងនៅតែបន្ត ហើយយើងនឹងបន្តបង្ហាញឯកសារថ្មីៗ ហើយមាននីតិវិធីមួយ> តើ<គួរតែ>មានភស្តុតាងថ្មី<>ណាសំខាន់<> ដែល<ទាំងមេធាវីការពារក្តី ទាំងសហព្រះរាជអាជ្ញាចង់ឲ្យ>អង្គជំនុំជម្រះសាលាដំបូងត្រូវស្តាប់ភស្តុតាងទាំងអស់នោះ<ទេ>។ <ដូច្នេះ មិនមានហេតុផលអីត្រូវ>ផ្អាកសវនាការវគ្គនេះ <ដោយសារតែមាន>ការស៊ើបអង្កេត<កំពុងបន្តនោះទេ>។

<ហើយយើងយល់ស្របជាមួយនឹង>មេធាវីការពារក្តី <ដែលកំពុង>ដាក់សំណើសុំប្រកបទៅដោយហេតុផល<ថា> តុលាការ<គួរតែ>អនុញ្ញាតឲ្យមានពេលវេលាដើម្បីឲ្យពួកគាត់អានបាន<។> ប៉ុន្តែការស្នើសុំឲ្យផ្អាកសវនាការនេះគឺមិនត្រឹមត្រូវទេ។ លើសពីនេះទៅទៀតគឺថាយើងមានសាក្សីតែម្នាក់ទៀតទេតើទាក់ទងទៅនឹងការសម្លាប់នៅស្រុកកងមាស។ មេធាវីការពារក្តីថាឲ្យផ្អាកសិនទៅ

ហើយទៅស្តាប់សវនាការពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើជនជាតិចាមនៅភូមិភាគបូព៌ា<ស្រុក ក្រូចឆ្មារ>វិញ។ <យើងមានតែសាក្សីមួយនេះទេនៅថ្ងៃនេះ។>

ខ្ញុំយល់ឃើញថាការសុំឲ្យផ្អាកសវនាការស្តីអំពីស្រុកកងមាសនេះគឺថាមិនត្រឹមត្រូវទេ ដោយសារតែយើងនៅសល់តែសាក្សីតែម្នាក់ទៀតទេតើ។ ហើយគាត់អាចនឹងមករៀបរាប់ប្រាប់យើងបានថា នូវអ្វីដែលកើតឡើងចំពោះជនជាតិចាម។ បើសិនណាជាផ្អាកសវនាការវគ្គនេះ ខ្ញុំយល់ឃើញថាសាក្សីរូបនេះប្រហែលជាអង្គជំនុំជម្រះអាចនឹងត្រូវកោះហៅរហូតទៅដល់ខែតុលា<>ឯណោះ។ ដូច្នេះ យើងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាពិចារណាមើលថាតើគួរអនុញ្ញាតឲ្យមេធាវីការពារក្តីមានពេលវេលាប៉ុន្មាន ដើម្បីអាននូវឯកសារទាំងអស់នេះ។ នេះគឺជាចម្លើយតបរបស់ខ្ញុំ ទៅនឹងការលើកឡើងរបស់មេធាវី កូប៉េ។

[០៩:៥០:៣៦]

ទាក់ទងទៅនឹងក្រុមមេធាវីការពារក្តី ខៀវ សំផន វិញម្តង។ យើងបានដឹងទាំងអស់គ្នាហើយថាពួកគាត់ -- ហេតុម៉េចបានពួកគាត់ផ្លាស់ប្តូរគោលជំហរលឿនយ៉ាងនេះ<? នៅពេលដែលគេបានប្រើប្រាស់កិច្ចសម្ភាសន៍នៅក្នុងសំណុំរឿង004 នៅក្នុងសវនាការ ពួកគេមិនបានប្រឆាំងនឹងសំណើរបស់យើងដើម្បីឯកសារទាំងអស់នេះជាភស្តុតាងទេ។ ហើយបន្ទាប់មកទៀត> កាលពីប៉ុន្មានសប្តាហ៍មុននេះគឺថាវា<បានក្លាយ>ជាគោលការណ៍ គឺថាយើងមិនត្រូវស្តាប់សក្ខីកម្មរបស់សាក្សីទាំងអស់នេះបន្តទៅទៀតទេ។ នេះគាត់លើកឡើងយ៉ាងដូច្នេះ។ យើងខ្ញុំសុំ ស្នើសុំថា កាលប៉ុន្មានសប្តាហ៍មុននេះ គឺថាពួកគាត់ដឹងអំពីកិច្ចសម្ភាសន៍សំខាន់ៗជាមួយនឹងសាក្សីទាំងអស់នេះ <នៅពេលដែលពួកគាត់កំពុងរៀបចំករណីសម្រាប់ជនជាតិចាម ហើយនេះជាភស្តុតាងមួយដែលមានសារៈសំខាន់ ដែលវាបំផ្លាញដល់ការការពារក្តី>។ សូមទុកបញ្ហានេះមួយអន្លើសិនចុះ។

តុលាការនេះគឺថាត្រូវស្វែងរកការពិត ហើយភាគីទាំងពីរគឺមេធាវីការពារក្តី និង សហព្រះរាជអាជ្ញា <មានសិទ្ធិស្នើសុំ>ភស្តុតាង<ថ្មីស្របតាមវិធាន>។ អ៊ីចឹងហើយបានជាយើងបង្ហាញភស្តុតាងនូវកិច្ចសម្ភាសន៍ថ្មីៗនេះ។ មេធាវីការពារក្តីគាត់មានសិទ្ធិជំទាស់បាន មិនជាអ្វីទេ ប៉ុន្តែ<ពួកគេមិនបានជំទាស់ទេ នៅពេលយើងបានដាក់ភស្តុតាងនោះ។> ខ្ញុំសូមជម្រាបទៅអង្គជំនុំជម្រះថា ភស្តុតាងនេះជាភស្តុតាងមួយដែលមានសារៈសំខាន់បំផុត គឺថាវាជាចំណុចស្នូលហើយសម្រាប់សវនាការនេះ។ បើសិនណាជាភាគីដទៃ អង្គជំនុំជម្រះមានសំណួរអីមកកាន់យើងខ្ញុំ យើងខ្ញុំគឺថាត្រៀមខ្លួនរួចជាស្រេចកំពុងតែ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឈរដើម្បីត្រៀមខ្លួនឆ្លើយទៅនឹងសំណួរណាមួយមកកាន់យើងខ្ញុំ។

**ប្រធានអង្គជំនុំ៖**

អរគុណ។សូមអញ្ជើញសហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់ ខ្ញុំមានការកត់សម្គាល់មួយចំនួនជាការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ យើងមិនធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងសំណើនេះទេ។ ខ្ញុំសូមបញ្ជាក់ឡើងវិញ ដូចដែលខ្ញុំបាននិយាយដដែលៗនៅពេលដែលយើងពិភាក្សាគ្នាអំពីបញ្ហាហ្នឹង។ យើងនិយាយអំពីគោលជំហររបស់យើងដែលវាពិសេសខុសគេនៅក្នុងសំណុំរឿងនេះ ពីព្រោះថាយើងគាំទ្របណ្ដឹងអាជ្ញាដែលដាក់ដោយសហព្រះរាជអាជ្ញា ក៏ប៉ុន្តែយើង គឺយើងធ្វើការដោយឯករាជ្យ ហើយសហមេធាវីនាំមុខមិនបានចូលមើលក្នុងសំណុំរឿង០០៣, ០០៤ ទេ។ យើងស្ថិតនៅក្នុងស្ថានភាពដូចគ្នាទៅនឹងមេធាវីការពារក្ដីដែរ ពាក់ព័ន្ធទៅនឹងការចូលមើលឯកសារទាំងអស់នេះ។ ទោះបីជាយើងមាន -- មិនមានតួនាទីដូចគ្នានៅក្នុងសំណុំរឿងនេះក៏ដោយ។ ខ្ញុំសូមនិយាយដោយត្រង់ និងដើម្បីឲ្យអង្គជំនុំជម្រះយល់អំពីការលំបាករបស់ភាគី ខ្ញុំបង្ខំចិត្តត្រូវតែនិយាយថា យើងមិនទាន់បានមើលសំណើ<នោះទេ> ហើយយើង<មិនដឹងដោយពេញលេញចំពោះឯកសារពាក់ព័ន្ធនឹង>សាក្សី 2-TCW-938<នេះទេ>។ ខ្ញុំនិយាយបែបនេះ ដើម្បីឲ្យអង្គជំនុំជម្រះយល់អំពីបន្ទុកការងារដែលភាគីទាំងអស់កំពុងតែប្រឈមមុខ។ ភាគីទាំងអស់មានតួនាទីរៀងៗខ្លួន ហើយមានមុខងាររៀងៗខ្លួននៅក្នុងសាលសវនាការនេះ ហើយនិងនៅក្រៅសាលសវនាការនេះ។ ហើយចំពោះសហមេធាវីនាំមុខបន្ទុកការងាររបស់យើងនៅខាងក្រៅសាលសវនាការនេះ ក៏មានសារៈសំខាន់ផងដែរ។ ដូច្នេះ យើងអាចយល់ថាមេធាវីការពារក្ដី អាចស្នើសុំពេលវេលាមួយចំនួនដើម្បីពិនិត្យមើលឯកសារទាំងអស់នេះ។ ខាងយើងក៏យើងមានការលំបាកផងដែរក្នុងការអានពិនិត្យមើល និងស្វែងយល់អំពីឯកសារដែលបានបង្ហាញជូនដោយសហព្រះរាជអាជ្ញា។

[០៩:៥៤:៤៧]

យើងតែងតែនិយាយតាំងពីចាប់ផ្ដើមសវនាការមកថា វាជាប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលយើងធ្វើយ៉ាងម៉េចអាចឲ្យសវនាការយើងបន្តទៅមុខបាន ដោយគោរពនូវសិទ្ធិរបស់ភាគីទាំងអស់។ យើងមិនដែលជំទាស់ទៅនឹងសំណើរបស់ភាគីណាមួយនោះទេ ពាក់ព័ន្ធនឹងការកោះហៅសាក្សី

រូបណានោះ យើងតែងតែគោរពទៅតាម -- ទៅនឹងអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ ហើយចំពោះសំណើជាក់លាក់មួយរបស់សហព្រះរាជអាជ្ញានេះក៏យើងគោរពដូចគ្នា។ វាតែងតែមានបញ្ហាដដែលៗ ហើយយើងទទួលរងនូវផលវិបាកនៅក្នុងសំណុំរឿងយើងនេះ។ យើងត្រូវការពេលវេលាមួយដើម្បីទទួលបាននូវសាលដីការបស់តុលាការកំពូលនៅក្នុងសំណុំរឿង០០២/០១ មុនពេលសវនាការយើងនេះចប់ ពីព្រោះថាវាមានផលប៉ះពាល់ដោយផ្ទាល់រវាងសេចក្ដីសម្រេចរបស់តុលាការកំពូល និងការជំនុំជម្រះក្ដីបច្ចុប្បន្នយើងនេះ។ យើងត្រូវសួរអំពីបញ្ហាថាតើពេលណាទើបចប់សំណុំ -- ស៊ើបអង្កេតចប់សំណុំរឿង ០០៣, ០០៤ មុនពេលចប់សវនាការក្នុងសំណុំរឿង០០២/០២ យើងនេះ។

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំសូមឆ្លើយតបទៅនឹងចំណុចមួយរបស់មេធាវី កូប៉េ ពាក់ព័ន្ធទៅនឹង តាអាន ពីព្រោះថាខាងដើមបណ្ដឹងរដ្ឋប្បវេណីយើងចាប់អារម្មណ៍ក្នុងការស្វែងរកការពិត។ យើងដឹងតាមរយៈ <វេបសាយ>របស់តុលាការថា តាអាន ត្រូវបានចោទប្រកាន់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយនិងឧក្រិដ្ឋកម្មពាក់ព័ន្ធទៅនឹង<ការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា និងបទឧក្រិដ្ឋនៅវត្ត>អូរត្រកួន ដែលនិយាយជាទៀងទាត់តាំងពីសវនាការទៅលើជនជាតិចាម។ ដូច្នេះអង្គជំនុំជម្រះត្រូវតែសួរសំណួរថាតើតាអាន នេះត្រូវតែកោះហៅមកឲ្យពន្យល់ ឬក៏ផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២ ឬក៏អត់។ មិនមានឧបសគ្គខាងនីតិវិធីអ្វីដែលហាមឃាត់មិនឲ្យអង្គជំនុំជម្រះស្ដាប់ចម្លើយតាអាន នោះទេ។ គាត់មើលទៅហាក់ដូចជាសហការជាមួយតុលាការណាស់ ពីព្រោះថាគាត់មិនត្រូវបានដាក់ឲ្យពិនិត្យដោយអាថ៌កំបាំងមុខទេៗ។ តាមរយៈសារព័ត៌មាន តាមរយៈវេបសាយរបស់តុលាការនោះគឺថាគាត់ដូចជាសហការជាមួយតុលាការ។ អ៊ីចឹងមិនមានឧបសគ្គអីទេ តុលាការយើងនេះអាចកោះហៅតាអាន មកស្ដាប់ចម្លើយរបស់គាត់បាន ដោយសារតែគាត់អាចមានព័ត៌មានសំខាន់ជាច្រើន ហើយវាអាចពាក់ព័ន្ធក្នុងការស្វែងរកការពិតទៅលើផ្នែកណាមួយនៃសវនាការរបស់យើង។ យើងមិនធ្វើសំណើឲ្យកោះហៅតាអានទេ ក៏ប៉ុន្តែយើងគ្រាន់តែ ជម្រាបអង្គជំនុំជម្រះអំពីលទ្ធភាពនៃការកោះហៅនេះ។ នេះជាការកត់សម្គាល់របស់ខ្ញុំ។

លោកប្រធានលោក លោក លោកស្រីចៅក្រម សូមអរគុណដែលបានស្ដាប់នៃការលើកឡើងរបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៥៨:១៣]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំពេញចិត្តណាស់ ក្នុងការទទួលបានការគាំទ្រពីសហមេធាវីនាំមុខ។ ខ្ញុំក៏មានការរីករាយដែលដឹងថាទោះបីជាគាត់មានទំនាក់ទំនងជាមួយសហព្រះរាជអាជ្ញាក៏ដោយ ក៏គាត់គាំទ្រនូវជំហររបស់យើង។ លោក លីសាក់ បានបញ្ជាក់ថា គាត់បាននិយាយតាមលក្ខណៈចំអកថា អ្វីដែលយើងធ្វើហ្នឹងគឺវាមិនត្រឹមត្រូវទេ។ <តាមពិតទៅគឺវាមិនដូច្នោះទេ។ ហើយខ្ញុំរីករាយណាស់ដែលសហមេធាវីនាំមុខគាំទ្រយើងនៅក្នុងរឿងនេះ នៅពេលនេះ។ ពួកគេមិនមានយោបល់អីអំពីភាពសំខាន់របស់សាក្សីនេះទេ។> ដូច្នេះចំពោះខ្ញុំៗគិតថា អង្គជំនុំជម្រះតុលាការ -- ខ្ញុំគិតថាតុលាការយើងនេះក៏ភ្ញាក់ផ្អើលដែរ ពាក់ព័ន្ធនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញានេះ។ ចំណុចមួយទៀត សហព្រះរាជអាជ្ញានិយាយល្អណាស់ ក៏ប៉ុន្តែខ្ញុំចង់ដឹងថាតើសហព្រះរាជអាជ្ញាជាតិហ្នឹងគាត់គិតយ៉ាងម៉េចនៅពេលដែលខ្ញុំស្នើសុំការបញ្ជាក់នោះ។ <គាត់អាចឆ្លើយតបបាន ខ្ញុំគិតថាអ៊ីចឹង តាងនាមឲ្យការិយាល័យសហព្រះរាជអាជ្ញានោះ។ ប្រសិនបើ>លោកជំទាវ ជា លាង <>មិនមានវត្តមាននៅទី<នោះទេ នោះយើងមិនមានបញ្ហាអីនោះទេ>។ ខ្ញុំគិតថាខាងសហព្រះរាជអាជ្ញាជាតិនេះ ខាងផ្នែកភាគីជាតិនេះ គួរតែផ្តល់គោលជំហររបស់ខ្លួនផង ចង់ដឹងថាខ្លួនហ្នឹងយល់ឃើញយ៉ាងម៉េច ហើយផ្តល់មូលហេតុមើលហេតុអីបានជាភាគីជាតិនេះ ព្រះរាជអាជ្ញាជាតិមិនចុះហត្ថលេខាលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិនោះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវីកូប៉េ ខ្ញុំចង់យល់ឲ្យបានច្បាស់អំពីសំណើរបស់លោកដែលសុំឲ្យព្រះរាជអាជ្ញាជាតិបំភ្លឺនោះ លោកចង់ជំទាស់ទៅនឹងសំណើដែលមានហត្ថលេខាតែមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិឬក៏យ៉ាងម៉េច? ខ្ញុំមិនសូវយល់ពីសំណើរបស់លោកពាក់ព័ន្ធទៅនឹងនីតិវិធីយើងនេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

នៅក្នុងសំណើសុំជាលាយលក្ខណ៍អក្សររបស់ខ្ញុំទាក់ទងទៅនឹងចម្លើយតបទាក់ទងទៅនឹងសំណើសុំនេះ គឺថាហេតុអ្វីបានជាសហព្រះរាជអាជ្ញាទាំងពីររូបនេះគឺថាមិនចុះហត្ថលេខាទាំងពីរៗនាក់ទៅ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពីព្រោះថានៅក្នុងតុលាការនេះយើងមានសហព្រះរាជអាជ្ញាពីរ អ៊ីចឹងបានខ្ញុំចោទជាសំណួរបែបនេះ។ ហើយយោងទៅតាមច្បាប់ជាតិនោះ គឺថាក៏មិនអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំការកោះហៅសាក្សីតែម្នាក់ឯងយ៉ាងដូច្នេះបានដែរ។ ដូចដែលខ្ញុំពេលខ្ញុំដើរចេញពីបន្ទប់សវនាការយ៉ាងដូច្នេះដែរ បើសិនណាជាមេធាវីជាតិមានវត្តមាននៅទីនេះ វានោះវាមិនបញ្ហាអ្វីនោះទេ។ ហើយពីមុនៗគឺថាយើងតែងមានសំណើសុំចុះហត្ថលេខាទាំងពីរនាក់តែម្តង។ ខ្ញុំមិនដឹងថាគួរតែសហព្រះរាជអាជ្ញាជាតិនោះទេ ខ្ញុំមិនដឹងថាច្បាប់ជាតិមានចែងយ៉ាងច្បាស់ពីចំណុចនេះ ឬក៏អត់នោះទេ។

[១០:០១:៥៨]

**ប្រធានអង្គជំនុំ៖**

យើងអត់យល់ដែរ ឥឡូវហ្នឹងដូចជាប៉ុស្តិ៍វ៉ាដូហើយ យើងដូចឲ្យផ្តល់តួនាទីហ្នឹង ម្នាក់ៗនិយាយឲ្យច្បាស់លាស់ហើយ ឥឡូវព្រះរាជអាជ្ញាដើបទៀត ព្រះរាជអាជ្ញារងដើបផង ហើយព្រះរាជអាជ្ញាធំអន្តរជាតិដើបទៀត។ យើងបាននិយាយច្បាស់លាស់ហើយអំមិញឲ្យភាគីម្ខាងធ្វើការអត្ថាធិប្បាយឲ្យបានច្បាស់លាស់ ហើយភាគីម្ខាងទៀត សូម្បីតែចៅក្រមហ្នឹង ក៏យើងឲ្យនិយាយឲ្យបានច្បាស់លាស់ដែរ យើងមិនចង់ត្រឡប់ត្រឡិនម្តងហើយ ទៅវិញទៅមកអ៊ីចឹងទេ! ព្រះរាជអាជ្ញារងជាតិមានបញ្ហាអីឆ្លើយ អាចឆ្លើយតប ឬក៏រក្សាសិទ្ធិមិនឆ្លើយតបលើបញ្ហានេះទេ?

**លោក សេង លាង៖**

សូមគោរពលោកប្រធាន! ខ្ញុំយល់ថាអ្វីដែលលោកកូប៉េលើកឡើងនេះ គឺព្រឹកនេះគឺជាការឆ្លើយតបទៅនឹងសារណារបស់ការិយាល័យសហព្រះរាជអាជ្ញា។ ហើយដូច្នេះខ្ញុំមិនមានកាតព្វកិច្ចអ្វីត្រូវឆ្លើយជំនួសសហព្រះរាជអាជ្ញាជាតិនោះទេ បើលោកកូប៉េមានបញ្ហា អាចសរសេរចូលទៅក្នុងសារណារបស់គាត់ទៅដើម្បីឲ្យយើងមានលទ្ធភាពក្នុងការឆ្លើយតបឲ្យបានជាក់លាក់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗនូវរាល់មតិយោបល់លើកឡើងជុំវិញបញ្ហានានាពាក់ព័ន្ធនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលបានដាក់សំណើសុំស្តាប់សក្ខីកម្មសាក្សីបន្ថែម ហើយនិងដាក់ឲ្យសុំឲ្យអង្គជំនុំជម្រះទទួលយកឯកសារថ្មីបន្ថែមដែលមានបញ្ហានាពេលនេះ ហើយរាល់មតិយោបល់នេះ អង្គជំនុំជម្រះនឹងយកទៅពិនិត្យពិចារណាគួបផ្សំនឹងសំណើសុំដែលភាគីសហមេធាវីការពារក្តីទាំងពីរក្រុមបានលើកឡើងថាខ្លួននឹងដាក់បន្ថែមនូវសេចក្តីជំទាស់ជាលាយលក្ខណ៍អក្សរនាពេលនេះ ហើយនិងនៅសប្តាហ៍

ក្រោយឆាប់ៗនេះដើម្បីអង្គជំនុំជម្រះយកមកពិនិត្យពិចារណាគួបគ្នានឹងសម្រេចចុងក្រោយលើបញ្ហានេះ តែទោះបីយ៉ាងណាក៏ដោយ បញ្ហាលើកឡើងនៅពេលនេះគឺមានចំនួនច្រើន អ៊ីចឹងបញ្ហាខ្លះគឺអង្គជំនុំជម្រះត្រូវពិនិត្យពិចារណាត្រូវដោះស្រាយចំពោះមុខភ្លាមៗ ហើយរឿងខ្លះត្រូវតែដោះស្រាយជាបន្តបន្ទាប់រហូតដល់បានសម្រេចលើទាំងស្រុងលើសំណើ និងសេចក្តីជំទាស់របស់ភាគីពាក់ព័ន្ធនឹងបញ្ហានេះ។ ឥឡូវនេះដល់ពេលសមស្របនឹងសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ និងម្ភៃនាទី អញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:០៤ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងកោះហៅដើមបណ្តឹងរដ្ឋប្បវេណីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ អង្គជំនុំជម្រះក្រោយពីបានស្តាប់នូវសេចក្តីជំទាស់ និងសំណើសុំរបស់មេធាវីការពារក្តី វ៉ិចទ័រ កូប៉េ និងសំណើសុំចុងក្រោយលេខ E366 របស់សហព្រះរាជអាជ្ញាអន្តរជាតិ អង្គជំនុំជម្រះសម្រេចថា នៅថ្ងៃយើងបន្តធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-252 ដោយមូលហេតុថា ឥឡូវនេះគាត់មានវត្តមាននៅទីនេះហើយ ហើយបញ្ហាដែលសំណើសុំរបស់លោក វ៉ិចទ័រ កូប៉េ ថាគាត់មានការពាក់ព័ន្ធទៅនឹងកិច្ចដំណើរការស៊ើបអង្កេតនៅក្នុងសំណុំរឿង០៣, ០៤ ពាក់ព័ន្ធជាមួយនឹងការប្រព្រឹត្តទៅលើជនជាតិចាមនៅតំបន់៤១នៅក្នុង សំណុំរឿង ០៣, ០៤ នោះកំពុងដំណើរការ។ អង្គជំនុំជម្រះគិតយល់ឃើញថា ប្រសិនបើពេលណាដែលកាលៈទេសៈណាមួយដែលចាំបាច់នៅពេលក្រោយ បន្ទាប់ពីស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទៅ ហើយបើមេធាវីយល់ថាចាំបាច់ត្រូវតែស្តាប់សក្ខីកម្មសាក្សីគាត់សាជាថ្មីម្តងទៀត គឺអាចដាក់សំណើសុំដើម្បីអង្គជំនុំជម្រះធ្វើការកោះហៅគាត់សាជាថ្មីមកស្តាប់សក្ខីកម្មសាជាថ្មីម្តងទៀត។ នេះគឺកុំឱ្យវាមានការកកវាំងស្ទះនូវដំណើរការសវនាការ ទី១។ ទី២ ចំពោះកាលវិភាគសវនាការសម្រាប់សប្តាហ៍

បន្តបន្ទាប់ទៅមុខទៀត ដោយសារឥទ្ធិពលនៃសំណើសុំនេះ អង្គជំនុំជម្រះនឹងពិភាក្សាហើយនិងសម្រេចលើបញ្ហានេះ និងជូនដំណឹងទៅភាគីឆាប់ៗនៅក្នុងចុងសប្ដាហ៍នេះ ឬក៏យ៉ាងយូរបំផុត គឺដើមសប្ដាហ៍ក្រោយ។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-252 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១០:៣៨:២៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

**លោក ហ៊ឹម ម៉ាន៖**

**ឆ៖** ខ្ញុំបាទ ឈ្មោះ ហ៊ឹម ម៉ាន។

**ស៖** អរគុណ។ លោក ហ៊ឹម ម៉ាន តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំដែរទេ?
កុំអាលទាន់ៗ ចាំក្បាលមីក្រូហ្វូន ប្រតិបត្តិការដោយឲ្យសញ្ញាភ្លើងក្រហមសិនណា។

**ឆ៖** ខ្ញុំបាទកើតឆ្នាំ១៩៥៩។

**ស៖** បាទ អរគុណលោកម៉ាន។ តើលោកមានទីកន្លែងកំណើតនៅទីកន្លែងណា?
កុំអាលទាន់ៗ។

**ឆ៖** ខ្ញុំកើតនៅភូមិសាច់ស្វ ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម។

**ស៖** បាទ អរគុណ។ ចុះទីលំនៅបច្ចុប្បន្នរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទនៅភូមិសាច់ស្វ។

**ស៖** ភូមិសាច់ស្វ ហ្នឹងស្ថិតនៅក្នុងឃុំអី ស្រុកអី សព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំបាទនៅភូមិសាច់ស្វ។

**ស៖** ភូមិអីគេ?

**ឆ៖** ភូមិសាច់ស្វ។

**ស៖** ភូមិសាច់ស្វហ្នឹងស្ថិតនៅឃុំអី ស្រុកអីសព្វថ្ងៃនេះ?

**ផ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** កុំអាលទាន់ៗ។

**ផ៖** ភូមិសាច់សូ ស្រុកកងមាស។

**ស៖** ឃុំ?

**ផ៖** ភូមិសាច់សូ ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកគាត់ឈ្មោះអី?

[១០:៤០:៥១]

**ផ៖** ឪពុកបង្កើតរបស់ខ្ញុំគឺឈ្មោះ ហ៊ុមៗ,ម៉ាន – ខ្ញុំឈ្មោះ ម៉ាន។

**ស៖** ចុះម្តាយរបស់លោក?

**ផ៖** អែល មឹះ។

**ស៖** អរគុណលោក ហ៊ុម ម៉ាន។ តើប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ផ៖** ខ្ញុំបាទមានកូនប្រាំនាក់។

**ស៖** ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី?

**ផ៖** ឈ្មោះ ខទីចះ– ហ៊ុម ខទីចះ។

**ប្រធានអង្គជំនុំ៖**

លោក ហ៊ឹម ម៉ាន ជាចុងក្រោយបង្អស់នៃការផ្តល់សក្ខីកម្មរបស់លោកក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណី លោកមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា ស្ថានភាពព្យសនកម្ម គឺផលអន្តរាយដែលបានកើតឡើងចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។

ដោយអនុវត្តតាមបទបញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន មុនភាគីដទៃទៀតនៃរឿងក្តី។ សហមេធាវីនាំមុខរួមទាំងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន នេះគឺលោក ឡោ ជុនធី ជាមេធាវីផ្ទាល់របស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះជាអ្នកសួរសំណួរ ហើយ និងបន្តដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ ជាដំបូងខ្ញុំបាទសូមគោរពអង្គជំនុំជម្រះ សូមគោរពភាគី ហើយខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយមេធាវីមកពីអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា។

[១០:៤៣:៤៥]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** នៅពេលនេះ ខ្ញុំបាទសូមជម្រាបសួរទៅលោកដើមបណ្ដឹងរដ្ឋប្បវេណី លោក ហ៊ឹម ម៉ាន នូវសំណួរមួយចំនួនដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាមពីក្នុងអំឡុងឆ្នាំ១៩៧៥ ទៅដល់ឆ្នាំ១៩៧៩។ ចាតើនៅមុនឆ្នាំ១៩៧៥ លោកពូ ហ៊ឹម ម៉ាន នៅឯណាដែរ?

**លោក ហ៊ឹម ម៉ាន៖**

**ឆ៖** ខ្ញុំបាទនៅភូមិសាច់សូហ្នឹងហើយ។

**ស៖** បាទ ចាតើនៅក្នុងភូមិសាច់សូនោះ តើមានជាជនជាតិចាមទាំងអស់ ឬមួយយ៉ាងណា?

**ឆ៖** បាទ ខ្ញុំបាទដឹងដែលខ្ញុំនៅភូមិសាច់សូហ្នឹង ជនជាតិចាមនៅទាំងអស់។ អត់មានបងប្អូនខ្មែរទៅនៅលាយឡំទេ។

**ស៖** បាទ អរគុណ។ ចាតើនៅពេលនោះ ក្នុងភូមិរបស់លោកមានហៅថា ព្រះវិហារសម្រាប់គោរពបូជាតាមសាសនារបស់លោកដែរឬទេ?

**ឆ៖** មានគ្រប់បែបយ៉ាងទាំងអស់ ដោយសារខាងសាសនាមហាម៉ាត់ហ្នឹង មានគ្រប់។

**ស៖** បាទ អរគុណ។ ចាតើនៅពេលនោះ អ្នកភូមិរួមទាំងលោកដែរ មានការគោរពសាសនានិងទំនៀមទម្លាប់ហ្នឹងយ៉ាងដូចម្ដេចដែរ?

**ឆ៖** បានគោរពខាងសាសនាមហាម៉ាត់ហ្នឹង តាមទំនៀមទម្លាប់ហ្នឹង គឺមានសេរីភាពណាស់។

**ស៖** បាទ អរគុណ។ បានសេចក្តីថា មានការគោរពជាធម្មតា មិនមាននរណាមកហាមឃាត់ទេ ឬមួយយ៉ាងណា?

**ឆ៖** គ្មានពីណាមកហាមឃាត់ទេកាលនុំងនោះ ប៉ុន្តែក្រោយមកហ្នឹង ឮដំណឹងប្លែកៗអីចេះៗអីចុះទៅ នៅរង់ចាំ។ ប៉ុណ្ណឹង។

[១០:៤៧:៥៧]

**ស៖** បាទ អរគុណ។ ចាតើនៅក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោកពូរស់នៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំរស់នៅ នៅភូមិសាច់ស្លូហ្នឹងដដែល។

**ស៖** នៅពេលនោះ បងប្អូនអ្នកភូមិដែលជាជនជាតិចាមហ្នឹងរួមរស់នៅទីនោះពេញភូមិដដែល ឬមួយអត់ទេ?

**ឆ៖** រស់នៅពេញភូមិដដែល រួចថាក្រោយមកបានគេជម្លៀសទៅអីណាអីណីនោះ គេដឹងតែគេជម្លៀសទៅពាក់កណ្តាលក្នុងភូមិសាច់ស្លូហ្នឹងណា៎ បំបែក។

**ស៖** បាទ អរគុណ។ តើលោកពូអាចដឹងទេថាតើកាលនោះ ប្រជាជនចាមនៅក្នុងភូមិហ្នឹងអាចមានប៉ុន្មានគ្រួសារដែរ សូមលោកអាចប្រមាណបានទេ?

**ឆ៖** ខ្ញុំគ្រាន់តែស្មានទេ ពីព្រោះថានៅពេលនោះប្រហែលជា អីការវាយស្មាន មិនដឹងខុស ដឹងត្រូវទេប៉ុន្តែប្រហែលជា ២០០, ៣០០ ហ្នឹង ពីព្រោះខ្ញុំអត់មានក្តោបក្តាប់មានតែតាកឹម តាអីហ្នឹង កាលហ្នឹង។ ប៉ុន្តែខ្ញុំគ្រាន់តែវាយស្មានប៉ុណ្ណឹងទេ។

**ស៖** បាទ អរគុណ។ ចាតើនៅពេលនោះ លោកពូបានលើកឡើងអម្បាញ់មិញថា មានការជម្លៀសប្រជាជនចាមហ្នឹងចេញទៅ។ ចាតើលោកពូអាចជម្រាបបានទេ នៅជូនអង្គជំនុំជម្រះនៅពេលនេះថាតើគេជម្លៀសទៅហ្នឹង ទៅខាងណា?

**ឆ៖** គ្រាន់តែដឹងថា ជម្លៀស ដឹងថាបាត់មនុស្សដែលខ្ញុំធ្លាប់រស់នៅក្នុងភូមិនោះបាត់មនុស្សទៅពាក់កណ្តាលហើយ មិនដឹងទៅទីណាទេ ប៉ុន្តែបាត់មនុស្សពីភូមិ ឮចាមខ្លះថាទៅលើ ទៅនៅភូមិផ្សេងៗ បាទ ប៉ុណ្ណឹង។

**ស៖** ចាតើទៅភូមិផ្សេងៗហ្នឹងតាមមធ្យោបាយអីដែរ លោកពូអាចដឹងទេ?

**ឆ៖** អត់មានអីនេះទេ ប៉ុន្តែទៅដើរធម្មតា ដើរតែម្តង ដើរ។ អត់មានរទេះសេះ អត់មានឡានអី

ទេ កាលហ្នឹងនុ៎ះ។

**ស៖** តើលោកពូអាចដឹងទេថានៅពេលដែលគេជម្លៀសបងប្អូនជនជាតិចាមហ្នឹងចេញទៅហ្នឹង តើក្នុងឆ្នាំៗប៉ុន្មាន ឬមួយអាចជម្រាបពីពេលវេលាហ្នឹងបានទេ?

**ឆ៖** ខ្ញុំប្រហែលជាឆ្នាំហ្នឹងឆ្នាំ១៩៧៥ បាទប្រហែលឆ្នាំហ្នឹង ខ្ញុំប្រហែលដែរ ព្រោះខ្ញុំបានវាយរ៉ាប់ពីមុនមក ប៉ុន្តែខ្ញុំវា៤០ឆ្នាំហើយ វាភ្លេចភ្លាំងអស់ហើយ កាលពីធ្មេញនៅ ឥឡូវធ្មេញចង់បាក់អស់ហើយ។

[១០:៥៣:៣៨]

**ស៖** បាទ អរគុណ។ អ៊ីចេះ អ្វីដែលថាឆ្នាំយើងអាចកត់សម្គាល់ឆ្នាំបាន ប៉ុន្តែ តើលោកពូអាចកត់សម្គាល់បានទេថានៅពេលដែលបែកភ្លាមថ្ងៃ ១៧ មេសា បានន័យថាខែ៤ថាតើបានប៉ុន្មានខែដែលគេបានជម្លៀសចេញហ្នឹង ឬមួយអាចកត់សម្គាល់ថា ក្នុងរដូវណារដូវប្រាំង រដូវវស្សា រដូវភ្លៀង?

**ឆ៖** ជម្លៀសទៅហ្នឹងរដូវ ខែ រដូវប្រាំង បាទ រដូវប្រាំង។ មិនដឹងខែណាទេ ប៉ុន្តែរដូវប្រាំងព្រោះគ្មានភ្លៀង គ្មានផ្គរទេ វាក្តៅ។

**ស៖** តើលោកពូបានដូចជាអ្នកភូមិសាច់សូ អ៊ីចឹង អ្នកដែលគេជម្លៀសចេញទៅហ្នឹងស្គាល់ទេ មានស្គាល់ពួកគាត់ខ្លះទេជាបងប្អូនសាច់ញាតិ ឬមួយជាអ្នកជិតខាងអី ស្គាល់ទេ?

**ឆ៖** បាទ ខ្ញុំបាទស្គាល់។ ស្គាល់ខ្លះដូចជា តាសង្គ្រាជ សុះៗក៏ជម្លៀសទៅពេលហ្នឹងដែរ។ បើក្រៅពីហ្នឹងទៀតមនុស្សវាច្រើនដែរហ្នឹងហើយថាដឹងប្រាកដថាពូជ សង្គ្រាជ សុះ ក៏ទៅទាំងអស់។

**ស៖** បាទ អរគុណ។ ចុះវិលមកវិញថាតើការជម្លៀសចេញហ្នឹង ជម្លៀសខ្លះ ចុះអ្នកដែលនៅក្នុងភូមិ អ្នកដែលបន្សល់ទុកនៅក្នុងភូមិហ្នឹងប៉ុន្មានដែរ?

**ឆ៖** ខ្ញុំបើនៅក្នុងភូមិហ្នឹង ខ្ញុំដឹងវាយស្មានថាមនុស្សហ្នឹងវាប៉ានស្មានទេនៅប្រហែលជា ៣០ គ្រួសារ បាទ។ វាទៅហ្នឹង ភាគច្រើនដែរ។

**ស៖** អរគុណ។ តើ ៣០ គ្រួសារហ្នឹង ក្នុងនោះមានក្រុមគ្រួសារលោកពូដែរអត់ទេ?

**ឆ៖** បាទ មាន ក្រុមគ្រួសាររបស់ខ្ញុំនៅ។

[១០:៥៧:០៩]

**ស៖** បាទ អរគុណ។ ថាតើអ្នកដែលនៅទាំងអម្បាលម៉ាននៅក្នុងភូមិហ្នឹង ហើយក្រោយមកខាងណាគេមានហៅទៅប្រជុំប្រើអំពីបញ្ហាអ្វីផ្សេងៗទេ?

**ឆ៖** នៅសេលសល់ហ្នឹង កាលហ្នឹងគេហៅទៅប្រជុំ។ គេប្រជុំប្រាប់ថា ពួកជនជាតិនេះ ឲ្យកាត់សក់ កុំឲ្យទទូរក្រមា ហើយឲ្យហូបសាច់ជ្រូក ហើយកុំឲ្យសំពះឃុំង។ គ្រប់បែបយ៉ាងទាំងអស់ដែលសាសនាមូស្លីមកាន់ គាត់ឃុំឃាំងទាំងអស់។ បើសិនជាមិនស្ដាប់ទេ បងប្អូនកងប្រវត្តិសាស្ត្រវិលទៅហើយ លូកដៃដាច់ដៃ លូកជើងដាច់ជើង។ បាទ គាត់ប្រជុំធ្វើអ៊ីចឹង។

**សៈ** បាទ អរគុណ។ ថាតើនៅពេលប្រជុំនោះ នរណាជាអ្នកបានកោះហៅទៅប្រជុំហ្នឹង លោកពូនៅចាំទេ?

**ឆ៖** ខ្ញុំនៅចាំខ្លះៗ ពីព្រោះថាកាលនុ៎ងប្រធានភូមិឈ្មោះ តាដាំ – ប្រធានតាំ ពួកជនជាតិដែរអ៊ីស្លាមដែរហ្នឹង។ ពួកខាងកាន់សាសនាមហាម៉ាត់ដែរ។ បាទ គាត់បង្កើតនូវតាតាំ មួយ។ អ៊ីចឹង តាតាំប្រាប់ បាទ រឿងអីៗទាំងអស់ហ្នឹង ប៉ុន្តែ តាតាំ វាក្រោមបញ្ជាគេដែរ រួចក្រោយមកហ្នឹងតាតាំ ហ្នឹងក៏គាត់ងាប់ដោយសារយកទៅសម្លាប់ចោលអស់ទៅ។តាតាំ ហ្នឹងប្រធាន។ បាទប៉ុណ្ណឹង។

**សៈ** បាទ អរគុណ។ អម្បាញ់មិញលោកពូបានរំឮកថាមានមេភូមិឈ្មោះតាតាំ បាទ ហើយបានលើកឡើងថាគាត់ទទួលបញ្ជាពីខាងលើ។ តើពេលនោះគាត់បានប្រជុំជម្រាបថាដូចម្ដេចថាពាក់ព័ន្ធនឹងការទទួលបញ្ជានេះ លោកពូអាចនៅចាំទេ?

**ឆ៖** ខ្ញុំកាលហ្នឹង គឺកម្លាំងពលកម្មជីកដី ជីកអីទេ ប៉ុន្តែគេនៅប្រជុំ ខ្ញុំនៅៗតាមហ្នឹងរត់លេង រត់អីទៅ ព្រោះខ្ញុំខាងពលកម្មខាងជីកដី ជីកអីនោះ ប៉ុន្តែឮថា ប៉ុន្តែជំនាន់ខ្មែរក្រហមហ្នឹង កាលណាប្រធានលើកហើយហ្នឹង គឺខ្ញុំវាយស្មានថាគេបញ្ជាហើយបាទ ប៉ុណ្ណឹង។ រួចមិនដឹងជាលោកណាបញ្ជាៗខ្ញុំមិនដឹងទេ ប៉ុន្តែអ្វីដែលគាត់ប្រកាសហ្នឹង គឺមានគេបញ្ជាបានជាគាត់ប្រកាស អាហ្នឹង ខ្ញុំវាយស្មានទេ។

**សៈ** បាទ ថាតើក្រោយពីការប្រជុំនេះមក មានរឿងអ្វីដែលកើតឡើងបន្តទៀតទេ ចំពោះបងប្អូនជនជាតិចាមហ្នឹង?

**ឆ៖** មាន។ បាត់ម្ដងម្នាក់ ម្ដងគ្រួសារៗ បាទបាត់ម្ដងម្នាក់ៗអ៊ីចឹងទៅណា ម្ដងមួយគ្រួសារៗយកទៅបាត់ទៅហ្នួង អត់នេះទេ បាត់បន្តៗគ្នាអ៊ីចឹង។

[១១:0២:៤៧]

**សៈ** អរគុណលោកពូ។ ថាតើមូលហេតុនៃការបាត់នេះ លោកពូដឹងទេ?

**ឆ៖** ខ្ញុំបាទដឹង ព្រោះពេលបាត់ហ្នឹងក្រុមខ្មែរក្រហមពេលហូបបាយហ្នឹង វាមកភ្ជង់យកតែម្ដងពេលនៅហូបបាយហ្នឹង ហូបបបរហ្នឹង នៅជុំវិញអ៊ីចឹង វាមកពីក្រោយធ្វើមិនដឹងទៅ វាភ្ជង់យកទៅ ចង់

បានពីរនាក់ ចង់បានបីនាក់ ស្រេចតាមតែចិត្តវា ព្រោះអាចីកំបាំងអស់ហ្នឹង វាមិនប្រាប់វាយើងទេ ដល់ពេលវាយកហ្នឹង វាមកយកស្រឡាញ់អ្នកណាទៅមុន អ្នកណាទៅក្រោយ គឺស្រេចតែវា បាទ វាយកទៅពេលហូបបាយហើយ យកទៅ។ ពេលក្រោយទៀត ហូបបាយទៀត វាមកយកទៀត អ៊ីចឹងហូបបាយៗរាល់ថ្ងៃនេះភ័យ ហូបបាយនេះបងប្អូនងាប់ ចាស់ៗពីដើមហូបបាយរស់ បើជំនាន់ខ្មែរក្រហមហូបបាយហ្នឹងងាប់ ពេលហូបបាយហ្នឹងហើយ វាមកភ្ជង់យក បាទ ខ្ញុំដឹងប៉ុណ្ណឹង។ រួចមិនដឹងយកទៅស្លាប់ត្រង់ណា ប៉ុន្តែខ្ញុំឮថាវត្តនេះអូរត្រកួននេះ ទៅតែខាងលិចហ្នឹង បាទខ្ញុំអត់បាច់តាមដានទៅវត្តអូរត្រកួនទេហ្នឹងចាប់ពីហ្នឹងបន្តៗ។

**ស៖** បាទ អរគុណ។ ថាតើនៅពេលដែលលោកពូដឹងអំពីការភ្ជង់យកទៅហ្នឹង នៅពីក្រោយនោះវាមានមូលហេតុអ្វីដែលពាក់ព័ន្ធនឹងរឿងការគោរពសាសនាដែរឬអត់?

**ឆ៖** វាពាក់ព័ន្ធ ពីព្រោះខាងសាសនាមហាម៉ាត់ កុំថាតែខ្មែរក្រហមមកឃាត់ថាកុំឲ្យសំពះយ៉ាំងគេនៅតែលបធ្វើតែអ៊ីចឹង ហើយលបធ្វើ លបសំពះយ៉ាំង ប៉ុន្តែអាហ្នឹងកាលពីជំនាន់ហ្នឹង ឈ្លបលបមើលរួចលបមើលលោតែយកទៅអត់ប្រាប់ថា ហ៊ឺះ! អានេះរឿងសំពះយ៉ាំង អញយកវាទៅសម្លាប់ចោល អត់ប្រាប់ទេ បាត់ខ្លួនទៅតែម្តង ពេលហូបបាយទៅចាប់យកតែម្តង។ អ៊ីចឹងមានន័យថាឈ្លបហ្នឹងទៅពិនិត្យមើល លបអាខាងមូស្លីមហ្នឹងកាលណាគេឃាត់ហើយ គេមិនស្តាប់ទេ គេលបធ្វើដោយស្ងាត់ៗ ធ្វើម្នាក់ឯងក៏បានដែរ សំពះយ៉ាំងទៅអល់ឡោះ ហ្នឹងគោរពអល់ឡោះហ្នឹង។ កន្លែងហ្នឹងហើយ ដែលពួកឈ្លបហ្នឹងច្រើនតែឈ្លប។ អាហ្នឹងខ្ញុំ គ្រាន់តែវាយស្មានទេ ព្រោះវាគ្មានប្រាប់អីទេ ជួនណាកំពុងតែហូបបាយវាភ្ជង់យកៗ។ ហើយវាហាមរួចហើយតើ ពេលវាភ្ជង់ហ្នឹង លូកដៃដាច់ដៃ លូកជើងដាច់ជើង កង់ប្រវត្តិសាស្ត្រវិលទៅហើយបងប្អូន។ ហើយតែលបធ្វើ គឺមានកំហុស ងាប់តែប៉ុណ្ណឹង។

**ស៖** បាទ អរគុណ សូមលោកពូសម្រួលអារម្មណ៍ហើយឆ្លើយទៅតាមសំណួរ ហើយសូមឲ្យខ្លីបន្តិច បាទ។ ចំណុចនេះដែរ ថាតើ អ្វីដែលលោកពូបានលើកឡើងអំពីការហូបចុក ថាតើ រឿងហូបចុកនេះ ហូបរួម ហើយចំពោះបងប្អូនចាម គេអាចបង្ខំឲ្យពិសាអីដែរឬទេ?

[១១:០៧:២៥]

**ឆ៖** បាទ គេប្រជុំរួច គេប្រាប់រួច គេឲ្យបងប្អូនចាមហូបសាច់ជ្រូក។ រួចដល់ពេលទៅហូបបាយហ្នឹង គ្មានគេទៅឃាត់ គ្មានគេអីទេ គឺស្ងាត់ស្ងៀមទាំងអស់ ក៏គ្មានឈ្លបគ្មានអីទៅមើលទេ ព្រោះមិនបាច់ទៅមើលដែរហ្នឹង ពីព្រោះមានអ្នកផងទាំងអស់ហ្នឹង កាលហ្នឹងយកគុណសម្បត្តិ។ អ្នកណាវាយ

ការណ៍ឲ្យខ្មែរក្រហម អ្នកហ្នឹងគេអ្នកស្មោះស អ្នកហ្នឹងឲ្យគាត់ការពារខ្លួនគាត់ហ្នឹងគាត់ថាយកកិត្តិយស គាត់ ដើម្បីថាគាត់នេះស្មោះសជាមួយនឹងខ្មែរក្រហម បានជាមិនបាច់ឈ្លបអីទៅឈ្លបទេ អ្នកផងហូប បាយទាំងអស់ហ្នឹង ដើម្បីយកគុណសម្បត្តិ យកគុណសម្បត្តិដើម្បីថាទៅវាយការណ៍ថា នេះ អានេះ ប្រឆាំងនឹងបដិវត្តន៍ អាហ្នឹងវាមានគុណសម្បត្តិវា ហើយគេទុកវា។ អ៊ីចឹងអ្នកផងទាំងអស់ហ្នឹងដណ្ដើម យកគុណសម្បត្តិ។

**ស៖** បាទ អរគុណ ត្រង់ចំណុចនេះ ថាតើក្រុមបងប្អូនជនជាតិចាមទាំងអស់គឺត្រូវឲ្យគេ ត្រូវតែ ហូប ឬមួយយ៉ាងណា នៅពេលនោះ?

**ឆ៖** បាទ ខាងសាសនាមហាម៉ាត់ បើសិនជារបស់ហ្នឹងហូបមិនបានហើយគេបង្ខំ គេតម្រង់ កាំភ្លើងចំកណ្ដាលហើយ ឲ្យហូប បើមិនហូបទេ អ៊ីចឹងគេត្រូវហូប ហូបពីមុខសត្រូវហ្នឹង ហូបដើម្បី ការពារជីវិត ហូបក៏មិនបាបដែរ។ ប៉ុនហូប បាទ បងប្អូនខ្ញុំមានហូបខ្លះហើយ បាទ ពីព្រោះថា មិនហូប ទេ អញបាញ់ឯងចោល។ អ៊ីចឹងគេហូបៗដោយទឹកភ្នែកទៅណ៎ា។

**ស៖** តើហូបៗហ្នឹង ហូបសាច់អីដែរ?

[១១:១០:១២]

**ឆ៖** សាច់ជ្រូក ហូបសាច់ជ្រូកបាទ។ ព្រោះខ្ញុំក៏បានហូបដែរ បានខ្ញុំចេះឆ្លើយអ៊ីចឹង ខ្ញុំបានហូប ដែរ បើខ្ញុំមិនហូបទេគេបាញ់ខ្ញុំចោល។

**ស៖** ចំពោះការហូបនេះ ចុះផ្នែកមួយទៀត ការគោរពផ្សេងៗ ទំនៀមទម្លាប់ផ្សេងៗ តើគេត្រូវ ធ្វើដូចម្ដេចដែរ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធានមិនមែនជាការជំទាស់ទេ ប៉ុន្តែស្នើសុំឲ្យមេធាវីតំណាងដើមបណ្ដឹងរដ្ឋ ប្បវេណីសួរឲ្យជាក់លាក់បន្តិចថា តើសួរ -- ការសួរនេះគឺពាក់ព័ន្ធក្នុងអំឡុងពេលណា? <ខ្ញុំគិតថា>ដូច និយាយតែពី៧៥<ឬ> ឆ្នាំ១៩៧៦។ ហើយពីមុននោះ ខ្ញុំឮមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសួរដែរថា គឺ អំពើហ្នឹងកើតឡើងនៅក្នុងឆ្នាំណា? ដូច្នេះខ្ញុំក៏ចង់បានចម្លើយនេះដែរ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ឡៅ ជុនធី៖**

បាទ អរគុណ។

**សួរដោយលោក ឡៅ ជុនធី៖**

**ស៖** ខ្ញុំសូមជម្រាបសួរលោកពូបន្តទៀតថាតើរឿងហេតុដែលខ្ញុំបានសួរអម្បាញ់មិញ តើកើតនៅក្នុងអំឡុងឆ្នាំណាដែរ?

**លោក ហ៊ីម ម៉ាន៖**

**ឆ៖** បាទ ខ្ញុំប្រហែលដែលទេ កើតនៅឆ្នាំមួយពាន់ប្រាំបួនរយ -- មួយពាន់ប្រាំបីរយ ដូចប្រាំបួនរយទេដឹងនេះ -- អំឡុងឆ្នាំហ្នឹងហើយ ១៩៧៦ – ៧៦ហ្នឹងហើយ ព្រោះខ្ញុំអង្គាល់ហ្នឹងវាមនុស្សមិនដឹងជាម៉ែត្រនៅត្រង់ណាអីត្រង់ណាទេ ចេះតែស្មានទៅៗ។ រួចបើកាលរឿងៗធ្វើបាបហ្នឹងមិនស្មានទេ បើកាលឆ្នាំហ្នឹងស្មានទៅ។ បាទ ឆ្នាំខែហ្នឹងខ្ញុំស្មានហើយ ពីរឿងធ្វើបាបខ្ញុំពួកខ្ញុំអត់ស្មានទេ ប្រាកដណាស់។

**ស៖** បាទ អរគុណលោកពូ។ ខ្ញុំសូមបញ្ជាក់ចំណុចទៅក្រោយបន្តិចថាតើការប្រជុំគេហ្នឹងគេមានលើកឡើងថា ជនជាតិចាមហ្នឹងជាខ្មាំងនឹងគេដែរអត់ទេ?

**ឆ៖** ព្រោះមានពួចចាមអារ៉ាមពេញភូមិថា ចាមហ្នឹងខ្មាំងទី១ ទាំងបងប្អូនខ្មែរខ្មាំងទី២។ រួចខ្ញុំហ្នឹងក៏វាឆ្ងល់សួរទៅទៀតអ្នកហ្នឹងមិនដឹងថាឈ្មោះអីទេ ខ្ញុំសួរថាបងប្អូនខ្មែរម៉េចបានដាក់ខ្មាំងចាម ខ្មាំងទី១វិញ? គាត់ប្រាប់ខ្ញុំ គាត់និយាយជំនាន់ព្រះហ្នឹងមក ចាមបានគេដាក់ខ្មាំងទី១ ហ្នឹងចាមហ្នឹងល្មោភសង្គ្រាមណាស់ ច្បាំងមួយជំនាន់ព្រះមកហើយ បានគេដាក់ៗខ្មាំងទី១ទៅវិញ ល្មោភសង្គ្រាមណាស់។ ពួកខ្ញុំ ពួកអ្នកល្ងង់ ខ្ញុំស្តាប់*(ឮមិនច្បាស់)* ទៅបាន។ វាទៅជាអ៊ីចឹងទៅវិញ ប៉ុន្តែឮនេះចចាមអារ៉ាមទេ។ ចេះតែបន្តៗបាទ ឮតែអ៊ីចឹង។ ខ្ញុំសួរ សាកសួរ សួរលេងៗទេបាទ គេថាអ៊ីចឹង។ ខ្ញុំវាឆ្ងល់ថា ស្អីក៏ខ្ញុំមានទោសខ្មាំងទី១ ហ្នឹង។

[១១:១៥:២៥]

**ស៖** បាទ អរគុណលោកពូ។ ខ្ញុំឈានចូលនូវបរិបទមួយទៀត បងប្អូនចាមដែលរស់នៅក្នុងភូមិដែលលោកពូបានលើកឡើងអម្បាញ់មិញថា នៅសល់៣០គ្រួសារ។ ថាតើនៅពេលនោះ មានប្រជាជនផ្សេងទៀតមករស់នៅក្នុងភូមិនេះដែរឬទេ?

**ឆ៖** មាន។ ខ្មែរក្រហមចាត់តាំងឲ្យខ្មែរយើងហ្នឹងចូលទៅនៅភូមិចម្រុះគ្នាបាទ។ ចម្រុះចាមខ្មែរ

នៅចម្រុះគ្នាបាទ ហើយនៅចម្រុះគ្នាអ៊ីចឹងទៅ គេហៅថា គ្មានចាមគ្មានអីទៀតទេ មានតែខ្មែរមួយបាទ។

**ស៖** លោកពូចាំទេថា ព្រឹត្តិការណ៍នុំងនៅក្នុងអំឡុងឆ្នាំ៧៦ ឬមួយក្នុងឆ្នាំណា?

**ឆ៖** ឆ្នាំហ្នឹងខ្ញុំវាយស្មានទៀតហើយ ព្រោះពេលហ្នឹងតែវាយស្មានទាំងអស់ហ្នឹង ពេលហ្នឹងពេលសង្គមហ្នឹងនោះ វាយស្មានប្រហែល៧៦ណា ៧៦ហ្នឹងដដែលបាទ។

**ស៖** បាទ អរគុណ គឺនៅក្នុងភូមិនេះ មានថ្ងៃមួយ គឺមានការកៀររបស់ខាងខ្មែរក្រហមហ្នឹងកៀរប្រជាជនចាមហ្នឹងចេញពីភូមិហ្នឹង។ តើនៅពេលនោះ លោកពូនៅក្នុងនុំងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់អំពីឯកសារផង ទាក់ទងទៅនឹងការកៀរនេះ ពីព្រោះសាក្សី -- ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមិនទាន់បានឆ្លើយបញ្ជាក់អំពីការកៀរណាមួយនៅឡើយទេ។បាទ សូមអរគុណ។

**លោក ឡៅ ជុនធី៖**

បាទ អរគុណលោកប្រធាន គឺអ្វីដែលខ្ញុំបាទបានលើកឡើងនេះ គឺសំអាងទៅលើឯកសាររបស់គាត់ E3/4706 ហើយនៅ ERN ខ្មែរគឺ 00369051 ហើយ ERN អង់គ្លេស និងបារាំង ខ្ញុំសូមជូនតាមក្រោយបាទ។ អង់គ្លេស 00417863--

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី គង់ សំអុន!

[១១:១៩:៥៨]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ដើម្បីជៀសវាងការតាំងសំណួរដោយការអាន ឬក៏ស្រង់ដែលមានលក្ខណៈជាការនាំមុខនោះ គួរតែមានការតាំងសំណួរជាលក្ខណៈទូទៅសិន ណាមួយដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយទាក់ទងនឹងឯកសារដែលលោកចង់បង្ហាញនេះ។ បាទ សូមអរគុណ។

**លោក ឡៅ ជុនធី៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាទ អរគុណ។ ខ្ញុំរៀបចំសំណួរលើបញ្ហានេះឡើងវិញ។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សំណួរថាតើនៅក្នុងភូមិសាច់សូនោះមានព្រឹត្តិការណ៍អ្វីដែលកើតឡើងបន្ទាប់មកដែរឬទេ?

**លោក ហ៊ីម ម៉ាន៖**

**ឆ៖** ក្រោយមកឱ្យជនជាតិខាងមូស្លីម ខាងមហាម៉ាត់ហ្នឹង កុំឱ្យទៅធ្វើការ ឱ្យនៅនឹងផ្ទះហ្នឹង នៅនឹងភូមិស្រុកហ្នឹង ឱ្យនៅ គេចាប់ផ្តើមហើយថ្ងៃហ្នឹង ខាងបងប្អូនខ្មែរចេញធ្វើការ អ៊ីចឹងនៅតែជនជាតិទាំងអស់ដែលនៅសេសសល់ពីគេជម្លៀសនោះ។ ដល់អ៊ីចឹង ខ្ញុំចេះតែសង្ស័យ រឿងនេះប្រហែលមានហេតុការណ៍ហើយ ចេះតែសង្ស័យខ្ញុំនៅក្នុងខ្លួន មានហេតុការណ៍ហើយបានជាគេឱ្យពួកយើងនៅទាំងអស់ហ្នឹង។ ហើយដល់អ៊ីចឹង ថ្ងៃម៉ោងបីវាប្រមូលតែម្តង មានអាក្រុមដាវវែងមកៗប្រមូលតែម្តង។ ប្រមូលខ្លះទៅស្លៀកខោទៅ ខ្លះស្លៀកក្រមាទេ ខ្លះអត់មានអាវទេ។ ព័ទ្ធជុំៗរួច កៀងយកទៅតែម្តង ដោយទាំងខ្ញុំអីទៅទាំងអស់ នៅនោះ ដល់មែនដូចគិតមែន។ បាទ យកទៅរណ្តៅ វត្តអូរត្រកួន បាទ ទៅវត្តអូរត្រកួន។ រួចខ្ញុំក៏បានមក ខ្ញុំថាពួកនេះកៀងទៅហើយអ៊ីចឹង ជាប់អង្គប់គេហើយ ព្រោះខ្ញុំធ្វើយ៉ាងម៉េចឱ្យរួចខ្លួន? ខ្ញុំប្រាប់ប្រពន្ធខ្ញុំៗ ថា យើងលែងរបៀបម៉េច បើជាប់អង្គប់គេហើយ? ពេលនេះ កុំគិតរឿងបងប្អូនអី គិតមួយរួចខ្លួន ដោយៗខ្លួនទៅ។ ហើយខ្ញុំក៏ដើរតម្រង់ នៅក្នុងហ្វូងហើយ ខ្ញុំដើរមុខគេដូចមុខព្រួញអ៊ីចឹង ដើរមុខគេឱ្យអាពតវាទុកចិត្តថាទៅរណ្តៅហើយ រួចទៅតម្រង់រណ្តៅ រួចទៅជួបពួកតំបន់ម្នាក់ វាសួរខ្ញុំថា៖ “មិត្តឯងទៅណា?” ខ្ញុំក៏ឆ្លើយថា៖ “ខ្ញុំរកគោៗក៏ខ្ញុំក៏ស្រែកឱ្យគ្រួសារខ្ញុំថា ខទីចះមកឱ្យលឿនមក ដំណាំតឡូវមិនធម្មតាទេ តែគោយើងស៊ីគឺគុកហើយ។ អាហ្នឹងក៏ងាប់ក្រឡាស្លក អត់ឃាត់ខ្ញុំទេ ខ្ញុំក៏ទៅទៀតៗជួបអ្នកភូមិម្នាក់ “ហ្អែងទៅណា?” ប៉ុន្តែមុខហ្វូងគេហ្នឹង ខ្ញុំទៅៗដើរមុខហ្វូងអាក្រុមដាវវែងហ្នឹងកៀងមកហើយ កៀងមក ប៉ុន្តែខ្ញុំទៅមុខហ្វូងគេថា “ទៅណា?” ខ្ញុំថា “រកគោ” ព្រោះគាត់វាចៃដន្យអីគាត់ឃើញគោក្រហមមែន។ គោអី?គោក្រហមឃើញនៅក្រោយផ្ទះ។ បាទគោក្រហមហ្នឹង ឃើញនៅក្រោយផ្ទះសមល្មមនឹងបួងដែលខ្ញុំទៅហ្នឹង។ បាទខ្ញុំរួចខ្លួនៗទៅថាខ្លួន ទៅតិចហ្នឹងថារួចខ្លួន។ មានអី អាក្រៅភូមិសុទ្ធតែកាំភ្លើង បានក្រាបនៅគុម្ពោតព្រៃ។ ត្រឹមគុម្ពោតព្រៃហ្នឹងគុម្ពោតព្រៃហ្នឹងសំណាងល្អដែរ វាបានមើលខ្ញុំមិនឃើញបាទ មើលខ្ញុំមិនឃើញ ពីព្រោះថានៅប្រហែល ជា ៥០ម៉ែត្រ វាគួរតែឃើញហើយថ្ងៃចែស ម៉ោងបី ភ្លឺស្រែ គុម្ពោតព្រៃតូច មើលទៅឃើញខ្មៅសុទ្ធតែកាំភ្លើងអាកា បាទខ្មៅ។ ដល់ថាអ៊ូ! មិនដឹងលោកណាទេ ខ្ញុំមិនដឹងទេ ប៉ុន្តែព័ទ្ធភូមិ។ មានអាកៀងក្នុងភូមិហ្នឹងហើយ អា

ក្រុមដាវវែងមានអាព័ទ្ធភូមិហ្នឹងទៀត កុំឱ្យរួចមួយ។ បាទ ជីកស្មៅជីកទាំងឫស។

[១១:២៥:១៨]

**ស៖** អរគុណលោកពូ ខ្ញុំសូមកាត់បន្តិច។ ខ្ញុំចង់ពិនិត្យទៅលើអ្វីដែលលោកពូបាននិយាយអម្បាញ់មិញ ថាតើគេប្រមូលប្រជាជនហ្នឹង ថាតើប្រមូលយ៉ាង ប្រជាជនចាមហ្នឹង ប្រមូលយ៉ាងដូចម្ដេច? ចង់ឱ្យលោកពូ បញ្ជាក់ឱ្យច្បាស់តិចមើល?

**ឆ៖** គេប្រមូលរបៀបហ្នឹងហើយ។ គេមិនចង់ឱ្យច្រឡំខ្មែរ បើសិនជាខ្មែរនៅក្នុងភូមិហ្នឹងដែរហ្នឹង វាកៀងចាមហ្នឹងវាច្រឡំខ្មែរ។ បាទ អ៊ីចឹងវាឱ្យខ្មែរទៅធ្វើការដើម្បីនៅតែចាម កុំឱ្យច្រឡំខ្មែរនិងចាមយកទៅសម្លាប់ជាមួយគ្នា។ រួចដល់ក្រោយមកទៀតហ្នឹង វាប្រមូលទាំងអស់អាដែងនៅពីក្រោយហ្នឹង ដែលថាឱ្យចេញផុតពីភូមិចាមឱ្យទៅនៅធ្វើការហ្នឹង ក្រោយមកអាហ្នឹងក៏ងាប់ដែរ ប្រមូលទៅទាំងអស់។ បាទ សុទ្ធតែរឿងរ៉ាវអស់។

**ស៖** បាទ អរគុណ។ ចំណុចសំខាន់នៅក្នុងសកម្មភាពនៃការប្រមូល ទី១ ថាតើប្រមូលគេមានបានប្រាប់បងប្អូនជនជាតិចាមហ្នឹងថាយកទៅណាទេ? ទី២ ថាតើពេលដែលគេប្រមូលហ្នឹង គេមានចាប់ចង ឬមួយគេឱ្យយើងដើរតែធម្មតា?

**ឆ៖** ពេលគេប្រមូលហ្នឹងចង អ្នកដែលខ្លាំងដែលមើលទៅឃើញថាខ្លាំងណាស់ ចង។ បាទ អ្នកដែលខ្សោយ មើលទៅឃើញខ្សោយហ្នឹងមិនបាច់ចងទេ វាគ្មានរត់ទៅណាទេ តាពីសតាពាសនិយាយវាពេញភូមិ។ កុំថាតែខ្ញុំមនុស្សហ្នឹង ទោះបីតែសត្វគោក៏វាស្រែកដែរ ស្រែកពេញភូមិ តាំងពីមាន់តាំងពីឆ្កែ។ ស្រែកស្គាល់ម្ចាស់វាទៅងាប់ហើយ បាទ ម្ចាស់វាទៅងាប់ហើយ។ អ៊ីចឹងសត្វក៏ដឹងដែរ។ បាទ រួចតែសត្វដឹងប៉ុណ្ណឹងហើយហ្នឹង អស់លោកហ្នឹងអត់ដឹងទេ យកមនុស្សទៅសម្លាប់ចោល បាទ។

**ស៖** បាទ អរគុណ។ ក្នុងសកម្មភាពមួយទៀត លោកពូថាខាងមានកងដាវវែង កងអី គេអម។ ចុះចំពោះលោកពូ ហើយនិងប្រពន្ធ ម៉េចបានរត់ហើយចេញពីហ្វូងហ្នឹងរួច?

**ឆ៖** ដ្បិតថាខ្ញុំហ្នឹង កាលនុ៎ងខ្ញុំប្រើល្បិចខ្ញុំដែរហ្នឹង ប្រើល្បិចធ្វើជាមនុស្សទន់ភ្លន់មិនបាច់ចងមិនបាច់អីទេ។ វាមើលទៅឃើញទន់ភ្លន់ វាអត់ចង។ វាចេញល្បិចខ្ញុំ បាទ បានខ្ញុំចេញពីហ្វូងបានហ្នឹងទៅក្រាបនៅផ្លូវស្រែមួយគុម្ពោតព្រៃហ្នឹង បាទ ក្រាបត្រង់ហ្នឹង។ កន្លែងហ្នឹងដែលវាចេញល្បិចរបស់ខ្ញុំហ្នឹង បាទ។

[១១:២៩:១៧]

**ស៖** បាទ អរគុណ។ ចាតើនៅពេលដែលលោកពូរត់ចេញពីហ្វូងបានហើយ ទៅពួននៅទីនោះតាំងពីម៉ោងប៉ុន្មានរហូតទៅដល់ម៉ោងប៉ុន្មាន? តើនៅក្នុងរយៈពេលហ្នឹង លោកពូបានដឹងព័ត៌មានអីបន្ថែមទៀតទេ?

**ឆ៖** បាទ ខ្ញុំដឹង ព្រោះខ្ញុំអ្នកឆ្លងកាត់បាទ ខ្ញុំសូមជម្រាបអស់លោកទាំងអស់ ខ្ញុំប្រាប់កន្លែងហ្នឹងហើយដល់ពេលយប់ បាទខ្ញុំប្រាប់ទាល់តែយប់ យប់ទៅងងឹងមិនដឹងម៉ោងប៉ុន្មាន ប្រហែលជាម៉ោងប្រាំពីរអីហ្នឹង ងងឹត វាវៃពួកជនជាតិ ម៉េចក៏ខ្ញុំនៅនេះ ខ្ញុំដឹង វានៅក្បែររណ្ដៅប្រហែលជា១០០ម៉ែត្រហ្នឹងបាទ។ ម៉េចក៏ខ្ញុំដឹងបើនៅដល់១០០ម៉ែត្រ? បានជាដឹងពួសម្រែក ខ្ញុំនៅក្រាបជាមួយប្រពន្ធខ្ញុំហ្នឹងពួសម្រែក គ្រាន់តែវៃក៏ឮដែរ ពួសម្រែកថា "អល់ឡោះប៉ូលឹយ អូម៉ែហុត អានេះប៉ូលឹយ" ស្រែកហៅអល់ឡោះ បាទ។ អ៊ីចឹងស្រែកអ៊ីចឹងស្រែកថាអល់ឡោះៗជាម្ចាស់។ អ៊ីចឹងរឿងអីដែលក្រៅពីសាសនាមូស្លីមទៅស្រែកអល់ឡោះ មានតែបងប្អូនខ្ញុំ ឪខ្ញុំ ម៉ែខ្ញុំ ប្អូនខ្ញុំ បងប្អូនអ្នកភូមិអ្នកផងទាំងអស់ហ្នឹង ចាមដែលប្រមូលទៅជាមួយខ្ញុំហ្នឹង ដែលខ្ញុំគេចរួចហ្នឹង បានខ្ញុំពួស្នូរហ្នឹងដោយសារខ្ញុំក្រាបនៅក្បែរហ្នឹងដោយសារមានពួកខ្មែរក្រហមនេះ វាព័ទ្ធភូមិនេះ បាទ។ ខ្ញុំ--

**ស៖** បាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទៗអរគុណ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោកខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

បាទ សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរួមនឹងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគីនិងសាធារណជនបានជ្រាបថាដោយអង្គជំនុំជម្រះត្រូវទុកពេលវេលាសមស្របសម្រាប់ភាគីសហមេធាវីការពារក្តីមានពេលវេលា និងលទ្ធភាពក្នុងការត្រៀមរៀបចំសម្រាប់ការពិភាក្សាដេញដោលដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីមួយចំនួនខាងមុខនេះ និងដោយសារតែបញ្ហានានាដែលលើកឡើងដោយភាគីកាលពីព្រឹកមិញនេះ និងដើម្បីស្វែងរកដំណោះស្រាយសមស្រប និងមានករណីខ្លះ បញ្ហាខ្លះដែលអង្គជំនុំជម្រះត្រូវសម្រេចនៅក្នុងរយៈពេលឆាប់ៗផងនោះ ហើយក្រោយពីបញ្ចប់ការស្តាប់សួរដេញដោលសាក្សីរូបនេះ ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរួមទាំងសហព្រះរាជអាជ្ញា នោះអង្គជំនុំជម្រះនឹងផ្អាកសវនាការក្នុងការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅថ្ងៃនេះ។ ហើយមួយទៀត អង្គជំនុំជម្រះក៏ជម្រាបផងដែរថាអង្គជំនុំជម្រះនឹងមិនធ្វើសវនាការនៅសប្តាហ៍ក្រោយនេះទេ។ ចំណែកឯបញ្ហាផ្សេងៗទៀត អង្គជំនុំជម្រះនឹងផ្តល់ព័ត៌មានជូនភាគីជ្រាបតាមរយៈអ៊ីម៉ែល ក្នុងពេលសមស្របឆាប់ៗខាងមុខតាមដែលអាចធ្វើទៅបាន។

បាទ មានប៉ុណ្ណឹងទេ ដោយសារបញ្ហាវាមានច្រើន។ អ៊ីចឹងបញ្ហាមួយចំនួន អង្គជំនុំជម្រះដោះស្រាយបន្ទាន់ ហើយនិងបញ្ហាមួយចំនួនទៀត អង្គជំនុំជម្រះនឹងជូនដំណឹងភាគីតាមរយៈអ៊ីម៉ែលក្នុងអំឡុងពេលឆាប់ៗខាងមុខនេះ។

សូមអញ្ជើញលោកចៅក្រម ហ្វេនស៍!

[១៣:៣៥:២៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំជឿជាក់ថា ប្រហែលជាអាចជួយដល់ភាគីផងដែរ ប្រសិនណាខ្ញុំបញ្ជាក់តាមការបកប្រែជាភាសាអង់គ្លេស អង្គជំនុំជម្រះបានសម្រេចនឹងផ្អាកសវនាការ<នៅថ្ងៃនេះ> ក្រោយពី<សហមេធាវីនាំមុខ និងសហព្រះរាជអាជ្ញាបានសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ>។ ដូច្នេះ<ការសួររបស់>ភាគីមេធាវីការពារក្តីនឹង<ធ្វើ>ក្រោយពេល<សម្រាក។> មានបញ្ហាជាច្រើនដែលបានលើកឡើងព្រឹកមិញនេះ អង្គ

ជំនុំជម្រះនឹងពិចារណាទៅលើបញ្ហានេះ ហើយនិងជូនដំណឹងទៅដល់ភាគីទៅក្នុងរយៈពេលមួយសមស្រប។ ប៉ុន្តែដើម្បីជូនដំណឹងឲ្យបានជាមុន យើងថាអង្គជំនុំជម្រះនៅថ្ងៃនេះគឺថានឹងជម្រាបជូនដល់ភាគីទាំងអស់ថា សប្តាហ៍ក្រោយនេះគឺនឹងផ្អាកសវនាការសិន។ តើភាគីជ្រាបបានទេ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមការបំភ្លឺពីព្រោះថាសហភាតាខ្មែរ គឺអត់យល់ដូចខ្ញុំទេ។ បើសិនជាយើងខ្ញុំស្តាប់មិនច្រឡំទេគឺថា លោក ហ៊ីម ម៉ាន នឹងត្រឡប់មកម្តងទៀតនៅសប្តាហ៍ក្រោយ។ តើអ៊ីចឹងមែនទេ?

ខ្ញុំគ្រាន់តែចង់ជម្រាបជូនអង្គជំនុំជម្រះថា គាត់នៅទីនេះប្រាំថ្ងៃមកហើយ។ អ៊ីចឹងវាពិបាកណាស់សម្រាប់គាត់ដែលត្រឡប់មកវិញសប្តាហ៍ក្រោយមកទៀត ប៉ុន្តែទោះជាយ៉ាងណាក៏ដោយខ្ញុំគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះលើបញ្ហានេះ។

[១៣:៣៦:២៨]

**ប្រធានអង្គជំនុំ៖**

យើងធ្វើសវនាការនៅថ្ងៃនេះ គឺត្រឹមតែបញ្ចប់ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាទេ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សប្តាហ៍ក្រោយ អង្គជំនុំជម្រះមិនធ្វើសវនាការទេ ទុកលទ្ធភាពជូនភាគីសហមេធាវីការពារក្តីលោកមានឱកាសនិងពេលវេលាសមស្របក្នុងការពិនិត្យ សិក្សាស្វែងយល់អំពីឯកសារពាក់ព័ន្ធ ដើម្បីសួរដេញដោលសាក្សីនៅពេលក្រោយ -- ដើមបណ្តឹងរដ្ឋប្បវេណីទាំងរូបនេះផង និងទាំងផ្សេងទៀតហ្នឹងនៅពេលក្រោយ។ ហើយសវនាការហ្នឹង អង្គជំនុំជម្រះនឹងធ្វើបន្តធ្វើនៅសប្តាហ៍ក្រោយមួយទៀតហ្នឹងគឺនៅចាប់ពីថ្ងៃទី២៨ ខែកញ្ញា គឺថ្ងៃចន្ទ រំលងសប្តាហ៍ក្រោយនេះ។ ហើយនេះជាបញ្ហាដែលបញ្ជាក់។ ហើយចំពោះបញ្ហាផ្សេងទៀតដែលមានការពាក់ព័ន្ធទៅនឹងសំណើសុំដែលវាមានបញ្ហាស្មុគស្មាញ អង្គជំនុំជម្រះនឹងយកពេលវេលាទាំងអស់នេះទៅពិភាក្សាដើម្បីរកដំណោះស្រាយសមស្រប ហើយនិងជូនដំណឹងដល់ភាគីជ្រាបឲ្យបានឆាប់ៗក្នុងពេលសមស្របខាងមុខនេះ តាមដែលអាចប្រឹងប្រែងធ្វើទៅបាន។

បាទ ជាបន្តទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសបន្តសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះសាជាថ្មី។ ខ្ញុំសូមធ្វើសំណួរជាបន្ត។

[១៣:៣៨:២៥]

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** លោក ហ៊ីម ម៉ាន ព្រឹកមិញខ្ញុំបានសួរទៅដល់ចំណុចថា ពួបានទៅពួន ពួនហើយមានឮស្នូរសំឡេងស្រែក។ ថាតើការពួនហ្នឹង ពួនរហូតទៅដល់ប៉ុន្មានថ្ងៃ ឬមួយពួនហើយមានសកម្មភាពធ្វើអ្វីផ្សេងៗទៀត?

**លោក ហ៊ីម ម៉ាន៖**

**ឆ៖** ខ្ញុំពួនហ្នឹងដោយសាររត់ហ្នឹងប្រុងទៅក្នុងត្រពាំងហ្នឹងដែរ ក៏ប៉ុន្តែវាឃើញថាយោធិនដែលនៅពីមុខខ្ញុំៗក៏ក្រាបនៅភ្លឺស្រែហ្នឹងទៅ គុម្ពោតព្រៃតូចហ្នឹង។ ហើយពេលខ្ញុំពួនហ្នឹងជាមួយប្រពន្ធខ្ញុំហ្នឹងហើយទៅទៀតគឺខ្ញុំគ្រោះថ្នាក់ ពីព្រោះមានគេព័ទ្ធភូមិហ្នឹង។ ហើយអ៊ីចឹងទៅ ខ្ញុំឮសម្រែក ខ្ញុំនៅពួនហ្នឹងឮសម្រែកប្រហែលជា -- អឹងងឹតហើយ ប្រហែលម៉ោងៗប្រាំមួយប្រាំពីរហ្នឹង តាមស្មានទេ ពីមុនហ្នឹងសុទ្ធតែស្មានទាំងអស់ហ្នឹង បើងងឹតម៉ោងប្រាំមួយ ម៉ោងប្រាំពីរ។ អ៊ីចឹងសម្រែកថា “អល់ឡោះប៉ូលឹយ!” អ៊ីចឹងខ្ញុំក៏ផ្ដេកផ្ដួលថា ប្អូនខ្ញុំ ម៉ែខ្ញុំដែលគេចាប់ទៅជាមួយខ្ញុំ ហើយខ្ញុំរត់រួចហ្នឹង ឥឡូវឮស្នូរស្រែក “អល់ឡោះប៉ូលឹយ! ព្រះអើយ! ប៉ូលឹយ!”។ អ៊ីចឹង ស្រែកអ៊ីចឹងមានន័យថា ពួកសាសនាមហាម៉ាត់ហើយដែលទៅក្នុងភូមិហ្នឹងទាំងអស់គ្នាហ្នឹង ជាប់ខ្ញុំទៅពួនហ្នឹង ខ្ញុំបានស្ដាប់កន្លែងហ្នឹងបាទ។ ហើយស្ដាប់កន្លែងហ្នឹង--

**ស៖** បាទ ខ្ញុំសូមកាត់បន្តិចព្រោះកន្លែងហ្នឹងអាចនិយាយហើយៗ។ ថាតើពួននៅទីនោះ ហើយមានចេញទៅណាទៀតដែរអត់?

**ឆ៖** ខ្ញុំក៏ផ្ដាំប្រពន្ធខ្ញុំថា ខ្លួននៅចាំនៅហ្នឹងទៅ ខ្ញុំឡើងមកលើនេះ ខ្ញុំមកស៊ើបការណ៍ថា សល់ពួកខ្ញុំប៉ុន្មាននាក់ ពួកមូស្លីមហ្នឹង ពួកកាន់សាសនាមហាម៉ាត់ហ្នឹងប៉ុន្មាននាក់ដែលនៅសល់ ឬមួយអស់ហើយខ្ញុំក៏ឡើងមក ៗ ដើម្បីទៅយក ទៅរកកាំភ្លើងផង ដើម្បី -- វាអាណោចអាធ័មដែលគេកំពុងតែវ៉ៃនេះ។ អ៊ីចឹងខ្ញុំទៅរក ដល់ទៅៗពិនិត្យមនុស្សដែលនៅក្នុងភូមិនៅសល់ប៉ុន្មាននាក់ ទៅខ្ញុំឡើងទៅក្នុងវិហារចាមហ្នឹង ខ្ញុំស្ទាបទៅស្ទាបមកហ្នឹង នៅដេករាប ប៉ុន្តែអត់មានកាំភ្លើង ខ្ញុំរកកាំភ្លើងអត់បានទេ។ បាទ ខ្ញុំរកកាំភ្លើងអត់បាន ខ្ញុំអស់សង្ឃឹម ដែលខ្ញុំ ចិត្តខ្ញុំចង់ទៅជួយបងប្អូនដែលនៅក្នុងភូមិដែលខ្ញុំធ្លាប់រស់នៅជាមួយគ្នា ស៊ីបាយកក បាយក្ដាំងជាមួយគ្នា កាលពី -- ដល់ថ្ងៃដែលខ្ញុំនៅមិនទាន់មានរឿងហ្នឹង ធ្លាប់

ជួបគ្នា។អ៊ីចឹងថ្ងៃនេះវាអស់ដឹងថាទៅងាប់ហ្នឹង។ អ៊ីចឹងវាផ្ដេកផ្ដួល។ អ៊ីចឹងខ្ញុំមានលទ្ធភាពអីទៅជួយបើអត់មានកាំភ្លើងមានអីហ្នឹង។ បាទ បានខ្លួនខ្ញុំហ្នឹងវាទ្រុឌទ្រោមពីថ្ងៃនុ៎ងមក។ វាគ្មានអីសង្ឃឹម។ បាទ ចិត្តខ្ញុំនេះវាចង់ឆ្កួតបន្តិចអីបន្តិចហើយ ព្រោះវាអស់ពូជអម្បូរហ្នឹងវាអស់ ខាងសាសនាអីរលីងតាំងពីសាច់ញាតិ សាច់សាលោហិតក្នុងភូមិរលីងខ្ញុំគ្មានសង្ឃឹមទេ។ រួចខ្ញុំគិតថា បើមានកម្លាំងជួយនេះ បើមានលទ្ធភាពជួយនោះ អាចខ្ញុំទៅជួយហើយ ក៏ប៉ុន្តែគ្មានៗបាទ។

**ស៖** បាទ ចុះពេលនោះ លោកពូទៅកន្លែងណាទៀត?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ ៗ!

**លោក ហ៊ីម ម៉ាន៖**

**ឆ៖** ដល់ពេលខ្ញុំចុះមកវិញ ខ្ញុំមករះមកផ្ទះតាជីប ដើររះមកខាងលិច ឡើងគ្រប់ផ្ទះអ៊ីចឹង ឡើងគ្រប់ផ្ទះទៅមើលពួកមូស្លីមខ្ញុំនៅប៉ុន្មានគ្រួសារ។ បានដឹងថា អស់ៗ នៅបង្អើយផ្ទះតាជីប រួចផ្ទះតាជីបហ្នឹង ខ្ញុំក៏ឡើងផ្ទះតាជីបទៅ អត់ឃើញមនុស្សសោះ។ មានអីខ្ញុំចុះមកវិញ ខ្ញុំមកស្រែកយំនៅមុខផ្ទះតាជីប យំហើយបានថា ខ្ញុំនឹកក្នុងចិត្តថា អស់ហើយភូមិ បងប្អូនខ្ញុំនៅភូមិចាមនេះ។ អស់យប់ហ្នឹងហើយនៅសល់តែខ្ញុំជាមួយប្រពន្ធខ្ញុំ ហើយជីដូនមួយខ្ញុំដែលរត់ទៅកោះប៉ុណ្ណឹង។ ខ្ញុំថាអស់ហើយខ្ញុំយំៗស្រែកហើយ ខ្ញុំលូនមកវិញហ្នឹងទៅជួបប្រពន្ធខ្ញុំម៉ោងបួនៗភ្លឺ គិតទៅខ្ញុំឡើងមកមួយយប់ ទៅដល់ជួបប្រពន្ធខ្ញុំៗ ពិភាក្សាជាមួយប្រពន្ធខ្ញុំហើយ "ហើយយើងទៅខាងណា?" ត្រូវចុះទៅក្នុងបឹង។

[១៣:៤៣:៥២]

បាទ រមៀលចុះទៅក្នុងបឹង ទៅនៅក្នុងបឹងហ្នឹង។ បានក្រោយមកភ្លឺឡើង គេបាញ់ គេទៅបាញ់អាក្នុងកំប្លោកដែលខ្ញុំនៅ។ បាញ់កម្ទេចបន្តក់សេវេនធីណៃ បេ៤០ ហើយអាការស្វាយបត់រះ។ បាទរះក្នុងបឹង សំណាងដែលខ្ញុំមានកំប្លោក ខ្ញុំទូលកំប្លោក ហើយបាញ់ទៅវាត្រូវទឹកវាលោតវិញកាំភ្លើងហ្នឹងវាលោត ប៉ុន្តែគ្រប់កាំភ្លើងបាញ់អាធំហ្នឹង បាញ់វាមិនចំខ្ញុំវាទៅឆ្ងាយ ប៉ុន្តែវាញ័រទ្រូងបឿកៗអ៊ីចឹង។ ប៉ុន្តែខ្ញុំទ្រាំប្រពន្ធខ្ញុំចង់ងើបឡើងវាភ័យខ្លួន ចុះវាភ័យខ្លួន ខ្ញុំក៏ចាប់សក់វាក្រវី។ កុំងើប តែងើបងាប់ហើយវាមិនអាណិតអូនឯងថា អ្ហូ! ងើបមកអញខ្លាចហើយ អីហើយ គ្មានទេ គ្មានពេលអាណិតទេ។ ងើបកាលណាងាប់ពេលនុ៎ង។ ខ្ញុំ -- វាក៏យល់ស្រប។ វាបាញ់នេះ ខ្ញុំប្រាប់ប្រពន្ធខ្ញុំថា បាញ់នេះមិនមែនបាញ់ហ្សឺបទេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាញ់គូប្រកួត បាញ់រះ បាញ់ស្មានអត់មានឃើញចំណុចណាទេ បាញ់នេះបាទ។ បាទ អ៊ីចឹងប្រពន្ធខ្ញុំក៏តាមខ្ញុំ។

**ស៖** បាទ អរគុណ។ ចាតើរស់នៅៗក្នុងបឹងហ្នឹងប៉ុន្មានថ្ងៃប៉ុន្មានខែទៅ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ។

**លោក ហ៊ឹម ម៉ាន៖**

**ឆ៖** ខ្ញុំរស់នៅៗបានប្រាំបីថ្ងៃ ប្រហែលជាប្រាំបីថ្ងៃហ្នឹងខ្ញុំ ព្រោះវាឃ្លានខ្លាំងអស់មានបាយទេ ហើយខ្ញុំមើលដែលវាដាច់ៗហ្នឹងមានស្នាមកណ្ដុរវាស៊ីអាឫសកំប្លោកហ្នឹង ខ្ញុំក៏អ្នកអត់បាយហ្នឹងស៊ីអីវិញ បើអត់មានបាយ--

[១៣:៤៥:៤៣]

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ឈប់ៗ ខ្ញុំចង់បញ្ជាក់ចាត្រង់ចាតើរស់នៅក្នុងបឹងហ្នឹងប៉ុន្មានថ្ងៃប៉ុន្មានខែនៅទីនោះ? ហើយអម្បាញ់មិញឮថាប្រាំបីថ្ងៃ?

**ឆ៖** ប្រាំបីថ្ងៃខ្ញុំចារត់ទៅដំបូងទេ ប្រាំបីថ្ងៃហ្នឹង ព្រោះខ្ញុំតាមដានទៅឃើញកណ្ដុរហ្នឹងវាស៊ីគល់កំប្លោកហ្នឹង ខ្ញុំក៏ស៊ីតាមកណ្ដុរ ខ្លួនខ្ញុំចុះក្នុងបឹង ទៅនៅក្នុងបឹង មានន័យថាខ្ញុំកណ្ដុរដែរ អ៊ីចឹងស៊ីតាមកណ្ដុរបានរស់មានជីវិតទាល់តឡូវនេះមក។ អត់មានស្រូវអង្ករស៊ីទេ ព្រោះស៊ីអន្ទង់ឆៅ តាំងពីកង្កែប តាំងពីអីក្ដាម ខ្យង រុក្ខជាតិតាមហ្នឹងខ្ញុំស៊ីទាំងអស់ បាទ ខ្ញុំបានស៊ីទាំងអស់។ បានថាខ្ញុំលាមកខ្ញុំ ដូចអាចម៍ទន្សាយហ្នឹងមូល ហើយអត់មានក្លិនទេ បាទ គ្មានក្លិនទេ ហើយត្រដាបត្រដួសហើយ--

**ស៖** បាទ អរគុណ។ ចាតើរស់នៅក្នុងទីនោះអត់អីហូបអ៊ីចឹង ចុះខ្លួនប្រាណអី ពេលយប់រស់នៅយ៉ាងម៉េច? ពេលថ្ងៃរស់នៅយ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗលោកៗម៉ាន!

**លោក ហ៊ឹម ម៉ាន៖**

**ឆ៖**ខ្ញុំរស់នៅក្នុងកំប្លោកហ្នឹងពេលយប់ ខ្ញុំឡើងយកដើមទ្រាស ខ្ញុំដឹកដើមទ្រាសដែលនៅក្នុងបឹង

ហ្នឹង ទាញៗមកខ្ញុំដេកលើហ្នឹងៗ និយាយពីពស់ខាងក្រោមពស់ៗកន្លែងសំបុកពស់ ឲ្យតែភ្លឺឡើងម៉ោងបួន ខ្ញុំក្រវាត់ដើមឈើហ្នឹងឡើងវិញ កុំឲ្យអ្នកមកព័ទ្ធហ្នឹងឃើញមនុស្ស ឃើញកាច់ដើមឈើអ៊ីចឹងថាមនុស្សនៅហ្នឹង អ៊ីចឹងខ្ញុំវាត់ដើមឈើហ្នឹងឲ្យឈរៗឡើងវិញ ដូចជាដើមឈើរស់ អត់មានមនុស្សទេ អត់មានភស្តុតាង ខ្ញុំមុជទៅក្នុងកំប្លោកវិញក្នុងបឹងហ្នឹង ក្នុងទឹក បន្ថែមយកកំប្លោកដាក់ពីលើ ទាល់ៗល្ងាចម៉ោងបួនបានខ្ញុំចេញពីព្រោះពស់វារេរី វាកែនឲ្យអ្នកភូមិប្រាំភូមិ ទៅជាន់កំប្លោកហ្នឹង ទៅរើកំប្លោកដាក់មកដុំៗ។ រើមួយដុំយកដាក់ខាងនេះ ខ្ញុំរុលទៅ ខ្ញុំមុជទៅម្តុំដែលរើដាក់ម្តុំនោះទៀត។ ជួនកាលវារើរួច វាមកអង្គុយលើហ្នឹងទៀត វានៅពីលើខ្ញុំក៏មានដែរ។ រឿងនេះវា វេទនាខ្លាំងណាស់។

[១៣:៤៨:២៣]

**ស៖** បាទខ្ញុំសូមកាត់បន្តិច។ ថាតើពេលដែលនៅទីនោះហើយ នៅពេលណាដែលចេញៗពីកន្លែងនោះទៅវិញ?

**ឆ៖** ពេលដែលខ្ញុំចេញមកវិញហ្នឹង ទាល់តែទឹកហ្នឹងវាឡើង វាឡើងកម្ពស់ជើងខ្ញុំផុតពីទឹក ហើយខ្ញុំផុតពីទឹកខ្ញុំធ្វើម៉េច វរៗលង់ទឹកហើយ ខ្ញុំយកកំប្លោកដាក់កណ្តាលទ្រូងៗឲ្យអណ្តែត ប្រពន្ធខ្ញុំក៏អ៊ីចឹងដែរ ហើយខ្ញុំយកកំប្លោកហ្នឹងដាក់ពីលើក្បាលទៀត សំងំដូចក្រពើអ៊ីចឹង។ ហើយតែសំងំអ៊ីចឹងទៅត្រូវតែទឹកឡើងលិចភូមិមក ខ្ញុំក៏មកយប់ហ្នឹង មកដល់ខាងឃើញល្ហុងមួយ ឡើងមួយដើម រួចវាឃ្លាននេះអត់បាយៗ ៣ខែ ២៩ថ្ងៃ ខ្ញុំមកប៉ះល្ហុងមួយដែលខ្ញុំឡើង ល្ហុងមួយដើម រួចខ្ញុំឲ្យប្រពន្ធខ្ញុំឱបល្ហុងឲ្យជាប់ រួចខ្ញុំឡើងបេះល្ហុងបានពីរ ល្ហុងខ្ចីហ្នឹង យកមកស៊ីម្នាក់មួយ។ និយាយពីឆ្ងាញ់ពេលនោះ នៅក្នុងលោកិយនេះគ្មានអីឆ្ងាញ់ជាងល្ហុងខ្ចីទេដែលខ្ញុំអត់បាយ ៣ខែ ២៩ថ្ងៃ ហើយមកបានប្រទះល្ហុងខ្ចីម្នាក់មួយ ខ្ញុំស៊ីទាំងសំបកល្ហុងខ្ចី។ អ៊ីចឹងនៅលើពិភពលោកនេះមានអីឆ្ងាញ់ជាងល្ហុងខ្ចីដែលខ្ញុំមកៗប៉ះនោះទេ ដែលខ្ញុំអត់បាយប៉ុន្មានថ្ងៃហ្នឹងណា៣ខែ ២៩ថ្ងៃ។

**ស៖** បាទ អរគុណ។ ថាតើពូចារស់នៅទីនោះ ៣ខែ ២៩ថ្ងៃ តើមានស្អីដែលជាការកត់សម្គាល់ទេថារាប់ម៉េចបាន ៣ខែ ២៩ថ្ងៃ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗលោកម៉ាន!

**លោក ហ៊ឹម ម៉ាន៖**

**ឆ៖** បានខ្ញុំដឹង ៣ខែ ២៩ថ្ងៃហ្នឹង ថ្ងៃណាក៏ខ្ញុំរាប់ដែរ ខ្ញុំព្យាយាមបាទ ខ្ញុំព្យាយាមរាប់។ បានមួយថ្ងៃខ្ញុំរាប់ៗរាប់ប្រពន្ធខ្ញុំក៏រាប់ ខ្ញុំក៏រាប់ វាឈឺចាប់ រស់មួយថ្ងៃ ដូចរស់មួយឆ្នាំ ដែលវាឈឺចាប់រស់មួយថ្ងៃកន្លែងហ្នឹង ដូចរស់មួយឆ្នាំបាទ វាៗឈឺចាប់ វាៗៗយឺតពេល បាទ។ ហើយខ្ញុំបានរាប់ មិនមែនថាខ្ញុំឡើងមកៗសួរបងប្អូនថា បានប៉ុន្មានថ្ងៃដែលខ្ញុំចេញទៅខ្ញុំឡើងមកវិញ? អត់ទេ ខ្ញុំរាប់ជាមួយប្តីប្រពន្ធខ្ញុំហ្នឹងព្យាយាមរាប់បាទ ហើយវល្លួយអស់ហើយខ្លួនប្រាណហ្នឹងណា ខ្មៅ អត់ប៉ានខ្វេះខ្លាំងទេ រឫតសាច់បាទ។

[១៣:៥១:៣២]

**លោក ឡៅ ជុនធី៖**

**ស៖** បាទ អរគុណ។ ខ្ញុំសូមត្រឡប់ទៅក្រោយបន្តិចថា ពេលដែលចូលក្នុងភូមិហើយរកកាំភ្លើងអត់ឃើញហើយហ្នឹង ចង់ត្រឡប់ថាតើបងប្អូនដែលគេនាំក្នុងហ្វូងហ្នឹង ដែលបងប្អូនសាច់បង្កើតហ្នឹងមានឈ្មោះអីខ្លះហើយដែលទៅហ្នឹង?

**ឆ៖** អាម៉ាត់កាម៉ែលមួយ ហើយម្តាយខ្ញុំ ហើយឡាប់លី, អាំមីណាស់, ហើយតូនី ហើយហ៊ីម -- អ៊ីប្រាហ៊ីម ហើយកះរ៉ាំ ហើយបងប្អូនឯទៀតៗដែលខ្ញុំធ្លាប់រាប់អានគ្នាសាច់លោហិតហ្នឹងអស់ហើយបាទ មិនមែនឈឺចាប់តែបងប្អូនខ្ញុំសាច់សាលោហិតទេ អ្នកផងទាំងអស់ខ្ញុំឈឺចាប់ទាំងអស់ហ្នឹង ប៉ុន្តែមិនដឹងធ្វើម៉េចបាទ បើខ្ញុំគ្មានលទ្ធភាពជួយ បើខ្ញុំមានលទ្ធភាពជួយខ្ញុំជួយបានហើយ ប៉ុន្តែខ្ញុំអត់ ជួយអត់បានទេ។

**ស៖** អរគុណលោកពូ ហើយមួយសំណួរទៀតដែលចុងក្រោយរបស់ខ្ញុំថា តើលោកពូមានស្គាល់ឈ្មោះឈ្លបនៅទីនោះទេ អាចរៀបរាប់ឈ្មោះបានទេ?

**ឆ៖** ខ្ញុំស្គាល់ខ្លះ ព្រោះខ្ញុំអាល័យជីវិតខ្ញុំ ខ្ញុំបានក្រឡេកមកស្គាល់ខ្លះអ្នកហ្នឹងបាទ។ អ្នកហ្នឹងឈ្មោះ យុង មួយដែលអ្នកក្រុមដាវវែង។ ហើយឈ្មោះ ចឹក មួយ, ហើយក្រៅពីហ្នឹង ឃើញច្រើនណាស់ ប៉ុន្តែខ្ញុំឃើញដែលច្បាស់ៗពីរនាក់ហ្នឹងដែលខ្ញុំឃើញ ប៉ុន្តែមានច្រើនណាស់ បាទ មានច្រើនណាស់ៗដែលមកប្រមូលទៅហ្នឹងបាទ។ ហើយខ្ញុំមិនបានចាប់ភ្លឹកថាឈ្មោះនេះ ឈ្មោះនោះទេ ព្រោះខ្ញុំអាល័យជីវិតខ្ញុំនេះនៅចុងសក់នេះបាទ ខ្ញុំចេះតែរត់យកជីវិត គ្រាន់តែក្រឡេកមួយភ្លែតហ្នឹង វាឃើញប៉ុណ្ណឹងជិតច្បាស់ពីរនាក់ហ្នឹងច្បាស់ហ្នង ចឹក, យុង បាទ ឃើញច្បាស់ ហើយមិនដឹងនៅទីណាទេ។

**ស៖** បាទ អរគុណ។ លោកពូស្គាល់ឈ្មោះ ឌឿន ដែរ?

**ឆ៖** ឡើនៗមួយដែរ អាឡើន មិនដឹងនៅទីណាទេ។

**លោក ឡោ ជុនធី៖**

បាទ អរគុណលោកប្រធាន ខ្ញុំសុំផ្ទេរវេទិកាទៅមេធាវីអន្តរជាតិ។ សូមអរគុណ។

[១៣:៥៥:១៤]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណសហភាតារបស់ខ្ញុំ។ សូមគោរពលោក លោកស្រី ចៅក្រម។ ជម្រាបសួរភាគីទាំងអស់ ជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំសួរសំណួរមួយចំនួនដើម្បីឲ្យលោកបន្តរឿងរ៉ាវរបស់លោកតទៅទៀត។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ឥឡូវនេះ ខ្ញុំចាប់ផ្ដើមនិយាយនៅពេលដែលលោកនៅក្នុងស្រះ ហើយលោកលាក់ខ្លួនជាមួយនឹងប្រពន្ធរបស់លោក។ ខ្ញុំចង់ដឹងថា តើលោកនៅក្នុងស្រះហ្នឹងអស់រយៈពេលប៉ុន្មាន? លោកៗឆ្លើយថា ៣ខែ ២៩ថ្ងៃ ហើយលោកបានរាប់ថ្ងៃហ្នឹង មួយថ្ងៃៗ។ អ៊ីចឹងទៅខ្ញុំយល់អ៊ីចឹងត្រូវទេ ថាលោកនៅក្នុងហ្នឹងពិតជាអស់ ៣ខែ ២៩ថ្ងៃ?

**លោក ហ៊ឹម ម៉ាន៖**

**ឆ៖** ខ្ញុំរាប់ហ្នឹង ខ្ញុំរាប់ប្រាកដរបស់ខ្ញុំមែន។ ខ្ញុំមិនមែនទៅសួរបងប្អូនទេ ហើយខ្ញុំនៅប្រាកដណាស់ដែលខ្ញុំរស់នៅ ៣ខែ ២៩ថ្ងៃនេះ។ ខ្ញុំបានជារស់នៅដល់សព្វថ្ងៃដោយសារខ្ញុំបានហូបរុក្ខជាតិតាមហ្នឹងទាំងអស់ អន្ទង់បានមួយដែលក្នុងរយៈ ៣ខែ ២៩ថ្ងៃ បានអន្ទង់មួយប៉ុណ្ណោះ។ យកមកកាច់ជាពីរ ខ្ញុំស៊ីជាមួយប្រពន្ធខ្ញុំ ស៊ីអត់កើត ខ្ញុំយកពោះវៀនវាស៊ីៗ ខ្ញុំលេបទោះបីថាឆ្អាបយ៉ាងម៉េចក៏ខ្ញុំលេបដែរ។ តែលេបទៅវាប្រុងក្អួតមកវិញ ក្អួតអត់មកទេ ព្រោះក្រពះវាទទេ។ ហើយខ្ញុំបានរស់ហ្នឹង រឿងអីរស់មកដល់សព្វថ្ងៃ ដោយសារខ្ញុំបានរុក្ខជាតិទាំងអស់ហ្នឹងហើយ បានផ្សិតល្អិតៗហ្នឹង ដែលបានហ្នឹងហើយ ស៊ី ខ្ចៅខ្ចង ហ្នឹង ចាប់ទំពាៗ ត្រីហ្នឹង យូរៗបានមួយទៅ បាទ ចាប់នៅគុម្ពកំប្លោកបានទៅ ស៊ីទៅ ម្នាក់ មួយកំណាត់ទៅ ស៊ីអត់មានភ្លើងទេ ស៊ីដូចសត្វកណ្ដុរអ៊ីចឹង។ បាទ ខ្ញុំបានអាហ្នឹងហើយ។ បើសិនជា អត់មានអីស៊ីសោះ អត់មានរុក្ខជាតិសោះ ខ្ញុំមិនទ្រាំបាន ៣ខែ ២៩ថ្ងៃនោះ ទេ ខ្ញុំងាប់ហើយ។ បាទ ប៉ុណ្ណឹងខ្ញុំមិនរស់នៅផង។

[១៣:៥៧:៣៤]

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោករៀបរាប់អំពីរបៀបដែលជនជាតិចាមត្រូវបានគេប្រមូលផ្តុំ និងនាំទៅកាន់រណ្តៅ។ នេះជាចម្លើយរបស់លោកអម្បាញ់មិញនេះ។ ខ្ញុំចង់ដឹងថា ពីស្រះដែលលោកលាក់ខ្លួនហ្នឹង ហើយទៅដល់រណ្តៅហ្នឹងមានចម្ងាយប៉ុន្មានម៉ែត្រដែរ?

**ឆ៖** ពីស្រះដែលខ្ញុំលាក់ខ្លួន អ៊ូ! ខ្ញុំសុំសួរលោកតុលាការថា ពីស្រះដែលខ្ញុំពួនហ្នឹង? វាមានច្រឡំពីរ មានមួយហ្នឹងភ្លឺស្រែ មួយហ្នឹងស្រះ។ ចម្ងាយដូចគ្នាទេ ប្រហែលជា២០០ម៉ែត្រ ក្នុងស្រះ ខ្ញុំពួនហ្នឹង។ បើស្រះខ្ញុំពួនមិនទាន់ដល់ក្នុងបឹង អាហ្នឹងប្រហែលជា១០០ម៉ែត្រទេ។ រួចបើស្រះ ខ្ញុំពួនហ្នឹងប្រហែលជា២០០ម៉ែត្រ ខ្ញុំសុំស្មានដែរទេ ប៉ុន្តែស្រះខ្ញុំលោតដែលហ្នឹង ស្មានដែរ ២០០ម៉ែត្រ ខ្ញុំស្មានដែរ។ បាទ ខ្ញុំស្មានទេ ខ្ញុំអត់បានទៅវាស់ទេ ហើយខ្ញុំលោតយ៉ាងម៉េច ឲ្យតែរួចជីវិតខ្ញុំប៉ុណ្ណឹងទេ។ ប៉ុន្តែតែឮច្បាស់ ឮ រួចធុំស្អុយ ស្អុយហ្នឹងធ្លាប់អស់រលីង ស្អុយហ្នឹង។ ស្អុយហ្នឹងបើសិនជាអណ្តែតមកខ្ញុំ មនុស្សហ្នឹងអណ្តែតមកខ្ញុំ ខ្ញុំអាចហូបអស់ ដែលខ្ញុំឃ្លានណាអស់លោក បាទ ខ្ញុំឃ្លានណាស់។ ស្អុយហ្នឹង វាត្រឡប់ទៅជាធុំក្រអូប។ បើសិនជាមនុស្សហ្នឹងអណ្តែតមក ខ្ញុំហែកស៊ីអស់ ដែលខ្ញុំឃ្លាន។ ខ្ញុំអត់បាយ ៣ខែ ២៩ថ្ងៃហ្នឹងណា សំណាងដែរវាអត់អណ្តែតមកខ្ញុំ។ បើអណ្តែតមកខ្ញុំ ខ្ញុំប្រុងជាមួយប្រពន្ធខ្ញុំយើង បែបបានមនុស្ស មួយពីរអណ្តែតមកហ្នឹង ស៊ីដែរហ្នឹងស៊ីដែរ? ប្រពន្ធខ្ញុំថាស៊ី ខ្ញុំក៏ស៊ីដែរ។ ព្រោះវាអត់ធុំ ស្អុយ វាធុំប្រហើរក្រអូប ដែលចំហាយពីរណ្តៅម៉ែឪខ្ញុំដែលងាប់នោះ វានៅក្បែរ បាទ វានៅក្បែររួចថា ធុំមកចេះតែដកដង្ហើមធំៗ ដកដង្ហើមវែងៗ ដើម្បីស្រូបយកក្លិនស្អុយហ្នឹង រួចម៉េចក៏វាទៅប្លែក ខ្ញុំឆ្ងល់ ខ្លួនខ្ញុំក៏ខ្ញុំរាល់ថ្ងៃក៏ឆ្ងល់។ មនុស្សស្អុយ ស្អុយណាស់ណា ហើយចុះយ៉ាងម៉េចក៏ហិតក្លិនវែងៗ ដើម្បីឲ្យ--វាក្រអូបៗទៅវិញ បាទៗ ប៉ុណ្ណឹង។ ខ្ញុំវាជាក់ស្តែងហើយខ្ញុំនេះអត់មាននិពន្ធរឿងទេ អស់លោកអើយអត់មាននិពន្ធរឿងទេ។រឿងខ្ញុំឆ្លងកាត់ វាក្លាយទៅជាក្រអូបអស់ ស្អុយទៅជាក្រអូប ដកដង្ហើមវែងៗដើម្បី --អត់បាយខ្ញុំម៉េចបានស៊ី?បានស៊ីឯណា បើវានៅក្នុងរណ្តៅឯណោះ វាផុសពីដីមកវាស្អុយតែម្តង វានៅក្បែរហ្នឹង។ បាទ ប៉ុណ្ណឹង។

[១៤:00:៥១]

**ស៖** តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះបានទេថាហេតុអីបានជាលោកអាចចេញពីស្រះ? ហើយពេលដែលចេញហើយហ្នឹងលោកទៅណាទៀត?

**ឆ៖** ខ្ញុំចេញពីស្រះទៅវិញហ្នឹង ឡើងមកប្រុងទៅៗកន្លែងណាដែលសុខ បាទ ខ្លួនខ្ញុំៗប្រុងទៅវៀតណាមណោះ។ រួចទៅវៀតណាមធ្វើម៉េច បើស្គមប៉ុណ្ណឹងទៅវៀតណាម? ខ្ញុំគិតខ្លួនខ្ញុំរួចឡើងពីបឹង

មកហ្នឹង។ ខ្ញុំទៅ ព្រោះទឹកវាឡើងពេញអស់ហើយ ខ្ញុំទៅតាមកំប្លោក ខ្ញុំព្រលឹមកំប្លោក ឲ្យកំប្លោកវាអណ្តែតមកតាមទន្លេមក តាមទន្លេមក វាចូលអ្នកលឿងអ្នកអីទៅៗ ទាំងកំប្លោកមកទូកអត់រួច ខ្ញុំគិតរួចនៅក្នុងបឹងបានខ្ញុំមក។ មកវាអត់រួច វាមកគុម្ពឫស្សី គុម្ពឫស្សីពួកហ្នឹងទៅដេញកណ្តុរព័ទ្ធខ្ញុំ ដំបងដាក់ខ្ញុំបឿកៗ ចាប់ខ្ញុំយកមកដាក់ជម្រុកពោត គេហៅគុក។ បាទ គុកហើយជម្រុកពោតហើយ ព្រោះៗពួកដាវវែងនៅយាមខ្ញុំចាប់ខ្ញុំយកដាក់ក្នុងជម្រុកពោតហ្នឹង ពួកវានៅពីក្រោម ខ្ញុំនៅពីលើណោះ ដែលបាំងជិត។ ចាប់នេះប្រាប់គេថា ដល់ម៉ោងគេយកទៅសម្លាប់នៅវណ្តៅវត្តអូរត្រកួន គ្រាន់តែចាប់សម្រាកសិន ។រួចដល់អ៊ីចឹងទៅនៅមួយសន្ទុះអ៊ីចឹងទៅ ខ្ញុំហ្នឹងវាប្លែក ឲ្យសញ្ញាប្លែក។ ព្រស្រីប រួចដល់ស្រីបទៅវារីកៗអាទ្រូងនេះ បើនៅស្គម ខ្ញុំសម្បុរខ្មៅ រួចវារីកទ្រូងនេះ ក៏ខ្ញុំវាស់អង្កាល់ហ្នឹង ប្រហែលជាប្រាំពីរៗហត្ថទ្រូងខ្ញុំនេះ ហើយជើងខ្ញុំប៉ុណ្ណេះៗ ខ្ញុំយារទាត់ជម្រុកជ្រូកមួយហ្នឹង ខ្ញុំថាចូលខ្ញុំទាត់មួយជើងហើរ។ បាទខ្ញុំយារទាត់ទៅ ព្រស្រីបមករិ ស្រីបមកវិញមើលខ្លួនឯងស្គម អត់ហ៊ានទាត់។ ខ្ញុំនៅទៅទៀតហ្នឹងបានៗបងប្អូនហ្នឹងគេទៅពិភាក្សាជាមួយ កាន ថា ឲ្យទុកខ្ញុំ ខ្ញុំគ្មានទៅទាក់ទងជាមួយពីណាទៀត នៅរស់នៅក្នុងថ្លុកបឹងបានគេឲ្យខ្ញុំរស់។ ហើយអាប៉ិកចៅហ្វាយស្រុក កាន ហ្នឹង បាទ វាថា "រួចអ៊ីចឹងកុំសម្លាប់ វាមនុស្សហ្នឹងវាអស់ហើយ នៅសល់ចាមពីរទៅឲ្យវានៅទៅ។ នៅទៅ ពីព្រោះពួកហ្នឹងវាចេះមុជទឹកហើយវាចេះរំលាយធ្វើស្រាបព្រា វាចេះរំលាយដែក"។ ពួកហ្នឹងក៏ឯកភាពឲ្យខ្ញុំនៅ។តាមចៅហ្វាយស្រុកកាន ហ្នឹងវាថាឲ្យទុកទៅម្នាក់នេះគ្មានទាក់ទងពីណាទេ វាៗដឹងថាខ្ញុំអត់មានទៅណា នៅក្នុងថ្លុកក្របីហ្នឹង ក្នុងបឹងហ្នឹង។ អ៊ីចឹងវាឲ្យខ្ញុំរស់ ដោយសារតែខ្ញុំចេះមុជទឹកៗបាតទន្លេនេះ ដោះមងលីងត្រីទៅក៏វាអស់ហើយចាមៗអ្នកមុជទឹកអស់ហើយនៅសល់តែខ្ញុំម្នាក់ទេ។ អ៊ីចឹងវាទុកខ្ញុំ ហើយអ្នករំលាយដែកហ្នឹងធ្វើស្លាបព្រា ធ្វើផាលអី ខ្ញុំអ្នករំលាយដែក។ ហើយវាទុកទៅ បានខ្ញុំរស់ដល់សព្វថ្ងៃហ្នឹង។ បាទ ព្រោះនៅទៀត។ មានរឿងរ៉ាវដែលត្រូវរស់ហ្នឹងនេះច្រើនណាស់ ខ្ញុំហ្នឹង។ វាទុកដោយសារខ្ញុំចេះមុជទឹក ចេះស្លដែកធ្វើស្លាបព្រា ធ្វើអីឲ្យវាប្រើហ្នឹង។ អស់ហើយ។

[១៤:០៤:៣៥]

**ស៖** សូមអរគុណ។ តើជង្រុកហ្នឹងស្ថិតនៅក្នុងភូមិកំណើតរបស់លោកហ្នឹង ភូមិសាច់ស្ងួហ្នឹង មែនទេ? អ៊ីចឹងមានន័យថា ពេលដែលលោកចេញពីកន្លែងលាក់ខ្លួននៅក្នុងបឹងហ្នឹងហើយ លោកទៅភូមិកំណើតរបស់លោកគឺភូមិសាច់ស្ងួហ្នឹង មែនទេ?

**ឆ៖** បាទ ហើយវាចាប់ខ្ញុំពីភូមិសាច់ស្ងួហ្នឹង នៅៗគុម្ពឫស្សីហ្នឹង នៅភូមិសាច់ស្ងួហ្នឹងទេ។

ហើយបញ្ជូនមកសំបួរមាស ជង្រុកពោតហ្នឹងនៅកន្លែងសំបួរមាស បាទ នៅសំបួរមាស។ ជង្រុកពោតហ្នឹង គេសម្រាប់តែ ដូចគោ គេយកមកដាក់នង្គ័លទម្រាំតែដល់តែដល់ម៉ោងគេយកទៅសម្លាប់ប៉ុណ្ណឹងទេ ព្រោះខ្ញុំក៏អស់សង្ឃឹម។

**សៈ** ពេលដែលលោកចេញពីជង្រុកពោតហ្នឹង លោកទៅភូមិណាទៀត?

**ឆៈ**នៅជង្រុកពោតហ្នឹង វាឲ្យខ្ញុំរស់ ១ខ្ញុំនៅក្បែរៗជង្រុកពោតហ្នឹង។ វាឲ្យចាំការពារជង្រុកពោត វាឲ្យខ្ញុំរស់ វាបញ្ជាឲ្យយកបាយមកឲ្យខ្ញុំស៊ី ស៊ីមានបងប្អូនហ្នឹងនៅយាមកុំឲ្យខ្ញុំស៊ីច្រើន តែស៊ីច្រើនទៅក្រែងលោវាងាប់កន្លែងហ្នឹងទៅ។ វាយាម វាឲ្យរស់ហើយ បើស៊ីទៅវាលើម៉ាកេអ៊ីចឹងទៅហ្នឹងងាប់ហ្នឹងវាយាម បាយហ្នឹងវាឲ្យស៊ីបន្តិចៗ បែបវាឲ្យខ្ញុំរស់ហើយ រួចខ្ញុំក៏ស៊ីតាមវាទៅបាទ។ ស៊ីតាមវាទៅ ក៏បានពីរបីខែ១វាជួយគេហៅថា ដាំបាយឲ្យខ្ញុំស៊ីអ៊ីចឹងទៅ ហើយមើលខុសត្រូវខ្ញុំបានពីរខែបីខែ ពីរបីខែប៉ុណ្ណឹង។ លោថាពួដំណឹងមកម្តងទៀតហើយ ថាចាមនៅសល់ពីរនាក់ ពួអ្នកភូមិថាចាមនៅសល់ពីរនាក់ ប៉ុន្តែចាមសល់ពីរនាក់ទេ។ អ្នកភូមិក៏ស្រលាញ់ខ្ញុំដែរ អ្នកភូមិហ្នឹងដាក់ឈ្មោះខ្ញុំឲ្យបាត់ចាមឲ្យអស់បំបាត់ចាមឲ្យអស់។ ឈ្មោះខ្ញុំដាក់ អាលីម ប្រពន្ធខ្ញុំដាក់ មីណា។ លីម ប្រពន្ធខ្ញុំដាក់មីណា ដើម្បីថាចាមអស់ហើយ។បាទ រួចដល់អ៊ីចឹងទៅ។ ដល់ពេលវាសម្រេចផែនការថា ពួថា ពួមកម្តងទៀតថាចចាមអាវ៉ាមនៅភូមិហ្នឹង "ថា អេ្ហ! ចាមនៅសល់ម្នាក់។ គេសម្លាប់ម្តងទៀត ទាំងខ្មែរទាំងចាមតែម្តងយកទៅទាំងអស់ៗ ហើយខ្ញុំអ្នកតែកុងកាណូត។ វាឲ្យខ្ញុំបញ្ជាកាណូតដាក់ចាស់ៗ អាក្មេងៗហ្នឹងដើរទៅតម្រង់ទៅរណ្តៅវាយប៉ាយ។ វាយប៉ាយ នៅវាយប៉ាយហ្នឹង ពាមជីកងនេះទេ កាលនោះនៅស្រុកពាមជីកង ដែរ អ៎! ស្រុកកងមាសដែរ។ ហ្នឹងរណ្តៅវាយប៉ាយ។ ហើយដល់ខ្ញុំនេះ ខ្ញុំធ្វើល្បិចខ្ញុំ ដល់ពេលម៉ាស៊ីនហ្នឹងខ្ញុំបើកទៅម៉ាស៊ីនវាខូច ពួកខ្មែរក្រហម "ម៉េចក៏បងឯងមិនធ្វើម៉ាស៊ីនហ្នឹង?" ឲ្យធ្វើម៉េច ខ្ញុំមិនមែនអ្នកជាងម៉ាស៊ីនឯណាខ្ញុំមិនចេះធ្វើផង។ ប៉ុន្តែតាមការពិតម៉ាស៊ីនហ្នឹង វាគ្រាន់តែចូលខ្យល់តាមកូនជ្រូក ប៉ុន្តែខ្ញុំធ្វើជាល្ងង់ដើម្បីព្រងើយកន្តើយដើម្បីរស់មនុស្សមួយទូកហ្នឹងទាំងពួកទាហានអីនៅក្នុងហ្នឹង ហើយពួកទាហានហ្នឹង ពួកវាការពារពួកចាស់ៗដែលយកទៅសម្លាប់ក្នុងបឹងហ្នឹង។រួចខ្ញុំរកគន្លឹះ ខ្ញុំមិនមែនជាងទេ ម៉ាស៊ីនហ្នឹងវាខូច វាចូលខ្យល់ វាខូចអីវាចូលខ្យល់។ ខ្ញុំអត់ចេះធ្វើទេ។ ដល់អត់ចេះធ្វើទេ នៅប្រតេកពេលអ៊ីចឹងទៅ ទាល់តែវៀតណាមវាយផ្តាច់ភ្នំពេញ បែកភ្នំពេញទៅ រថក្រោះទៅតាមផ្លូវលេខ៧ ទៅវាបែកអស់ អ៊ីចឹងពួកហ្នឹងលោតពីក្នុងទឹកទៅ ខ្ញុំរស់ទាំងអស់មួយទូកហ្នឹង បានបងប្អូនខ្មែរនៅរស់ទាំងអស់មួយទូកបាទ។ ពួកអាវាយប៉ាយហ្នឹងលែងយកទៅកប់ហើយ ច្រាលមកវិញអស់ អាទៅរណ្តៅនុំងមកពី

ស្រុកៗណាទៅជីកនៅរណ្ដៅនៅវាយប៉ាយហ្នឹង។ រួចម្ដងនេះ ខ្មែរ-ចាមត្រូវតែងាប់ទាំងអស់។ ទីបញ្ចប់ត្រូវងាប់។ នៅសល់រណ្ដៅខ្ញុំ សាច់ស្ងួហ្នឹងមួយដែរ សម្រាប់ដាក់ខ្មែរ។ រណ្ដៅហ្នឹងគ្រាន់តែ ៥០ម៉ែត្របួនជ្រុង មិនទាន់កប់មនុស្សទេ យួនវ៉ៃភ្នំពេញបាន អត់មានកប់មនុស្សទេ។ អត់ទាន់កប់បានទេ រណ្ដៅនៅភូមិសាច់ស្ងួ។ ឥឡូវនេះ គេដាំស្វាយអស់ហើយ គេជីកៗ វាឲ្យមនុស្សទៅជីកៗទៅ១០០ -- ៥០ម៉ែត្របួនជ្រុង។ ខ្ញុំស្មានទេ សម្រាប់ដាក់កូនខ្មែរ។ ថ្ងៃមុនវាថា មានតែខ្មែរមួយទេ បាត់ចាម រួចឥឡូវនេះវាសម្រេចខ្មែរ វាជីករណ្ដៅដាក់ខ្មែរ បើចាមងាប់អស់ហើយវាជីករណ្ដៅដាក់ខ្មែរទៀត។ មិនទាន់កប់អីណា អ្នកតស៊ូមកជួយ អ្នកដែលមានបុណ្យមកជួយ បានខ្មែររស់នៅទាល់សព្វថ្ងៃហ្នឹងទៅ។ឃើញរណ្ដៅធំៗណាស់សាក្រោយនេះ រណ្ដៅធំៗណាស់ រណ្ដៅប៉ុនបាតស្រះ អត់ទាន់កប់ទេ។ ទាល់តែអ្នកមានបុណ្យមកជួយហ្នឹង បានរួចខ្លួនរស់ទាំងអស់គ្នា ខ្ញុំឮចចាមអារ៉ាមដែរទេ ឃើញជីកក្រោយហ្នឹងងាប់ចាមអស់ហើយនៅភូមិសាច់ស្ងួហ្នឹង ជីកក្រោយហ្នឹង ងាប់ចាមហ្នឹង -- ជីករណ្ដៅធំម្ល៉េះ។ វាលាក់ការណ៍ជិតបានក្រោយមកវាយកខ្ញុំទៅវាយប៉ាយហើយតើរណ្ដៅវាយប៉ាយ តំបន់ហ្នឹងជីករួចហើយ ហែពួកខ្ញុំទៅហ្នឹង។ និយាយទៅសាដានមកវិញ ចង់និយាយសាដើមដដែលហ្នឹង

វាសាហាវពេកបាទ ព្រោះរឿងរបស់ខ្ញុំនេះ អត់មានរឿងនិពន្ធទេ បើខ្ញុំមាននិពន្ធអី ខ្ញុំភ្លេចអស់ហើយ។

[១៤:១១:១០]

**ស៖** សូមអរគុណលោក។ ខ្ញុំមានសំណួរចុងក្រោយដើម្បីសួរលោក បន្ទាប់មកខ្ញុំនឹងប្រគល់វេទិកានេះជូនតំណាងសហព្រះរាជអាជ្ញាដើម្បីសួរសំណួរបន្ត ហើយនិងសំណួរសុំការបំភ្លឺពីលោកបន្ថែមទៀត។ លោកបាននិយាយថាលោកបាននៅបើកកាណូតជាមួយនឹង -- ហើយមានដឹកខ្មែរ គឺលោកថាដឹកហ្នឹង ដឹកយកទៅសម្លាប់ចោល។ លោកមានដឹងទេ ថាហេតុអ្វីបានជាលើកទី២ហ្នឹង គេចាប់លោកបន្តទៀត គេមានប្រាប់មូលហេតុទេ ថាហេតុអ្វីបានជាគេចាប់ខ្លួនលោក ហើយឲ្យលោកបើកកាណូតយកទៅ ដើម្បីយកអ្នកផ្សេងទៅសម្លាប់ចោលហ្នឹង?

**ឆ៖** ខ្ញុំនេះ បានបងអ្នកភូមិទេ ព្រោះសម្លាប់ចាមអស់ហើយ ព្រោះខ្ញុំចាមខ្ញុំនៅសល់ម្នាក់ ដែលខាងបច្ចេកទេសខាងទឹក ខាងនេសាទ កាលណាជំពាក់មងខ្ញុំមុជ ជំពាក់មងខ្ញុំមុជ ហើយដល់ខ្ញុំមុជទៅអ្នកមុជហ្នឹងវាអស់ នៅសល់តែខ្ញុំ ហ្នឹងបងប្អូនខ្មែរស្រឡាញ់ខ្ញុំបាទស្រឡាញ់ខ្ញុំឲ្យខ្ញុំរស់ព្រោះខ្ញុំនេះ គេនិយាយថាមិនបានទាក់ទងនៅតែវាតើអាហ្នឹងនៅតែក្នុងៗថ្លុកហ្នឹងទេ អ៊ីចឹងទុកឲ្យវារស់ទៅ។ ដើម្បីខ្ញុំអ្នកបច្ចេកទេស មុជបាតទន្លេនោះ ព្រោះគ្មានអ្នកមុជទេ បាទ គេទុកខ្ញុំកន្លែងហ្នឹង។ រួចដល់ពេលអាសន្ន

ថាយកទៅសម្លាប់នេះខ្ញុំត្រូវតែស្លាប់ដែរទេ បាទ ខ្ញុំត្រូវតែស្លាប់ដែរ ប៉ុន្តែមុនហ្នឹងវាប្រើខ្ញុំ ខ្ញុំស្លាប់ហើយ ប្រើខ្ញុំក្នុងការស្លាប់ហ្នឹងទៀត ឲ្យខ្ញុំបើកកាណូត។ បាទ រួចបើកកាណូត បើកកាណូតយ៉ាងម៉េច បើខ្ញុំដឹងថា ចចាមអារ៉ាមឮថាទៅសម្លាប់នៅវាយប៉ាយឯណោះ រួចខ្ញុំដឹងខ្ញុំខំបើកធ្វើអី ខ្ញុំធ្វើជាកាណូតហ្នឹងចូលខ្យល់ ខ្ញុំថា វាឲ្យខ្ញុំធ្វើខ្ញុំថាអត់ចេះធ្វើ។ ទៅទាល់តែពួកហ្នឹងវាយប្រាវ អ្នកមានបុណ្យមកហ្នឹង អ៊ីចឹងបានពួកហ្នឹងលោត ព្រឹបៗអស់ខ្ញុំរស់ ខ្ញុំបានរំដោះជីវិតខ្មែរចាស់ៗហ្នឹងបានមួយកាណូតដែរ ខ្ញុំបាទ អត់ធ្វើអីទេបាទ។ សុទ្ធខ្មែរចាស់ហ្នឹង គេឲ្យខ្ញុំយកខ្មែរចាស់ៗក្នុងភូមិទៅក្រោយគេបានរស់ទាំងអស់។ រួចបានរស់ហ្នឹង បានអ្នកមានបុណ្យមកទេបើគ្មានអ្នកមានបុណ្យមក ក៏មិនដឹងរស់យ៉ាងម៉េចទេ ឥឡូវបើកទៅណាបើទន្លេប៉ុណ្ណឹង។

[១៤:១៣:៤៧]

**ស៖** អម្បាញ់មិញនេះលោកឆ្លើយថានៅពេលដែលលោកចូលទៅសាច់ស្វូវិញហ្នឹងអត់មានចាមទៀតទេ។ អ៊ីចឹងក្រោយមកទៀតហ្នឹងក្នុងឆ្នាំ៧០ -- ឆ្នាំ៨០ ឆ្នាំ៩០ អ៊ីហ្នឹងលោកធ្លាប់ឃើញចាមដែលធ្លាប់រស់នៅកាលពីសម័យខ្មែរក្រហមនៅសាច់ស្វូហ្នឹង លោកធ្លាប់ឃើញមកវិញទៀតទេនៅក្រោយឆ្នាំ៨០ ឬ៩០អីហ្នឹង?

**ឆ៖** វាបំបែក រួចមានរស់មកខ្លះ ឈ្មោះ តាសង្គ្រាជ សុះ។ តាសង្គ្រាជ សុះ នៅស្រុកខ្ញុំដែរ នៅភូមិជាមួយគ្នាដែលគេជម្លៀសទៅថា មួយរឹកដែលវាជម្លៀសទៅណា ឥឡូវមានរស់មកវិញ ពូជហ្នឹងមក។ ដូចថាតាសង្គ្រាជ សុះ, តាកឹម គាត់នៅទេសព្វថ្ងៃហ្នឹងនោះ បានមកវិញ។ ប៉ុន្តែមកវិញមិនមែនមកគ្រប់ទាំងអស់ទេ បានប្រាកដ ខ្ញុំឃើញគាត់ ឃើញតែតាសុះ ពូជតាសុះ ហ្នឹងម្នាក់ ក្រៅពីហ្នឹងដូច អត់ឃើញបាទ ខ្ញុំអ្នកស្គាល់តើអ្នកផងហ្នឹងព្រោះអត់ឃើញ ប៉ុណ្ណឹង។

**ស៖** អម្បាញ់មិញនេះ លោកនិយាយអំពីរណ្តៅ ហើយលោកបានរៀបរាប់អំពីក្លិនស្អុយចេញពីរណ្តៅនោះ។ ក្រោយពេលវៀតណាមចូលនៅឆ្នាំ៧៩ លោកមានបានឃើញរណ្តៅហ្នឹងទៀតទេ?

**ឆ៖** រណ្តៅហ្នឹងៗរណ្តៅបើតាមនិយាយហ្នឹង ដីភូមិចាមហ្នឹងហើយ ព្រោះបងប្អូនខ្មែរហ្នឹងណាវាទៅចាប់យក វាទៅដាំស្វាយសព្វថ្ងៃហ្នឹងស្វាយ ប៉ុន្តែប្រហែលជាដាំស្វាយហ្នឹងប្រហែលជាទ្រង់ទ្រាយហ្នឹងនៅទេ បើទៅវាស់បានបាទ វាដាំស្វាយ រណ្តៅហ្នឹង។ រួចមិនមែនតិចទេ ៥០ម៉ែត្របួនជ្រុងដំណើរខ្ញុំស្មានទេណា។ មិនមែន -- ក្រោយមកទៀត មិនមែន -- ដឹងវាធ្វើម៉េច ផែនការរបស់គេ ខ្ញុំអត់ដឹង ប៉ុន្តែឮទៅថារណ្តៅទុកដាក់មនុស្សៗ ឮអ្នកភូមិនិយាយតែអ៊ីចឹងៗ។ រួចងាប់ហើយខាងណា*(ឮមិនច្បាស់)*។

[១៤:១៦:៣៥]

**ស៖** សំណួរចុងក្រោយដើម្បីសុំការបំភ្លឺអំពីចំណុចនេះ។ លោកថាមានរណ្ដៅពីរប្រភេទ ដំបូងគេនាំចាមទៅកាន់រណ្ដៅ ហើយលោករៀបរាប់ថាមានក្លិនចេញមកពីរណ្ដៅនោះ បន្ទាប់មកទៀតលោករៀបរាប់រណ្ដៅប្រភេទមួយទៀតដែលសម្រាប់ដាក់ជនជាតិខ្មែរ។ សំណួរខ្ញុំគឺខ្ញុំផ្ដោតទៅលើរណ្ដៅដែលលោកឃើញគេនាំជនជាតិចាមទៅនោះ ខ្ញុំចង់ដឹងថានៅឆ្នាំ៧៩ហ្នឹង លោកឃើញរណ្ដៅហ្នឹងទៀតទេ?

**ឆ៖** រណ្ដៅដែលកប់ជនជាតិចាមនៅវត្តអូរត្រកួនហ្នឹង ខ្ញុំកាលពីមួយរីកប៉ុល ពត ខ្ញុំអត់បានទៅមើលផ្ទាល់ទេ បានឮពីឆ្ងាយទេ ប៉ុន្តែអាពេលចប់នេះ អង្គការអីទេនាំខ្ញុំទៅ ទៅវាស់ៗអត់ដឹងអង្គការអាដហុក ឬមួយអង្គការអីទេ ខ្ញុំអត់ដឹង គេទៅវាស់ ហើយគេៗឲ្យខ្ញុំជូនទៅៗវាស់ខ្ញុំ ឲ្យខ្ញុំកាន់ខ្សែនោះទៀត វាស់រណ្ដៅវត្តអូរត្រកួនហ្នឹង បាទ ឥឡូវនេះវាដាំស្វាយ ដាំៗដូចជាក្រូចអីអស់។ អាខាងកើតហ្នឹងភូមិចាមនោះ អាហ្នឹងមិនទាន់កប់មនុស្សទេ អាហ្នឹងធំជាងគេ បាទមិនទាន់កប់មនុស្សទេ។

**ស៖** តើលោកអាចរៀបរាប់អំពីរណ្ដៅដែលលោកឃើញហ្នឹងបានទេ មានរណ្ដៅច្រើនទេ ហើយក្នុងរណ្ដៅហ្នឹងមានឆ្អឹងទេ មានខោអាវទេ ហើយទំហំប៉ុនណាដែរ លោកអាចរៀបរាប់លម្អិតអំពីរណ្ដៅដែលលោកឃើញហ្នឹងបានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ។

**លោក ហ៊ឹម ម៉ាន៖**

**ឆ៖** ចេះតែភ្លេច ចង់និយាយពេក។ រណ្ដៅហ្នឹងនោះ រណ្ដៅហ្នឹងអត់មានទាន់មនុស្សងាប់ទេ ផែនការវាថ្មីហ្នឹង អត់ទាន់ងាប់ម្នាក់សោះ រណ្ដៅទទេ។ ជីកសម្រាប់ទទេអ៊ីចឹងហ្នង មិនដឹងជាជីកដាក់អីប៉ុន្តែក្រោយមកដឹងថាដាក់មនុស្សៗប៉ុន្តែគ្រាន់ថាឮថាដាក់មនុស្សប៉ុនមិនទាន់អ្នកណាងាប់ទេ។ ងាប់ឯណាបើអ្នកមានគុណវៃកម្ទេចចោលទៅហើយនោះ មកទាន់ហ្នឹង ងាប់ពីណាទៀត។

[១៤:១៩:២៥]

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** នៅឆ្នាំ១៩៧៩ ខ្ញុំនឹងប្រាប់លោកអំពីអ្វីដែលលោកបានឆ្លើយ ហើយតើលោកឆ្លើយប្រាប់ខ្ញុំថាលោកឯកភាពតាម ឬក៏អត់។ ខ្ញុំយោងទៅលើឯកសារលេខ E3/5203, ERN ជាភាសាបារាំង គឺ 00321726, ERN ជាភាសាអង់គ្លេស <0024292091>*(ស៊ីក)*, ជាភាសាខ្មែរគឺ<2092>*(ស៊ីក)*។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកថា “ក្រោយឆ្នាំ៧៩ ខ្ញុំនឹងអ្នកភូមិផ្សេងទៀតបានទៅមើលរណ្តៅ ដែលជីកដោយអ្នកភូមិដើម្បីរកមាស។ នៅទីនោះ មានក្លិនស្អុយ<ខ្លាំង។ មាន>ឆ្អឹង<ជាច្រើន> ប៉ុន្តែអត់មានសាច់ទេ។ សពខ្លះនោះមានខោអាវ សពខ្លះអត់មានខោអាវទេ។” តើលោកចាំនូវរឿងរ៉ាវដែលលោកបានរៀបរាប់នេះទេ គឺក្រោយឆ្នាំ១៩៧៩? បើលោកមិនចាំនោះ គឺមិនអីទេ។

**ឆ៖** ខ្ញុំដឹងត្រឹមប៉ុណ្ណឹង រឿងដែលខ្ញុំឆ្លើយមករួចហ្នឹង។ វាមិនដឹងឆ្អឹងពីណាៗ ប៉ុន្តែខ្ញុំដឹងថា ម៉ែឪខ្ញុំទៅត្រង់ហ្នឹងដែរ។ ដឹងថាទៅគោលដៅត្រង់ហ្នឹងហើយទៅស្តាប់សំឡេងទៀតនោះ ក្រាបស្តាប់សំឡេង។ រួចចុះវាភស្តុតាងដោយសារមនុស្សហ្នឹងទៅអត់ងាប់ហ្នឹង ទៅអត់ងាប់ណា ពួកអ្នកជីកមាសហ្នឹង ជីកសុទ្ធតែឆ្អឹងនៅក្នុងរណ្តៅហ្នឹង។ អ៊ីចឹងខ្ញុំវា ឯកភាពទៅលើពួកហ្នឹងសម្លាប់ម៉ែឪខ្ញុំច្បាស់ណាស់។ បើមិនស្លាប់ហ្នឹងមកវិញហើយ។ បាទ ខ្ញុំដឹងច្បាស់ប៉ុណ្ណឹង។

**លោកស្រី ម៉ារី ហ្គី្ររ៉ូដ៍៖**

សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ ខ្ញុំចង់បញ្ជាក់ថា យើងបានចំណាយពេលលើស ១០ ទៅ១៥នាទីនៃពេលវេលាដែលយើងបានចរចាគ្នាជាមួយសហព្រះរាជអាជ្ញា។ នេះគ្រាន់តែជាការជម្រាបជូនអង្គជំនុំជម្រះប៉ុណ្ណោះ។ សូមអរគុណ។

[១៤:២២:០៤]

**លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ វាំងសង់ ដេ វ៉ាយដ៍។ ខ្ញុំនឹងសួរសំណួរលោកពាក់ព័ន្ធនឹងហេតុការណ៍ដែលបានកើតឡើងនៅមុន និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺរបបខ្មែរក្រហម។ ជាដំបូង ខ្ញុំសុំសួរសំណួរមួយចំនួនពាក់ព័ន្ធនឹងភូមិចាមរបស់លោកគឺភូមិសាច់ស្វ ក្នុងឃុំពាមជីកង។ មុនខ្មែរក្រហមចូលមកដល់ គឺខ្ញុំសំដៅរបបសីហនុ នៅភូមិរបស់លោកហ្នឹងគឺលោកអាចនិយាយភាសាចាមក្នុងចំណោមគ្នាលោកបានមែនទេ?

**លោក ហ៊ីម ម៉ាន៖**

**ឆ៖** មិនដែល -- ដូចជាវាក់ៗអំមិញ សូមអស់លោកបញ្ជាក់ម្តងទៀតមើល៍ ខ្ញុំដូចវាក់មិនចេះ

ឆ្លើយ។

**ស៖** មុនពេលខ្មែរក្រហមចូលទៅដល់ភូមិរបស់លោក តើលោកនិយាយគ្នាជាភាសាចាមមែនទេនៅក្នុងភូមិរបស់លោកដែលជាភូមិចាមនោះ? ហើយលោកចេះភាសាខ្មែរទេនៅពេលនោះ?

**ឆ៖** កាលពេលនោះ ពួកចាមខ្ញុំនិយាយភាសាចាមទាំងអស់ សាសនាមហាម៉ាត់ហ្នឹងនិយាយទាំងអស់បាទ និយាយទាំងអស់ ក្នុងភូមិចាមហ្នឹងនិយាយទាំងអស់ និយាយចាមតែម្តង។ ម្តងម្យាមទេនិយាយជាមួយខ្មែរៗ ម្តងម្យាមទេ ច្រើនតែនិយាយចាមតែម្តងព្រោះសាសន៍គេ គេនិយាយចាម។

**ស៖** ចុះនៅពេលដែលលោកនិយាយភាសាខ្មែរនោះ ខ្មែរដឹងថាលោកជាចាមទេ ពេលដែលលោកនិយាយខ្មែរនោះ លោកនិយាយច្បាស់ទេ លោកនិយាយរដឹនៗ ព្រោះថាខ្មែរនេះមិនមែនជាភាសាកំណើតលោកទេ?

**ឆ៖** រឿងហ្នឹង វាអ្នកទាំងពីរហ្នឹងតុងដូចគ្នា បើខ្មែរនិយាយចាម មានតុងខ្មែរ បើចាមនិយាយខ្មែរមានតុងចាម គេស្តាប់បានតុងចាម ប៉ុន្តែស្តាប់បានថា ស្តាប់បានថាចាម។ អ្ហូ! ខ្មែរនិយាយចាម ចាមនិយាយខ្មែរ វាមានតុងចាម។ និយាយខ្មែរក៏មានតុងចាមដែរ បាទ មានតុងចាម។

**ស៖** នៅក្នុងឃុំរបស់លោកមានភូមិខ្មែរនិងភូមិចាម។ តើជីវភាពប្រចាំថ្ងៃរបស់ជនជាតិចាមនៅក្នុងភូមិចាម និងភូមិខ្មែរហ្នឹងមានភាពខុសគ្នាទេ? លោកមានធ្វើពិធីបុណ្យប្រពៃណី ឬក៏មានអីខុសគ្នាពីភូមិខ្មែរ និងភូមិចាមហ្នឹងទេ?

**ឆ៖** និយាយទៅរឿងធ្វើបុណ្យៗប្រហែលៗគ្នា វាអត់ខុសគ្នាទេ។ រឿងចាម និងខ្មែរនោះ។ បាទធ្វើបុណ្យដូចគ្នា ហើយតែធ្វើបុណ្យចាមនិងខ្មែរអត់ៗខុសគ្នាទេ។

**ស៖** ចុះការស្លៀកពាក់ទុំងខុសគ្នាទេ? មានន័យថា គេអាចសម្គាល់ច្បាស់ទេនៅពេលដែលគេដើរទៅឃុំពាមជីកងហ្នឹង ដើរទៅអាចដឹងថា អ្នកណាជាខ្មែរ អ្នកណាចាមទេ តាមរយៈសម្លៀកបំពាក់នោះ?

[១៤:២៦:២៦]

**ឆ៖** ដឹង ស្លៀកសម្លៀកបំពាក់ដឹងៗថាខ្មែរ ថាចាម ដឹងព្រោះសម្គាល់ទៅលើសម្លៀកបំពាក់។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលដល់ពេលដែលខ្មែរក្រហមចូលមកដល់តំបន់របស់លោក។ តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះបានទេថា ពេលខ្មែរក្រហមមកដល់ហ្នឹងមានការជម្លៀសមេដឹកនាំសាសនានៅក្នុងភូមិរបស់លោកទេ?

**ឆ៖** ជម្លៀស មកដល់ជម្លៀសទៅមួយចំនួនធំ បាទ ជម្លៀសទៅមួយចំនួនធំ ព្រោះអីជម្លៀស ហ្នឹងយកទៅដាក់ចម្រុះទៅខាងៗលើ មិនដឹងជាភូមិអីទេ នៅតែគ្រប់ភូមិហ្នឹងនៅខាងលើណោះ។ ចម្រុះ កុំឲ្យថា នៅផ្តុំផ្តុំគ្នា អត់បានទេ ត្រូវបំបែកគ្នា។ ប៉ុន្តែផែនការគេ រឿងអាថ៌កំបាំងរបស់គេខ្ញុំមិនដឹងទេ ប៉ុន្តែគ្រាន់តែឃើញទៅហើយ ព្រោះខ្ញុំនៅក្នុងភូមិហ្នឹងវាបាត់មនុស្សមួយពាក់កណ្តាលទៅហើយ បាទ បាត់ទៅហើយ ហើយមិនដឹងទៅណាទៅទិសណាទេ មិនដឹងទៅងាប់ មិនទៅរស់ ប៉ុន្តែគ្រាន់តែឮ ចចាមអារ៉ាមថាយកទៅចែកគ្នាក្នុងភូមិម្នាក់មួយ ម្នាក់ពីរ នៅចម្រុះ។

**ស៖** តើមេដឹកនាំសាសនានិងអ្នកចេះដឹងជនជាតិនៅក្នុងភូមិលោកនោះមានត្រឡប់មកវិញទេ ក្រោយឆ្នាំ១៩៧៩នោះ ឬក៏លោកមិនដែលឃើញពួកគាត់ត្រឡប់មកវិញទេ។ ឧទាហរណ៍ដូចជា <ហាក៏ម> អីជាដើមហ្នឹងក្រោយឆ្នាំ៧៩ហើយ លោកឃើញពួកគាត់វិញទេ?

[១៤:២៨:៤៩]

**ឆ៖** បាត់មនុស្សច្រើន មានឃើញខ្លះ ហាក៏ម, យូសុះ, ក៏ម យូសុះ នៅ – ពួកក៏ម យូសុះ នៅ ត្រឡប់មកវិញ។ រួចក្រៅពីហ្នឹងអត់ឃើញៗ មានន័យថាងាប់អស់ហើយ។

**ស៖** ពេលដែលខ្មែរក្រហមកាន់អំណាច តើខ្មែរក្រហមធ្វើយ៉ាងម៉េចចំពោះវិហារសាសនាចាម នៅពាមជីកងនោះ គេយកទៅធ្វើអី?

**ឆ៖** វាយកត្បាល់កិនយកទៅដាក់លើវិហារ យកស្រូវ អង្ករ យកទៅដាក់លើវិហារទាំងអស់ ព្រោះគ្មានអ្នកណាមកថ្វាយបង្គំទៀតទេ។ វាកម្ចាត់អស់ហើយ។ វាយកៗអង្ករទៅដាក់ក្នុងហ្នឹង យកដូច ជាស្រូវ ដូចជាត្បាល់កិន ទៅកិនក្នុងហ្នឹង ដែលសាសនាមូស្លីមនេះ មិនឲ្យស្រីឡើងវិហារទេ វាយកស្រី ទៅកិន យកធ្វើត្បាល់នៅនុ៎ង លើវិហារហ្នឹងកន្លែងព្រះហ្នឹងបាទ។

**ស៖** នៅសម័យនោះ គេមានរឹបអូសគម្ពីរគូរ៉ាអានទេ ហើយគេមានដុតចោលទេ នៅក្នុងភូមិ របស់លោកនោះ?

**ឆ៖** ដូចមិនបានឃើញដុតដែរ ប៉ុន្តែហាម មិនបានឃើញដុតទេ ប៉ុន្តែហាមកុំគោរព កុំថ្វាយបង្គំ ត្រូវតែស៊ីជ្រូក ត្រូវតែហូប ត្រូវតែកាត់សក់ ត្រូវកុំទទូលក្រមា កុំរបៀបរបបដូចចាម បានប៉ុណ្ណឹង។ ពី រឿងថា -- បាទរឿងហ្នឹងរឿងច្បាស់ហើយ។

**ស៖** សូមអរគុណ។ មុននេះ លោកនិយាយអំពីការជម្លៀសជនជាតិចាមជាច្រើន ហើយក្រោយ មកនុ៎ងនៅសល់តែគ្រួសារប្រហែលជា៣០ជាងទេ។ លោកបានឆ្លើយប្រាប់ អ៊ីសា ឧស្មាន គឺឯកសារ

E3/9338 ដែលជាសៀវភៅដកចេញពីការបះបោរ<របស់ជនជាតិចាម>។ ជាភាសាបារាំង 0028 6655 រហូតទៅដល់ 56។ ជាភាសាអង់គ្លេស 00218503, ជាភាសាខ្មែរ 00218496 លោកបានឆ្លើយដូចតទៅ៖

[១៤:៣២:១៦]

ខ្ញុំសូមដកស្រង់៖ “នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសអ្នកភូមិរបស់ខ្ញុំម្តងទៀត គឺជម្លៀសក្នុងបរិមាណដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងពេលនោះ គឺមានតែ៣០គ្រួសារប៉ុណ្ណោះដែលមិនត្រូវជម្លៀស។ ខ្មែរក្រហមមានបំណងបញ្ជូនជនជាតិចាមទៅឲ្យស្លាប់ ដោយបង្អត់បាយ និងជំងឺ។ រីឯអ្នកដែលនៅសេសសល់៣០គ្រួសារ មិនយូរ មិនឆាប់ក៏គង់តែងាប់ ឬត្រូវគេសម្លាប់ដូចគ្នា។ ធ្វើយ៉ាងនេះ ខ្មែរក្រហមចង់ឲ្យជនជាតិចាមបែកបាក់កម្លាំងគ្នា ព្រោះថា បើនៅជុំគ្នា ខ្លាចយើងតដៃដូចបងប្អូនចាមនៅភូមិកោះផល។” សូមបញ្ចប់នូវការដកស្រង់ចម្លើយរបស់លោក ដែលលោកបានឆ្លើយជាមួយ អ៊ីសា ឧស្មាន។ នៅក្នុងសម្រង់នេះ លោកបាននិយាយថា ខ្មែរក្រហមនុំងចង់ឲ្យជនជាតិចាមហ្នឹងស្លាប់ដោយបង្អត់បាយ និងឲ្យស្លាប់ដោយសារជំងឺ។ តើលោកមានមូលដ្ឋានអីបានជាលោកហ៊ានឆ្លើយបែបនេះជូន អ៊ីសា ឧស្មាន នោះ? លោកមានព័ត៌មានអីខ្លះបានជាលោកហ៊ាននិយាយថា ខ្មែរក្រហមនុំងមានបំណងឲ្យជនជាតិចាមហ្នឹងស្លាប់តាមរយៈការបង្អត់បាយ និងជំងឺនោះ?

[១៤:៣៣:៣៦]

**ឆ៖** ព្រោះខ្ញុំប៉ាន់ស្មាន មិនមែនប៉ាន់ស្មានទេ មូលដ្ឋាននោះ វាមានៗដោយថា ខ្លួនខ្ញុំនេះពិសោធឲ្យខ្លួនខ្ញុំងាប់ រត់មិនចង់រួចផង។ ហើយចុះបើយកបងប្អូនខ្ញុំបាត់ទៅ រឿងអីវាយកទៅទុកហ្នឹង។ បាទ ខ្ញុំប៉ាន់ស្មានអ៊ីចឹង ព្រោះខ្លួនខ្ញុំនេះ វាយកទៅបាញ់ចោលនៅ៣០គ្រួសារនេះ នៅក្នុងភូមិសាច់សូនេះ។ អ៊ីចឹងមានន័យថា វាបំបែកហើយបានវាយកទៅសម្លាប់ រួចទៅស្លាប់ទៅហើយនេះខ្ញុំរត់រួចនេះ។ វា*(ឮមិនច្បាស់)* មិនស្លាប់ទេ មិនចេះស្លាប់ទេ មកតែតួន សុះ ទេអស់លោក។ មកតែតួន សុះ គេហៅថា សង្គ្រាជសុះមកម្នាក់មួយគ្រួសារនៅសព្វថ្ងៃហ្នឹង។ បាទ ហ្នឹងសូមជម្រាប់អស់លោកប៉ុណ្ណឹងលោក។ ខ្ញុំមួយសាយកប៉ុណ្ណឹង យកដែលយកខ្ញុំទៅស្លាប់ហ្នឹង។

**ស៖** សូមអរគុណលោក។ លោកដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសម្រង់នេះ លោកនិយាយអំពីហេតុការណ៍នៅកោះផល គឺការបះបោររបស់ជនជាតិចាម។ <តើពេលនោះ>នៅឆ្នាំ១៩៧៥<លោកបានឮពីការបះបោរនោះដែរឬទេ?> ឬក៏ក្រោយរបបខ្មែរក្រហមនោះ លោកធ្លាប់ឮគេនិយាយអំពីហេតុ

ការណ៍នៅកោះផលហ្នឹងទេ?

[១៤:៣៥:០៣]

**ឆ៖** ខ្ញុំនៅក្នុងភូមិសាច់សូនេះ ខ្ញុំឮ ព្រោះខ្ញុំឮ ខ្ញុំនេះអ្នកជីកដីទេ អ្នកប្រើកម្លាំង ដែលវាប្រើទៅជីកដី ជីកនោះជីកនេះ ប៉ុន្តែស្តាប់ឮ អ្នកផងទាំងអស់ហ្នឹង ឮវានិយាយថា "កោះផលនេះបះបោរគេនឹងបង្ក្រាបសព្វថ្ងៃនេះ" បាទ ផុតបាត់កោះផលទៅ ដែលបង្ក្រាបហ្នឹង តានតឹងពីហ្នឹងមកតែម្តងៗបាទ ស្មានតែប៉ុណ្ណឹង ស្មាន។ កោះផលហ្នឹង វាចាមកោះផលបះបោរ។ អ៊ីចឹងគេបង្ក្រាបបានហើយ។ អ៊ីចឹងពីហ្នឹងមកវាប្រយ័ត្នចាមហ្នឹង រឿងជនជាតិ ប្រយ័ត្នមែនទែនបាទ។ អ៊ីចឹងចាម ពួកជនជាតិខ្ញុំនេះមិនជា ប្រយ័ត្នយ៉ាងម៉េច ក៏មិនឈ្នះពួកមូស្លីមហ្នឹងដែរ មិនឈ្នះត្រង់កន្លែងអី?រឿងថ្វាយបង្គំព្រះទេណ៎ាទោះបីអ្នកឯងឃាត់ក៏វាលបថ្វាយ បើវាថ្វាយលើផ្ទះមិនបាន មានគេឃើញវាថ្វាយក្នុងចិត្តលាក់មិនបានគឺគេថ្វាយ យូរៗទៅប្រហែលជាវាដឹងរឿងហ្នឹងហើយ បានយូរៗអស់មួយពូជៗបន្តិចៗអស់មួយពូជ ទាល់តែអស់។ វាដឹងរឿងថាតាមលបថ្វាយបង្គំ ចាមហ្នឹងរឹងណាស់។ ប៉ុនណ៎ា អី ខ្ញុំវាយស្មានដែរទេប្រហែលជាអ៊ីចឹងហើយ ពីព្រោះវាមានឈ្លបវា បីនាក់មើលម្នាក់ មើលពីរនាក់ បីនាក់មើលពីរនាក់ គេហៅប្រធានពួក។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ មានឃ្លាមួយដែលខ្ញុំចង់អានឲ្យលោកស្តាប់ គឺវាស្ថិតនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកគឺលេខ E3/4706 ហើយចំណុចនេះក៏មាននិយាយនៅក្នុងសៀវភៅការបះបោររបស់ចាមដែរ លេខ ERN ជាភាសាអង់គ្លេស គឺ 00417861, ជាភាសាខ្មែរ 00369050, ជាភាសាបារាំង គឺ 00898349។ នេះជាចម្លើយដែលលោកបានឆ្លើយពាក់ព័ន្ធនឹងឆ្នាំ១៩៧៦ លោកបាននិយាយថា៖ "ខ្មែរក្រហមបានផ្សព្វផ្សាយថាចាប់ពីពេលនេះទៀតទៅគឺលែងមានចាមលែងមានខ្មែរហើយ គឺយើងជាជាតិតែមួយគឺជាតិខ្មែរ ហេតុហ្នឹងហើយបានជាយើងទាំងអស់គ្នាត្រូវតែហូបបាយរួម។" សូមបញ្ចប់ការដកស្រង់។ តើការប្រកាសរបស់ខ្មែរក្រហមហ្នឹងលោកឮញឹកញាប់ទេ? ហើយខ្មែរក្រហមឬក៏កម្មាភិបាលខ្មែរក្រហមហ្នឹងមានបានពន្យល់ប្រាប់លោកទេថាហេតុអ្វីបានជាឲ្យជនជាតិចាមហ្នឹងក្លាយទៅជាខ្មែរនោះ?

[១៤:៣៨:៤២]

**ឆ៖** វាចង់ផ្សាចិត្តមួយថ្លើមមួយ ឲ្យទៅជាចាមទៅជាខ្មែរទៅវិញបាទ។ វាចងចិត្តមួយថ្លើមមួយហ្នឹងហើយ ឲ្យទៅជាខ្មែរ ឲ្យអស់ចាមៗនៅសល់តែខ្មែរបាទ ប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោក ហ៊ឹម ម៉ាន ស្តាប់ៗសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិហ្នឹង ស្តាប់ឲ្យបានយល់ ហើយសឹមឆ្លើយតបឲ្យចំនឹងសំណួរណ៎ះ! លោកហាក់ដូចជាស្តាប់សំណួរមិនយល់ទេ ឆ្លើយទៅវាមិនចំនឹងសំណួរ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំនឹងអង្គន់សំណួរនេះជាពីរ។ តើលោកធ្លាប់ស្តាប់ឮអំពីការប្រកាសរបស់ខ្មែរក្រហមថា ខ្មែរហ្នឹងគឺគ្មានជាតិខ្មែរ គ្មានជាតិចាមអីទេ គឺត្រូវតែជាតិតែមួយ ហើយត្រូវហូបរួមគ្នា។ ខ្ញុំចង់ដឹងថា លោកធ្លាប់ស្តាប់ឮការប្រកាសហ្នឹងញឹកញាប់ទេ?

**លោក ហ៊ឹម ម៉ាន៖**

**ឆ៖** វាមិនញឹកញាប់ហ្នឹងខ្ញុំហ្នឹង ព្រោះប្រធានភូមិហ្នឹងវាមិនប្រកាសញឹកញាប់ទេ ដល់ពេលវាប្រកាស វាអីទេ មានខ្ញុំទៅលើកដីហ្នឹង ក៏វាមានដែរ ព្រោះខ្ញុំខាងកម្លាំងពលកម្ម ខ្ញុំបញ្ចេញ បាទ រួចអីចឹងវាៗប្រកាសអីចឹងមែនទេ ប៉ុន្តែឮមកហ្នឹង ប៉ុន្តែមិនមែនថាញឹកញាប់ទេ។

**ស៖** សូមអរគុណ។ ខ្ញុំមានត្រឹមតែ១០ ឬ១៥នាទីទៀតទេ ខ្ញុំព្យាយាមសួរឲ្យលឿន ពាក់ព័ន្ធនឹងវត្តអូរត្រកួនវិញម្តង។ មុនពេលក្រុមចាមធំ ដែលគេនាំទៅកាន់វត្តនោះ ហើយទៅជាមួយលោក ហើយលោករត់គេចខ្លួននោះ តើលោកដឹងទេថាខ្មែរក្រហមបានយកវត្តហ្នឹងធ្វើជាមន្ទីរសន្តិសុខ?

**ឆ៖** ឮតាមគេៗប៉ុល ពត វាដើរពាសវាលអីចឹងទៅ ឮវានិយាយទៅខ្ញុំមិនច្បាស់ថាខ្ញុំមិនដែលទៅវត្តផងហ្នឹង គ្រាន់តែឮថាកន្លែងហ្នឹងដាក់ច្រវាក់ ដាក់តាំងពីស្អី ដាក់ខ្នោះដាក់អីមនុស្សនៅកន្លែងហ្នឹង។

**ស៖** លោករស់នៅឆ្ងាយពីវត្តអូរត្រកួនទេ ភូមិសាច់សូលោកនោះ ខ្ញុំចង់ដឹងថាចម្ងាយពីផ្ទះរបស់លោកក្នុងភូមិសាច់សូ ទៅវត្តហ្នឹងមានចម្ងាយប៉ុន្មានម៉ែត្រដែរ?

**ឆ៖** ខ្ញុំជម្រាបទៅវាទៅជាគេហៅថាស្មាន ប៉ុន្តែខ្ញុំស្មានកាលពីខ្ញុំស្មានហ្នឹងគឺប្រហែលជា១០០ម៉ែត្រ ប៉ុន្តែស្មានទេ មិនដឹងត្រូវមិនដឹងខុសទេ ព្រោះខ្ញុំមិនបានទៅវាស់ សុទ្ធតែស្មានទាំងអស់ពេលនោះ។ ស្មានៗ មិនបានទៅវាស់ម្តងផង។

[១៤:៤២:៣៩]

**ស៖** ក្នុងឆ្នាំ៧៦, ៧៧មុនពេលគេចាប់ខ្លួនលោកជាមួយនឹងចាមផ្សេងទៀតដើម្បីបញ្ជូនទៅវត្តអូរត្រកួននោះ លោកធ្លាប់សង្កេតឃើញថាមានក្លិនស្អុយភាយចេញពីវត្តមកទេ?

**ឆ៖** រណ្តៅដែលខ្ញុំនៅពួននៅក្នុងស្រះដែលមានកំប្លោកហ្នឹងស្អុយក្លិន ដោយស្អុយក្លិនហ្នឹងមក ខ្ញុំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដកដង្ហើមធំវែង ដើម្បីក្លិនហ្នឹងមិនមែនធុំស្អុយទេ ធំក្រអូបហើយឆ្ងាញ់ដូចងៀតសំយ៉ង់អ៊ីចឹងបាទ ដូចងៀតសំយ៉ង់ ហឹតដែលវាឃ្លានបាយខ្លាំងបាទ ខ្ញុំហឹត។

**សៈ** សូមអរគុណលោក។ ខ្ញុំមិនមែននិយាយពេលដែលលោករត់គេចក្នុងបឹងទេ ខ្ញុំនិយាយមុនហ្នឹង នៅពេលដែលលោកនៅផ្ទះលោកនៅសាច់សូនោះ លោកមានធ្លាប់ធុំក្លិនស្អុយចេញមកពីវត្តទេ?

**ឆៈ** នៅភូមិសាច់សូហ្នឹង គ្មានពីណានៅម្នាក់ទេ ទៅងាប់អស់ហើយ ពីណាគេនៅលើផ្ទះ អត់មានទេអស់លោក។ ពេលក្លិនហ្នឹង ក្លិនគេយកទៅសម្លាប់អស់ហើយ គ្មានពីណានៅចាំស្រូបក្លិននៅលើផ្ទះទេ បាទ ព្រោះចាមងាប់អស់ហើយ ងាប់រួចខ្ញុំពីរនាក់ហ្នឹង។

**សៈ** ខ្ញុំមិនទទូចសួរលោកទៀតទេ ព្រោះខ្ញុំមានពេលខ្លីណាស់។ តើលោកមានឃើញកម្មាភិបាលនិរតីមកចូលនៅក្នុងភូមិលោកទេ?

**ឆៈ** ខ្ញុំមិនបានឃើញទេ ព្រោះសុទ្ធតែខ្មៅៗទាំងអស់ មិនដឹងលោកណាធ្វើធំ លោកណាធ្វើតូចខ្ញុំមិនបានដឹងឃើញ ប៉ុន្តែមិនបានដឹងថា លោកនេះធ្វើនេះ លោកនោះធ្វើនោះ អត់ដឹងទាំងអស់ចំពោះខ្ញុំ។ មនុស្សខ្ញុំដូចខ្ញុំជម្រាបថាមនុស្សពលកម្ម គេឲ្យរែកដី គេឲ្យជីកប្រឡាយ មិន -- គ្រាន់តែឃើញខ្មៅ អូ៎! ខ្មៅ។ បាទ ប៉ុណ្ណឹង។ ឃើញៗ។

**សៈ** អម្បាញ់មិញ លោកនិយាយអំពីឈ្មោះ កាន លោកដឹងថាគាត់មកពីណាទេ? ហើយគាត់និយាយហ្នឹង គឺមានតុងខុសពីអ្នកនៅភូមិភាគឧត្តរទេ ខុសពីកម្មាភិបាលភូមិភាគឧត្តរទេ?

**ឆៈ** កាន ហ្នឹងមិនមែននៅភូមិយើងទេ។ គាត់ឈ្មោះ កាន ហ្នឹងមិនមែននៅភូមិយើងទេ។ ឮតែឈ្មោះ កានៗ ហ្នឹង។ ប៉ុន្តែឮសម្ដីថា ប្រាប់ឲ្យបងប្អូនឲ្យ តាម៉ាន ហ្នឹងរស់ទៅ ក៏ខ្ញុំមិនបានឃើញជួបនឹងគាត់ដែរ ឮតែអ្នកភូមិទេប្រាប់ខ្ញុំ។ កាន ហ្នឹងមិនមែននៅភូមិសាច់សូ ហ្នឹងទេ ហើយនៅក្បែរៗហ្នឹងទេ ប្រហែលជានៅខាងណាទេ ខ្ញុំមិនដឹងបាទ រឿង កាន ហ្នឹង។

[១៤:៤៦:៤០]

**សៈ** ឥឡូវនេះ ខ្ញុំនិយាយអំពីថ្ងៃដែលគេប្រមូលពួកលោក ហើយនិងបញ្ជូនទៅវត្តអូរត្រកួន។ លោកអាចបញ្ជាក់បានទេ ថានៅពេលនុ៎ងមានចាមប៉ុន្មាននាក់ដែលពួកឈ្លបដាវវែង ឬក៏ពួកឈ្លបហ្នឹងប្រមូលផ្ដុំយកទៅវត្តអូរត្រកួននោះ?

**ឆៈ** ខ្ញុំគ្រាន់តែវាយស្មានទេ បើមិន៣០គ្រួសារទេ ២០គ្រួសារជាងពីព្រោះខ្ញុំមនុស្សមិនដែលធ្វើប្រធានក្រុមផងហ្នឹង ខ្ញុំ--ព្រោះវាយកទៅទាំងអស់ហ្នឹង។ យកទាំងខ្ញុំ ទាំងអីហ្នឹង។ បាទ ខ្ញុំប្រហែលដែរ

ទេ ប៉ុន្តែងាប់អត់ប្រហែលទេ ងាប់អស់ហើយ។ បាទ នេះគ្រាន់តែប្រហែល ប៉ុន្តែងាប់អស់ហើយ។

**សៈ** ខ្ញុំចង់អានសម្រង់នៃកិច្ចសម្ភាសន៍របស់ អ៊ីសា ឧស្មាន ជាមួយលោក គឺឯកសារ E3/9338 ជាភាសាខ្មែរ 00218497, ជាភាសាបារាំងគឺ 00286656, ជាភាសាអង់គ្លេសគឺ 00218503។ លោកបានឆ្លើយដូចតទៅ ហើយប្រហែលជាលោកអាចចងចាំនូវតួលេខឡើងវិញ។ ខ្ញុំសូមដកស្រង់៖ "នៅម៉ោងបី ខ្មែរក្រហមចាប់ផ្តើមប្រមូលជនជាតិចាមដែលនៅតាមផ្ទះនីមួយៗ ទូទាំងស្រុកកងមាស។ ភាគច្រើននៃអ្នកទាំងនេះ គឺជាអតីតអ្នកភូមិសាច់ស្វ ភូមិអន្ទង់ស និងភូមិអង្គរបាន ដែលមានចំនួនរាប់រយនាក់។" សូមបញ្ចប់ការដកស្រង់។ តើលោកអាចបញ្ជាក់បានទេថា ជនជាតិចាមដែលប្រមូលផ្តុំពេលនុំងគឺមានអ្នកមកពីភូមិ<ផ្សេងៗគ្នានៅក្នុងឃុំ និងស្រុករបស់លោក>?

**ឆៈ** អ្នកហ្នឹងបានជាវាងាប់ទាំងអស់ហ្នឹង វាងាប់ស្មើៗគ្នាហ្នឹង ដោយសារថា ពលកម្មជីកទំនប់មួយៗវាបញ្ជូនមកទាំងអស់ ហើយដល់ពេលស្លាប់វិញ ក៏ស្លាប់ចម្រុះគ្នាដែរ។ រឿងអីបើ ខ្ញុំនៅសាច់ស្វ ក៏ដឹងនៅអង្គរបាន? ដោយសារវាបញ្ជូនមនុស្សហ្នឹងមកធ្វើពលកម្ម។ រួចដល់ពេលវាងាប់ វាចាប់យកទៅចម្រុះគ្នាដូចវាមកធ្វើការអីចឹងដែរ បាទ ចម្រុះគ្នាងាប់ហ្នឹង ងាប់មែន។ ងាប់ចាមហ្នឹងអន្ទង់ស អង្គរបានសាច់ស្វហ្នឹង ដោយសារខ្ញុំឃើញជុំគ្នាហ្នឹង ព្រោះវាមកធ្វើការជាមួយគ្នា គ្រប់ភូមិមកធ្វើការជាមួយគ្នា។ រួចដល់អីចឹងគេចាប់ចាម វានៅអន្ទង់សមែន ប៉ុន្តែវាចាមដែរ វានៅសាច់ស្វមែន ប៉ុន្តែវាចាមដែរ វាត្រូវតែងាប់។

[១៤:៥០:០០]

**សៈ** នៅថ្ងៃដែលគេប្រមូលជនជាតិចាមនៅក្នុងភូមិរបស់លោក តើមានត្រឹមតែរាប់សិប ឬក៏រាប់រយនាក់ដូចដែលលោកបានឆ្លើយកាលពីមុនជាមួយនឹង អ៊ីសា ឧស្មាន នោះ?

**ឆៈ** វារាប់សិបហ្នឹងតែភូមិចាមទេ ប៉ុន្តែវាដោយភូមិគេមក វាសាសនាមូស្លីមដូចគ្នា ប៉ុន្តែវាត្រូវជាប់រយហើយៗ ដូចជាអន្ទង់ស អង្គរបានអី គឺវាសុទ្ធតែចាមដូចគ្នា វាស្លាប់ដែរ អ៊ីចឹងវាជាប់រយពាន់ទៅហើយ។ បាទ អ៊ីចឹងតែភូមិខ្ញុំ វាបន្តិចបន្តួចទេ ព្រោះវាទៅ ជម្លៀសទៅមួយចំនួនទៅ នៅសល់ប៉ុន្មានជាង ២០គ្រួសារ ឬមួយ៣០គ្រួសារហ្នឹង ខ្ញុំស្មានទេ ព្រោះខ្ញុំទៅងាប់ជាមួយគ្នាហ្នឹង ខ្ញុំរត់រួចហ្នឹង។ ព្រោះខ្ញុំច្បាស់គ្រង់ងាប់ខ្លួនឯងហ្នឹងហើយតើ ច្បាស់តែទៅជាមួយពួកហ្នឹងហើយតើ។

**សៈ** នៅល្ងាច នៅពេលដែលមានការសម្លាប់មនុស្សនោះ លោកឮជនជាតិចាមស្រែក "អាឡា! ៗ"នៅពេលដែលលោកលាក់ខ្លួននោះ។ ចុះពេលៗហ្នឹង នៅជុំវិញវត្តហ្នឹង លោកមានឮសំឡេងគេចាក់

ភ្លេងតាមមីក្រូអីទេ?

**ឆ៖** ហ្នឹងវាឮឈ្មោះ វា១ឮសម្រែកដែលឈឺចាប់ ស្រែក "អស់ឡោះប៉ូលីយ! យ៉ាអស់ឡោះ អស់ឡោះប៉ូលីយ!" អ៊ីចឹងកន្លែងហ្នឹងបានខ្ញុំថាមីក្រូក៏ថាត្រូវដែរ បើខ្ញុំថាមិនមែនមីក្រូក៏ត្រូវដែរ១ម៉េច? ដោយសារខ្ញុំវានៅវាកៀក ព្រោះមីក្រូ ម៉េចក៏មិនឮគ្រឹកគ្រាក់។ ប៉ុន្តែម៉េចក៏ឮថា "អស់ឡោះ!" អស់ឡោះ មិនជនជាតិពួកខ្ញុំ! ព្រោះថាឮខ្លាំងមីក្រូ១ ខ្ញុំមិនចេះថា។ ខ្ញុំថាអត់ឃើញមីក្រូ ឮសម្រែកមនុស្សស្រែក ហៅ "អស់ឡោះ"។

[១៤:៥២:៤៩]

**ស៖** តើលោកដឹងទេថា រឿងរ៉ាវរបស់លោកជាមួយប្រពន្ធលោកដែលរស់រានមានជីវិតពីភូមិសាច់ស្ងួនេះ គឺគេដឹងឮទេនៅក្នុងស្រុករបស់លោកនេះ ដូចជាអ្នកអតីតឈ្លប អតីតសន្តិសុខអីហ្នឹងដឹងទេ ដឹងថាលោកដឹងរស់រានមានជីវិតទេ?

**ឆ៖** ដឹងតើលោក ដឹង១សឹងថាពាក់កណ្ដាលដែលដឹង ៥០ភាគរយ ដឹងដែលខ្ញុំនៅរស់ជាមួយប្ដីប្រពន្ធខ្ញុំហ្នឹង រស់ពីក្នុងបឹងគេដឹង ដឹងទាំងអស់។ គេហៅខ្ញុំតាម៉ានស៊ីកំប្លោក១ ដោយសារខ្ញុំហូបកំប្លោក។ អ៊ីចឹងគេដឹងមួយស្រុក តាម៉ានកំប្លោក បានរកខ្ញុំឃើញ។ ហូបកំប្លោកហ្នឹងបានគេហៅ "តាម៉ានកំប្លោក" បានរកខ្ញុំឃើញ។

**ស៖** ក្នុងចំណោមអ្នកយាម ឬឈ្លបដាវវែង លោកស្គាល់ឈ្មោះ តាយ គឹមហ៊ាន់ ទេ?

**ឆ៖** ខ្ញុំមិនបានស្គាល់អស់លោក ពីព្រោះថា -- ប៉ុន្តែដឹងច្បាស់ថា មកចាប់ពួកខ្ញុំហ្នឹងមានច្រើនណាស់ មានច្រើន។ ប៉ុន្តែខ្ញុំស្គាល់តែពីរបីនាក់ ដូចខ្ញុំជម្រាបទៅមុន។ រួចកន្លែងណាដែលខ្ញុំឃើញ ខ្ញុំនិយាយការពិត មិនឃើញ បើឃើញច្រើន ប៉ុន្តែមិនស្គាល់ឈ្មោះបាទ មិនស្គាល់ឈ្មោះ។

**ប្រធានអង្គជំនុំ៖**

បាទ១ បានហើយ តាម៉ាន អើយ ចាំស្ដាប់សំណួរបន្តទៀត! ពេលវេលាខ្លីណាស់ ទំនងចប់ហើយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំនឹងបញ្ចប់ដោយដកស្រង់ចំណុចពីរ។ ទី១ គឺចម្លើយរបស់ តាយ គឹមហ៊ាន់ នៅក្នុងឯកសារ E3/5257, ទំព័រជាអង់គ្លេស 00251021, ជាភាសាបារាំង 00342673, ជាភាសាខ្មែរ <00243107> ទៅដល់ 08។ គេសួរសំណួរគាត់ដូចតទៅ៖ "តើមានចាមជម្លៀសមកទីនេះនៅរស់ទេ?

គាត់ឆ្លើយថា៖ មានរស់ គឺមួយគ្រួសារ។ សួរ៖ លោកស្គាល់ឈ្មោះគ្រួសារហ្នឹងទេ ប្ដីឈ្មោះ ម៉ាន? ខ្ញុំអត់ស្គាល់ឈ្មោះប្រពន្ធរបស់ ម៉ាននេះទេ។ សួរ៖ តើចាមទាំងអស់ត្រូវគេសម្លាប់មែនទេ? ឆ្លើយ៖ ប្រហែលជាគេអ៊ីចឹងហើយ គេសម្លាប់ស្ទើរតែទាំងអស់ គឺពិតណាស់ គឺចាមត្រូវបានគេសម្លាប់។" លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកស្គាល់ឈ្មោះ សេង ស្រ៊ុនទេ? គាត់ជាជនជាតិខ្មែរ ហើយគាត់ធ្វើការនៅភូមិសាច់សូនេះដែរ។

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន!

[១៤:៥៦:៤១]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនដឹងថាខ្ញុំច្រឡំ ឬក៏យ៉ាងម៉េច។ អំមិញគាត់ដក<ស្រង់>នូវចម្លើយរបស់ តាយ គឹមហ៊ាន់ ដល់តែពេលគាត់សួរ ដូចជាអត់មានឮសួរឈ្មោះ តាយ គឹមហ៊ាន់ ហ្នឹងទេ ទៅសួរឮឈ្មោះ សេង ស្រ៊ុន ទៅវិញ។ ខ្ញុំមិនដឹងថា ខ្ញុំស្ដាប់ទៅយ៉ាងម៉េច? ចេញពីតាយ គឹមហ៊ាន់ ចូលទៅ សេង ស្រ៊ុន ដូចជាអត់មានស៊ីចង្វាក់គ្នា អត់មានទំនាក់ទំនងគ្នា។ ខ្ញុំអត់យល់សំណួររបស់សហព្រះរាជអាជ្ញា។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** សម្រាប់ជាប្រតិចារឹក ខ្ញុំសួរសំណួរបន្ទាប់ពីខ្ញុំអានចម្លើយរបស់ សេង ស្រ៊ុន គាត់គឺដោយបញ្ជាក់ថា លោកនេះ គាត់រស់នៅជាមួយប្រពន្ធគាត់ មានជីវិតជាមួយប្រពន្ធគាត់។ អ៊ីចឹងខ្ញុំសួរបញ្ជាក់ម្ដងទៀត ថាលោក ស្គាល់ឈ្មោះ សេង ស្រ៊ុន ហ្នឹងទេ?

**លោក ហ៊ីម ម៉ាន៖**

**ឆ៖** អាស្រ៊ុនៗ ខ្ញុំស្គាល់តើ នៅភូមិសំបួរមាស "ក" បាទ។

**ស៖** ខ្ញុំសូមអាននូវចម្លើយរបស់គាត់ ដែលគាត់ឆ្លើយពាក់ព័ន្ធនៅលោក គឺនៅក្នុងរបាយការណ៍សម្ភាសរបស់សហព្រះរាជអាជ្ញា គឺឯកសារ E3/5302, ជាភាសាបារាំង 00623191, ជាភាសាខ្មែរ 00635176, ជាភាសាអង់គ្លេស 00210488។ គាត់និយាយថា៖ "ពេលដែលខ្ញុំចូលមកផ្ទះខ្ញុំ<ពីការដ្ឋានព្រៃងជុំ> គេឱ្យខ្ញុំចូលទៅក្នុងក្រុមសន្តិសុខឃុំ ដែលទៅចាប់ជនជាតិចាមទាំងអស់នៅតាមផ្ទះ។ ខ្ញុំជាសមាជិកក្រុមនេះ គេប្រាប់ឱ្យខ្ញុំឃាមចាមដែលគេចាប់បាន ហើយគឺឃាមនៅខ្លោងទ្វារវត្ត គឺនៅខែ

សីហា ឆ្នាំ៧៧ នៅពេលនោះ ចាមនៅក្នុងភូមិទាំងអស់នៃឃុំរបស់ខ្ញុំត្រូវបានគេប្រមូល ហើយចាប់យកមកទុក។ មានតែចាមពីរនាក់តែប៉ុណ្ណោះបានរត់រួច ហើយគេចខ្លួននៅជិតបឹង។ ចំនួនចាមដែលគេចាប់នុំងគឺប្រហែលជា៣០០នាក់។" នៅបន្ថមកទៀតគាត់ថា៖"នៅចុងឆ្នាំ៧៨ គេឃើញចាមពីរនាក់ដែលរត់គេចខ្លួននោះ ដែលងើបចេញមកពីបឹងមកវិញ គេចាប់បានតែគេអត់សម្លាប់ទេ។ អ្នកទាំងពីរហ្នឹងរស់នៅសព្វថ្ងៃនៅភូមិសាច់ស្វ ឃុំពាមជីកង ហើយប្រុសនោះ ឈ្មោះ ម៉ាន ហើយស្រីនោះ អ៊ឹម ជា ពីរនាក់ហ្នឹងជាប្តីប្រពន្ធនឹងគ្នា។" សូមបញ្ចប់ការដកស្រង់។

[១៤:៥៩:៥២]

ក្នុងសម្រង់នេះ គឺ សេង ស្រ៊ុន គាត់និយាយនៅខែសីហា ឆ្នាំ៧៧ គឺវាពាក់ព័ន្ធនឹងពេលដែលគេប្រមូលផ្តុំជនជាតិចាម ហើយចាប់យកទៅវត្តអូរត្រកួន។ តើលោកយល់ស្របជាមួយនឹងសេងស្រ៊ុនទេថាការចាប់ចាមទៅវត្តអូរត្រកួនហ្នឹង គឺខែសីហា ឆ្នាំ ៧៧?

**ឆ៖** ស្រ៊ុនហ្នឹង ខ្ញុំស្គាល់ៗហើយ ពេល ប៉ុន្តែអារឿងចាប់ចាមហ្នឹងខ្ញុំក៏ឯកភាពដែរ ប៉ុន្តែបើរឿងថ្ងៃខែ ខ្ញុំមិនបានវាស់ទេ បាទ រឿងចាប់ចាមហ្នឹងចាប់មែន សម្លាប់មែន ព្រោះអី អាស្រ៊ុន អីហ្នឹង ខ្ញុំគ្រាន់តែស្គាល់ប៉ុណ្ណឹងទេ ខ្ញុំស្គាល់ឈ្មោះវាច្បាស់ដែរ អាស្រ៊ុន បាទ។ ហើយចាប់ចាមហ្នឹង មែន ហើយថ្ងៃប៉ុនណាៗខែប៉ុនណា ខ្ញុំមិនបានដឹងទេ ប៉ុន្តែចាប់ចាមមែន ងាប់មែន។ ដូចស្រ៊ុនថាហ្នឹងដែរ។

**ស៖** ខ្ញុំសូមការបំភ្លឺពីរពីលោក គាត់និយាយអំពីជនជាតិចាម ៣០០ នាក់នៅក្នុងភូមិរបស់លោកដែលត្រូវបាននាំទៅវត្ត តើលោកឯកភាពទេ ត្រង់ចំណុចនេះគឺមានចាម ៣០០នាក់ដែលគេត្រូវបានចាប់ខ្លួនបញ្ជូនទៅវត្តអូរត្រកួននោះ?

**ឆ៖** ខ្ញុំឯកភាពដោយសារថា ខ្ញុំចេះតែវាយស្មានទេនៅក្នុងភូមិ ខ្ញុំអត់បានធ្វើប្រធានក្រុមប្រធានអី មិនបានធ្វើតាកឹមតាសង្គ្រាជ។ អីចឹងអាហ្នឹងវាច្បាស់ថា៣០០នាក់ហ្នឹង ប្រហែល៣០០នាក់រួចខ្ញុំក៏ប្រហែលប៉ុណ្ណោះ សុទ្ធតែប្រហែល។ អីចឹងបើវាៗនៅជិតហ្នឹងវាប្រហែលហ្នឹង វាត្រូវជាង ដែលថាច្រើនហ្នឹងណ៎ា ខ្ញុំឯកភាព ឯកភាពថាវាថាចាមងាប់ច្រើនណាស់ ខ្ញុំឯកភាព ព្រោះខ្ញុំអត់បានរាប់ចាមនៅភូមិសាច់ស្វ គ្រាន់តែងាប់ច្បាស់ណាស់បាទ ប៉ុន្តែមិនបានឃើញចំនួន ប៉ុន្តែអានេះវានៅជិតហ្នឹងដែលគេប្រមូលទៅវានៅជិតហ្នឹង ខ្ញុំឯកភាពតាមវាហើយ អាស្រ៊ុនថាចាមងាប់ច្រើនហ្នឹង ព្រោះវាប្រាកដជាងខ្ញុំ។

[១៥:០២:៣២]

**ប្រធានអង្គជំនុំ៖**

ចុងក្រោយ សំណួរចុងក្រោយ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ<គឺថាលោកស្គាល់> អ្នកយាមឬក៏សន្តិសុខ<> ដូចជា តាយ គឹម ប៊ាន់ <និងអ្នកដែលមានភារៈក្នុងការយាមកាមជនជាតិចាមដែលគេចាប់យកមក ដូចជា ស្រ៊ុន> ហើយគេដឹងថាមានតែលោកមួយទេ ដែលនៅរស់នៅរស់មានជីវិតនោះ ពីហេតុការណ៍នោះ។ អ៊ីចឹង ខ្ញុំចង់ដឹងថា លោករស់នៅជាប្រចាំថ្ងៃយ៉ាងម៉េច ដែលបើលោករស់នៅរស់រានមានជីវិតតែខ្លួនឯង ហើយនិងប្រពន្ធរបស់លោកនោះ តើលោករ៉ាប់រងនូវព្រឹត្តិការណ៍ហ្នឹងយ៉ាងម៉េច? លោកប្រឹងត្រដររស់យ៉ាងម៉េច បើមានគ្នាតែពីរនាក់ជាមួយប្រពន្ធរបស់លោកនោះ ហើយលោកបន្តរៀបរាប់រឿងរ៉ាវហ្នឹង ទៅប្រាប់កូនចៅរបស់លោកយ៉ាងម៉េច?

**លោក ហ៊ីម ម៉ាន៖**

**ឆ៖** វារស់ដែរ វារស់ដោយៗវេទនាបំផុត ខ្ញុំរស់ដោយថា ដោយអស់កម្លាំងដោយអត់បាយ ៣ខែ ២៩ថ្ងៃ ហ្នឹងគ្រាន់តែអេះក្បាលរលើកជ្រោងដៃពីរ អេះក្បាលមួយហ្នឹង ជ្រោងដៃពីរ។ អ៊ីចឹងរស់ដោយវេទនាទេ មិនមែនរស់ដោយមានកម្លាំងពេញលេញទេ អត់ទេ។ រស់ហ្នឹង បើងាប់ល្អជាង។

**ប្រធានអង្គជំនុំ៖**

សំណួរលោកតំណាងសហព្រះរាជអាជ្ញារងអន្តរជាតិចុងក្រោយ ដូចជាសំណួរហ្នឹងជ្រៅណាស់ ប្រហែលជាដើមបណ្ដឹង ហ្នឹងមិនអាចឆ្លើយតបនឹងសំណួររបស់លោកបានទេ។

បាទ ហើយសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃចន្ទ ទី២៨ ខែកញ្ញា ឆ្នាំ២០១៥ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន។ ឯដើមបណ្ដឹងរដ្ឋប្បវេណីសាក្សី ឬអ្នកជំនាញនឹងធ្វើសវនាការស្ដាប់សក្ខីកម្មបន្តពីដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះនឹងជូនដំណឹងដល់ភាគីតាមរយៈអ៊ីម៉ែល សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ហ៊ីម ម៉ាន ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកមកឲ្យបន្តផ្ដល់សក្ខីកម្មនៅថ្ងៃចន្ទ ទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនលោក ហ៊ីម ម៉ាន ត្រឡប់ទៅកាន់លំនៅដ្ឋានដែលគាត់រស់នៅវិញចុះ ហើយនិងសូមឲ្យអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃចន្ទ ទី២៨ កញ្ញា ២០១៥ ឲ្យបានម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និងខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅថ្ងៃចន្ទ ទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:០៦ នាទី)*